ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ សាលាក្ដីខ្មែរក្រហម៖ សំណុំរឿង០០២ បញ្ជាក់ពីអំណាចនៃយុត្តិធម៌

◆ សំបុត្រពីមិត្តភក្ដិរបស់ខ្ញុំដែលបានបាត់ខ្លួន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២២៧ ខែវិច្ឆិកា ឆ្នាំ២០១៨

# ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ២២៧ ខែវិច្ឆិកា ឆ្នាំ២០១៨


## មាតិកា


### សំបុត្រ

- សាលាក្តីខ្មែរក្រហម៖ សំណុំរឿង ០០២ បញ្ចប់ពីអំណាច ..........១

### ផ្នែកឯកសារ

- ព្រាំ ធី ហៅ ឆេង ជាយុទ្ធនារីចិញ្ចឹមសត្វនៅពេទ្យ ព-១៧............ ៤

### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ

- របកគំហើញថ្មីចំពោះកិច្ចការស្រាវជ្រាវពីទីតាំងសម្លាប់មនុស្ស ..... ៩
- ចំណាប់អារម្មណ៍របស់សិស្សសាលាអន្តរជាតិភ្នំពេញ ............. ១១
- ព្រឹត្តិការណ៍នៃការសម្លាប់រង្គាលនៅកោះដេជូ.......................១៣
- ហេតុការណ៍ដ៏ឃោរនៅតែដិតដាមនៅក្នុងអារម្មណ៍របស់ខ្ញុំ ....... ១៧
- អ្នកជំងឺឃ្លង់នៅក្នុងភូមិត្រើង...........................................២០
- ពាក្យស្លោកសំខាន់ពីរ ដើម្បីរំឭកពីការចងចាំ និងទប់ស្កាត់.......២៣
- ឯកអគ្គរដ្ឋទូតអ៊ីស្រាអែលប្រចាំទីក្រុងបាងកក ..................... ២៦

### ផ្នែកច្បាប់

- នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសឲ្យជាប់គុក ........... ២៩
- ការបន្ថែមបទចោទទៅលើ នួន ជា និង ខៀវ សំផន................៣១
- ដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហមលើសំណុំរឿង........ ៣៥

### វេទិកាពិភាក្សាសាធារណៈ

- ភ្នំប្រសិទ្ធិទីតាំងប្រល័យពូជសាសន៍.................................. ៣៩
- រឿងរ៉ាវរបស់ជនរងគ្រោះណាខ្លះដែលគួរត្រូវលើកយក............៤៥

### ទំព័រស្រាវជ្រាវរកគ្រួសារ

- បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម ............៤៩
- សំបុត្រពីមិត្តភក្តិរបស់ខ្ញុំដែលបានបាត់ខ្លួន........................... ៥៣
- អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ ...............................................៥៨




លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងក្រុមស្រាវជ្រាវមកពីក្រុមហ៊ុនស្ប៉ារ៉ូហក ហ្វារអ៊ុស ពិនិត្យមើលម៉ាស៊ីនវាស់ជម្រៅដី និងឆ្អឹងជនរងគ្រោះ នៃរបបខ្មែរក្រហម។


## វក្យាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ៣៧៥ ព.មប្រក

ចុះថ្ងៃអង្គារ ៦រោច ខែអស្សុជ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



***ស្នេរលេខនេះ៖*** *ទ្រី សុជាតា, ផេង ពង្សរ៉ាស៊ី, សន ប៊ុនស៊ីម, ស៊ីវធួន, រ៉ាផែល ឃីល លាន, វ៉ាន់ ថាន់ពៅដារ៉ា, ដេន វេគនើរ, ចាន ប្រាថ្នា, ឆាំង យុ, ឡុង ដានី, សា ហ្វាទីលី និង សុភ័ក្ត្រ ភាណា* ***អ្នកនិពន្ធ និងស្រាវជ្រាវ៖*** *អ៊ុន សុដារី និង ដារ៉ារដ្ឋ មេត្តា* ***អ្នកបកប្រែ៖*** *អ៊ុន សុដារី* ***និពន្ធនាយកទូទៅ៖*** *សោម ប៊ុនថន* ***ជំនួយការនិពន្ធនាយក៖*** *ហូ ជុនា* ***ក្រាហ្វិកកុំព្យូទ័រ៖*** *គីម សុវណ្ណដានី* ***គ្រប់គ្រងការចែកផ្សាយ៖*** *ឆេង វេង*



**Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org**

# សាលាក្ដីខ្មែរក្រហម៖ សំណុំរឿង០០២ បញ្ជាក់ពីអំណាចនៃយុត្តិធម៌

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលត្រូវបានស្គាល់ថាជាសាលាក្ដីខ្មែរក្រហម បានដូនដំណឹងទៅកាន់ភាគីនានាថា ដោយអនុលោមតាមវិធាន១០២ នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសាលាដំបូងនឹងប្រកាសសេចក្ដីសំអាងហេតុ និងផ្នែកនៃសេចក្ដីសម្រេចនៃសាលក្រមក្នុងសំណុំរឿង០០២/០២ ដែលពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅថ្ងៃសុក្រទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ខាងមុខនេះ នៅសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វេលាម៉ោង ៩ និង ៣០នាទីព្រឹក។

ជនជាប់ចោទដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង០០២/០២ គឺ នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំផន ជាអតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត។

ព្រឹត្តិការណ៍សំខាន់ៗទាមទារឲ្យមានការយល់ដឹង ជជែកពិភាក្សា និងឆ្លើយតបជាសាធារណៈ ប៉ុន្តែខ្ញុំចង់លើកទឹកចិត្តឲ្យមានការយល់ឃើញយ៉ាងទូលំទូលាយនៃសារសំខាន់របស់ព្រឹត្តិការណ៍ក្នុងវិច្ឆិការនេះ។ យើងបានចំណាយពេលវេលាអស់ជាច្រើនដើម្បីបង្កើតតុលាការកាត់ទោសមេដឹកនាំ ខ្មែរក្រហមនិងរយៈពេលជាង១០ឆ្នាំបានកន្លងផុតទៅហើយ ចាប់តាំងពីការបង្កើតតុលាការនេះ។ ជាការពិតណាស់ រយៈពេលជាង៧ឆ្នាំបានកន្លងផុតទៅហើយដែរ ចាប់តាំងពីការចាប់ផ្ដើម



នួន ជា ខៀវ សំផន និង មេដឹកនាំកម្មាភិបាលខ្មែរក្រហមដ៏ទៃទៀត នៅក្នុងជំនួបប្រជុំនៅផ្ទះរបស់ តាម៉ុក ស្ថិតនៅស្រុកអន្លង់វែង ក្នុងឆ្នាំ១៩៩៨។ តាម៉ុក បានស្លាប់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ដោយសារតែជំងឺបេះដូង ប្រហែលជាអាចបណ្ដាលមកពីភាពតានតឹងពីការកាត់ទោសរបស់តុលាការខ្មែរក្រហម។ រក្សាសិទ្ធិ និងរូបថតដោយ ៖ ជេម៍ ជីរាណ (Jame Jerrand)។

នៃសវនាការដំបូងក្នុងសំណុំរឿង០០២ ហើយក្នុងអំឡុងពេលនោះដែរ មានជនជាប់ចោទមួយចំនួនបានបាត់បង់ជីវិត និងបានគេចផុតពីប្រព័ន្ធយុត្តិធម៌។ ជនរងគ្រោះជាច្រើនក៏បានស្លាប់ ចំណែកឯគ្រួសារជាច្រើនទៀតនៅតែមិនដឹងថា តើមានរឿងអ្វីដែលបានកើតឡើងទៅលើមនុស្សជាទីស្រឡាញ់របស់ខ្លួនហើយ មូលហេតុទាំងនេះអាចបង្កឲ្យប្រជាជនជាច្រើននៅមានការឈឺចាប់ ដោយសារតែការគិតទៅលើអ្វីដែលមនុស្សជាទីស្រឡាញ់របស់ខ្លួនបានរងទុក្ខ និងជាញឹកញាប់នោះ គឺវាអាចអាក្រក់ជាងការដឹងពុអំពីអ្វីដែលបានកើតឡើងទៅទៀត។

ការយល់ឃើញដ៏ទូលំទូលាយរបស់យើងនៅក្នុងខណៈពេលនេះគឺត្រូវតែទទួលស្គាល់ថាតើការស្វែងរកយុត្តិធម៌បានចំណាយអស់រយៈពេលប៉ុន្មាន និងបានចំណាយអស់ថវិកាចំនួនប៉ុន្មាន។ ប៉ុន្តែយើងមិនគួរបណ្តោយឲ្យកំហុសរបស់តុលា-ការ លុបបំបាត់សារសំខាន់របស់ដំណើរការតុលាការនោះទេ។ សាលាក្តីខ្មែរក្រហម បាននាំមកនូវចំណាប់អារម្មណ៍ និងការយល់ដឹងពីប្រជាពលរដ្ឋកម្ពុជានូវគោលគំនិតសំខាន់ៗ អំពីយុត្តិធម៌ និងសារសំខាន់នៃនីតិរដ្ឋ។ ជនរងគ្រោះដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ដែលបានចូលរួមក្នុងអង្គជំនុំជម្រះ មានអំណរគុណចំពោះគុណតម្លៃទាំងនេះ។ ទោះបីជាការស្វែងរកយុត្តិធម៌ ដែលជារឿយៗទទួលបានលទ្ធផលមិនល្អឥតខ្ចោះយ៉ាងណាក៏ដោយ ក៏អ្នករស់រានមានជីវិតទាំងនោះដឹងពុអំពីការរកខុសត្រូវចំពោះទុក្ខវេទនារបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅពេលដែលសង្គមទទួលស្គាល់ និងបន្តស្វែងរកយុត្តិធម៌ប្រឆាំងនឹងជនល្មើសដែលបានបង្កបទឧក្រិដ្ឋដ៏គួរឲ្យរន្ធត់ដែលប្រជាជនបានទទួលរងនាពេលនោះ។

សេចក្តីសន្និដ្ឋាននៃសំណុំរឿង០០២ នឹងបង្កឲ្យមានការឆ្លើយតប និងការឆ្លុះបញ្ចាំងជាច្រើនក្នុងចំណោមប្រជាជនកម្ពុជា។ ទោះបីជាយ៉ាងណា វានឹងបញ្ជាក់អំពីសមូហភាពនៃមនុស្សជាតិរបស់ជនរងគ្រោះ ដែលនៅរស់រានមានជីវិត និងបញ្ជាក់អំពីការឈឺចាប់ និងការបាត់បង់ដ៏សែនខ្លោចផ្សារបស់ប្រជាជន។ សម្រាប់ក្មេងជំនាន់ក្រោយនៅក្នុងប្រទេសកម្ពុជា ដែលមិនបានជួបប្រទះនឹងភាពភ័យតក់ស្លុតនៃសង្គ្រាមការអត់ឃ្លាន អំពើប្រល័យពូជសាសន៍ ឬអំពើឃោរឃៅទ្រង់ទ្រាយធំ ដំណើរការទាំងនេះនឹងក្លាយទៅជាការរំឭកដ៏គួរឲ្យរន្ធត់មួយអំពីសក្តានុពលរបស់មនុស្សចំពោះភាពអមនុស្សធម៌ ដែលបង្កឲ្យមានស្នាមរបួសជាច្រើន ទាំងកាយសម្បទា និងសតិអារម្មណ៍ និងកំពុងតែបន្តលងបន្លាចនៅក្នុងសង្គមកម្ពុជា។ សំណុំរឿង ០០២ ដែលបញ្ជាក់ពីអំណាចនៃយុត្តិធម៌ កំពុងតែផ្តល់ឲ្យនូវសេចក្តីបញ្ចប់នៃជំពូកដ៏អាក្រក់ នៅក្នុងប្រវត្តិសាស្រ្តរបស់ប្រទេសកម្ពុជា ទោះបីជាស្នាមរបួសទាំងនោះ បានមុតចូលជ្រៅយ៉ាងណាក៏ដោយ។ សំណុំរឿង០០២ ក៏មានសារសំខាន់ផងដែរ សម្រាប់ផ្តល់ជាមធ្យោបាយមួយក្នុងការបង្កើនការយល់ដឹង និងការប្រុងប្រយ័ត្ននៅក្នុងគំនិត និងដួងចិត្តរបស់មនុស្សជំនាន់ក្រោយ តាមរយៈការបញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាលា និងតាមសាកលវិទ្យាល័យនានា។ វាបង្ហាញអំពីសេចក្តីរន្ធត់នៃភាពអមនុស្សធម៌ ដែលអាចកើតមានឡើង នៅពេលដែលប្រជាជនមិនបានអនុវត្តដោយការព្យាយាមការពារផលប្រយោជន៍ និងអាទិភាពរបស់ខ្លួន និងជំនួសទៅវិញដោយចុះចូលខ្លួនឯងជាមួយនឹងអ្នកផ្តាច់ការ និងគំនិតមនោគមវិជ្ជាជ្រុលនិយមរបស់គេ។ មេរៀនជាច្រើន អាចទទួលបានពីកង្វះខាត កំហុស និងភាពខ្វះចន្លោះនៃដំណើរការរបស់តុលាការ និងលទ្ធផលរបស់វា។ កិច្ចការងារ និងមេរៀនពីតុលាការខ្មែរក្រហម និងតុលាការព្រហ្មទណ្ឌអន្តរជាតិដទៃទៀត ផ្តល់ឲ្យនូវការគិតអំពីសារសំខាន់នៃការប្រុងប្រយ័ត្ន និងការចូលរួមក្នុងដំណើរការនយោបាយ ដោយមិនត្រឹមតែសម្រាប់ប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ប្រព័ន្ធច្បាប់អន្តរជាតិ និងការទន្ទឹងរង់ចាំមើល ព្រមទាំងការឆ្លើយតបចំពោះអំពើឃោរឃៅទ្រង់ទ្រាយធំនេះ។

យើងត្រូវផ្តល់តម្លៃទៅលើសារសំខាន់នៃពេលវេលានេះ ដោយទាញយកឱកាសមួយដើម្បីបញ្ជាក់អំពីការប្តេជ្ញាចិត្ត

ជាបុគ្គល និងជាសមូហភាពរបស់យើងចំពោះការចូលរួមឲ្យបានសកម្មនៅក្នុងសង្គម និងការការពារទុកជាមុន នៅពេលដែលការប៉ះទង្គិចនៃព្រឹត្តិការណ៍នាពេលអនាគតចាប់ផ្តើមបង្ហាញខ្លួន។ តុលាការគឺជាអ្នកអនុវត្តយុត្តិធម៌ ការពារនីតិរដ្ឋ និងឈរជាអ្នកថែរក្សានៅមុខច្រក យុត្តិធម៌ ប៉ុន្តែកាតព្វកិច្ចនៃការស្តាបនា និងការពង្រឹងសង្គមក្រោយជម្លោះឡើងវិញ គឺជាការទទួលខុសត្រូវរបស់ប្រជាជន។ ជនរងគ្រោះដែលរស់រានមានជីវិតពីអំពើឃោរឃៅទ្រង់ទ្រាយធំនេះអាចរង់ចាំដោយអត់ធ្មត់ចំពោះភាពធូរស្បើយ ការទទួលស្គាល់ និងជំនួយ ប៉ុន្តែស្របពេលជាមួយគ្នានេះដែរ យើងត្រូវធានាឲ្យបានថា ដំណោះស្រាយត្រូវតែកើតមានជាមុនសិនជាជាងរួសបន្ទាយទុកនៅពេលក្រោយ។ យុត្តិធម៌ដែលទទួលបានក្រោយជម្លោះ មិនមែនសុទ្ធសឹងតែធ្វើឡើងនៅក្នុងប្រព័ន្ធតូចចង្អៀតនៃដំណើរការនៃការកាត់ទោស និងការវិនិច្ឆ័យទោសឲ្យបានត្រឹមត្រូវទៅតាមច្បាប់របស់តុលាការនោះទេ។ ដើម្បីយល់ដឹងឲ្យកាន់តែទូលំទូលាយ យើងទទួលស្គាល់ថា ដំណើរការទាំងនោះ ត្រូវតែកែលម្អតាមរយៈការប្តេជ្ញាចិត្តយ៉ាងទូលំទូលាយចំពោះការអប់រំទប់ស្កាត់ ការទទួលស្គាល់ជនរងគ្រោះ និងគំនិតផ្តួចផ្តើមរំឭក និងការព្យាបាលសុខភាព ការផ្តល់ប្រឹក្សា និងសេវាកម្មសង្គមផ្សេងៗទៀតស្របពេលដែលមានការកាត់ក្តី និងការវិនិច្ឆ័យទោស។

**ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**



តា ម៉ុក នួន ជា និង មេដឹកនាំកម្មាភិបាលខ្មែរក្រហមដ៏ទៃទៀត នៅក្នុងជំនួបប្រជុំនៅផ្ទះរបស់ តាម៉ុក ស្ថិតនៅស្រុកអន្លង់វែង ក្នុងឆ្នាំ១៩៩៨។ តាម៉ុក បានស្លាប់នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៦ ដោយសារតែជំងឺបេះដូង ប្រហែលជាអាចបណ្តាលមកពីភាពតានតឹងពីការកាត់ទោសរបស់តុលាការខ្មែរក្រហម។ រក្សាសិទ្ធិ និងរូបថតដោយ ៖ ជេម៍ ជឺរាណ (Jame Jerrand)។ (កំណត់ចំណាំ៖ រូបថតទាំងនេះ និងរូបថតផ្សេងៗទៀតនឹងជាផ្នែកមួយនៃការតាំងពិពណ៌នាពេលខាងមុខរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ «អន្លង់វែង ៖ ទីក្រុងនៃការយោគយល់រវាងមិត្តនិងសត្រូវ» ក្នុងខែធ្នូ ២០១៨)។

# ព្រាំ ធី ហៅ ឆេង ជាយុទ្ធនារីចិញ្ចឹមសត្វនៅពេទ្យ ៣-១៧

***ដកស្រង់ចេញពីឯកសារចម្លើយសារភាពលេខ D00090***

***ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ១៩៧៨***

ខ្ញុំឈ្មោះ ព្រាំ ធី អាយុ១៩ឆ្នាំ នៅភូមិត្បែង ឃុំសានគរ ស្រុកកំពង់ស្វាយ តំបន់៤១ ភូមិភាគឧត្តរចាស់ ខេត្តកំពង់ធំ។ គ្រួសារខ្ញុំជាអ្នកធ្វើស្រែ។ កាលពីឆ្នាំ១៩៧០ តំបន់ដែលខ្ញុំរស់នៅត្រូវបានរំដោះហើយ។ ដល់ឆ្នាំ១៩៧២ ខ្ញុំចូលធ្វើបដិវត្តន៍តាមពូ ម៉ែន ដែលជាប្រធានភូមិ។ ខ្ញុំចូលមកនៅមន្ទីរឃុំសានគរ ខាងធ្វើស្រែ មានពូវ៉ង់ជាប្រធានក្រុម។ ខ្ញុំនៅបានប្រហែល៣ខែ ក៏ចេញមកដឹកប្រឡាយនៅស្រុកសណ្តាន់វិញ។

មកដល់ពាក់កណ្តាលឆ្នាំ១៩៧២ ខ្ញុំត្រូវចូលរួមជាមួយក្រុមកុមារដឹកប្រឡាយនៅមន្ទីរតំបន់៤១ ក្រោមការដឹកនាំរបស់ពូ ផន។ នៅបានប្រហែល១ខែ ពូផន បានហៅខ្ញុំឲ្យទៅសរសេរប្រវត្តិរូបសង្ខេប។ គាត់សួររឿងរ៉ាវរបស់ខ្ញុំ ហើយបញ្ចុះបញ្ចូលខ្ញុំថា៖«មិត្តត្រូវតែនៅខាងខ្ញុំ ទើបមិត្តបាននៅមន្ទីរនេះ បើមិត្តមិនចូលខាងខ្ញុំទេ មិត្តច្បាស់ជាឃ្លាតពីទីនេះហើយ»។ គាត់ប្រាប់ខ្ញុំថា ៖ «មិត្តឯងកុំធ្វើបដិវត្តន៍អី ព្រោះធ្វើបដិវត្តន៍យ៉ាប់ខ្លួនណាស់ ក្រីក្រអត់បាយស៊ី ហើយអាយុក៏មិនវែងដែរ»។ ខ្ញុំក៏ព្រមធ្វើខ្មែរសជាមួយគាត់ដើម្បីឲ្យតែបានរស់។ ពូផន ប្រាប់ថា៖ បើខ្ញុំព្រម ខ្ញុំត្រូវធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ កាប់បំផ្លាញភ្លឺស្រែ។



នារីពេទ្យខ្មែរក្រហមពិនិត្យមើលសេរ៉ូម

ខ្ញុំ និងគាត់បានទៅកាប់ភ្លឺស្រែចំនួន២កន្លែងនៅស្រែវាល។ នៅឆ្នាំដដែល គាត់បានឲ្យខ្ញុំផ្លាស់មកនៅមន្ទីរពេទ្យយោធាភូមិភាគឧត្តរចាស់។ មុនពេលចេញដំណើរ គាត់ផ្តាំខ្ញុំថា ៖ «ពេលទៅដល់មន្ទីរពេទ្យ ខ្ញុំត្រូវទាក់ទងជាមួយឈ្មោះ សេត ជាអនុប្រធានមន្ទីរពេទ្យភូមិភាគឧត្តរ ព្រោះ សេត ក៏ជាខ្សែរយៈរបស់ខ្ញុំដែរ»។ ប៉ុន្តែក្រោយមកបាន៧ថ្ងៃ ទើប ពូផន ឌុបកង់ជូនខ្ញុំមកនៅមន្ទីរពេទ្យយោធាភូមិភាគឧត្តរបារាយណ៍។ ខ្ញុំមិនទាន់បានស្គាល់ឈ្មោះ សេត ទេ។ រហូតដល់មួយសប្តាហ៍ក្រោយមកទើប ពូផន មកណែនាំខ្ញុំឲ្យស្គាល់គាត់។ សេត ឲ្យខ្ញុំទៅព្យាបាលជាមួយឈ្មោះ ហ៊ាន ដើម្បីបូមថ្នាំចាក់សម្រាប់អ្នកជំងឺ។ បន្ទាប់មក សេត បានណែនាំឲ្យខ្ញុំស្គាល់ខ្សែរយៈរបស់គាត់៧នាក់ទៀត ដែលធ្វើការនៅក្នុងមន្ទីរពេទ្យនេះ និងនៅចម្ការកៅស៊ូបារាយណ៍។ ក្រោយមកខ្ញុំក៏ទៅនៅជាមួយ ហ៊ាន។ ហ៊ាន បានបូមថ្នាំ ៥សេសេ ចាក់ឲ្យអ្នកជំងឺប្រកាច់បែកពពុះមាត់ស្លាប់។

ដល់ឆ្នាំ១៩៧៣ សេត បានឲ្យខ្ញុំ និង វ៉ាន (ខ្សែរយៈខាងនារី) ស្ងោរសឺរ៉ាំង ដាក់ទឹកតិចជាងចំនួនកំណត់ធ្វើឲ្យបែកសឺរ៉ាំង និងខូចម្ជុលអស់។



នារីពេទ្យខ្មែរក្រហមបង្ហាញថ្នាំបុរាណដែលបានផលិតរួច

បន្ទាប់មក សេត បានចាត់តាំងឲ្យខ្ញុំ និងមិត្តនារីបីនាក់ទៀតទៅធ្វើការនៅចម្ការកៅស៊ូ។ យើងបានបំផ្លិចបំផ្លាញដើមកៅស៊ូអស់មួយចំនួន។ ដល់ចុងឆ្នាំ១៩៧៣ បង សេត បានឲ្យពួកខ្ញុំប្តូរមកត្រងជ័រកៅស៊ូវិញ។ គាត់ប្រាប់ឲ្យយើងដាក់ចានត្រងកៅស៊ូរាក់ៗ ងាយនឹងជ្រុះបែក និងកំពប់ជ័រៗក្រៅពីត្រងជ័រ គាត់បញ្ជាឲ្យយើងទៅបោសសម្អាតគល់កៅស៊ូ។ លើកនេះ ខ្ញុំបោសស្លឹកក្រៀមៗទៅដាក់នៅគល់ដើមកៅស៊ូ រួចហើយដុតឲ្យឆេះអស់ប៉ុន្មានដើមធំៗ។

នៅដើមឆ្នាំ១៩៧៤ សេត បានឲ្យខ្ញុំទៅនៅជាមួយឈ្មោះ ដឿន ជាប្រធានចម្ការកៅស៊ូភូមិភាគឧត្តរ។ គាត់បានណែនាំខ្ញុំឲ្យទាក់ទងជាមួយឈ្មោះ ដឿន។ ដឿន បានឲ្យខ្ញុំទៅទាក់ទងជាមួយខ្សែរយៈគាត់ ៤០៥ នាក់ទៀត នៅចម្ការកៅស៊ូចម្ការអណ្តូង។ គាត់បានបញ្ជាឲ្យខ្ញុំ និងមិត្ត៣នាក់ទៀត កាប់ដើមកៅស៊ូដែលកំពុងពេញជំទង់ និងដើមឈើហូបផ្លែមួយចំនួនទៀត។ ដល់ចុងឆ្នាំ ខ្ញុំត្រូវប្តូរកន្លែងម្តងទៀតទៅនៅមន្ទីរសិល្បៈ ប-២០ ដែលមាន កុំ ជាប្រធាន។ គាត់ក៏ជាខ្សែរយៈរបស់ ដឿន ដែរ។ កុំ ប្រើខ្ញុំ និងនារី យាង ឲ្យទៅដាំស្ពៃ ប៉ុន្តែគាត់បញ្ជាក់ថាត្រូវដាំគល់ឡើងលើ។ យើងធ្វើតាមគាត់ ហើយស្ពៃងាប់អស់មួយរង។

ក្រោយថ្ងៃរំដោះទូទាំងប្រទេស អង្គការបានដកខ្ញុំ និងមិត្តប្រាំនាក់ទៀតទៅដាក់នៅមន្ទីរសង្គមកិច្ច ក-៧។ កុំ បានផ្តាំថា ពេលទៅដល់ទីនោះ កុំភ្លេចបំផ្លាញថ្នាំពេទ្យរបស់អង្គការ ហើយត្រូវទាក់ទងមកគាត់ និង ដឿន ផង ទោះជានៅក្រោមការដឹកនាំរបស់ ធឿន ក៏ដោយ។

នៅមន្ទីរសង្គមកិច្ច ធឿន បានបញ្ជាឲ្យខ្ញុំ និងមិត្តបីនាក់ទៀត យកថ្នាំដេដេតេ ទៅបង់ក្នុងបាយសម្ល នៅកន្លែងដាំស្លរបស់មន្ទីរនៅម៉ោង៨យប់ ដើម្បីកុំឲ្យគេឃើញ។ នៅយប់នោះ ខ្ញុំនិងនារី យាង បានយកថ្នាំពី ធឿន។ ពេលដើរជិតដល់ផ្ទះបាយ ស្រាប់តែខ្ញុំជួបនឹង ស៊ូ ដែលជាប្រធានមន្ទីរ។ យើងក៏សម្រេចចិត្តមិនយកថ្នាំដាក់ចូលបាយសម្ល ព្រោះខ្លាចបែកការណ៍។

ដល់ខែ៦ ឆ្នាំ១៩៧៥ ធឿន បានហៅក្រុមយើងប្រាំនាក់មកប្រជុំ។ គាត់រៀបផែនការឲ្យ យើងដើរគោះទ្វារផ្ទះគេពេលយប់ ដើម្បីកុំឲ្យគេដេកបាន។ គាត់ថា ធ្វើបែបនេះ អ្នកទាំងនោះនឹងមានអារម្មណ៍មិនល្អ បង្កភាពស្មុគស្មាញក្នុងមន្ទីរ។ សកម្មភាពនេះបង្កឲ្យមិត្តនារីដែលដេកនៅក្នុងមន្ទីរភ័យផ្អើលអស់ពីរយប់។ ក្រោយពីបង្ករឿងមិនឲ្យគេដេកពួន ខ្ញុំនិងមិត្តបួននាក់ដដែល បានយកពូថៅទៅវាយម៉ាស៊ីនបូមទឹកមួយគ្រឿងខូចប្រើលែងកើត។

មួយខែក្រោយមក ធឿន បានហៅយើងទាំងបួនទៅប្រជុំ។ គាត់និយាយថា មិត្តជិតបែកពីខ្ញុំហើយ ដូច្នេះពេលទៅដល់មន្ទីរពេទ្យ ត្រូវទៅទាក់ទងជាមួយឈ្មោះ សី ដែលជាគណៈពេទ្យព-១៧ ហើយបើមានបញ្ហាក្តាប់សភាពការណ៍មិនបានយ៉ាងណា ត្រូវប្រាប់ឲ្យខ្ញុំដឹងផងៗ។ ២ថ្ងៃក្រោយមក យើងក៏ធ្វើដំណើរទៅមន្ទីរពេទ្យព-១៧។

នៅទីនេះ អង្គការបានចាត់ឲ្យនារី យាង ទៅមន្ទីរពេទ្យ ព-១ ខាងព្យាបាលកុមារ ឈ្មោះ ដន និង ធុន ទៅមន្ទីរ ព-២ ចំណែកខ្ញុំ និង សៀន នៅមន្ទីរ ព-១៧ នេះតែម្តង។ ពីរបីថ្ងៃក្រោយមក សី បានហៅខ្ញុំទៅសួរប្រវត្តិរូប ហើយសួរបញ្ជាក់ថា ខ្ញុំពិតជាខ្សែរយៈរបស់ ធឿន មែនឬទេ? ពេលប្រាកដក្នុងចិត្តហើយ គាត់ក៏នាំខ្ញុំទៅជួបមនុស្ស៦នាក់ទៀតដែលជាខ្សែរយៈរបស់គាត់។

មកដល់ខែមីនា ឆ្នាំ១៩៧៦ ខ្ញុំត្រូវផ្លាស់ចេញពីកន្លែងកុមារ មកនៅខាងដាំស្លវិញ។ ក្នុងខែដដែល សី បានហៅខ្ញុំ និងខ្សែរយៈគាត់៦នាក់ទៀតទៅប្រជុំនៅសាលាមួយមុខអគារពេទ្យ។ គាត់រៀបរាប់ផែនការក្បត់អង្គការជាច្រើនដូចតទៅ ៖

១) ខាងសំណង់ ត្រូវធ្វើឲ្យខូចម៉ាស៊ីនបូមទឹកធុនធំ

២) ខាងផ្នែកផ្ទះបាយ ត្រូវដាក់ថ្នាំបំពុលអ្នកជំងឺ និងពេទ្យ

៣) ផ្នែកវះកាត់ ត្រូវចាក់ថ្នាំសន្លប់ឲ្យហួសកំណត់ ធ្វើឲ្យអ្នកជំងឺស្លាប់

៤) ផ្នែកជំងឺភ្នែក ត្រូវលាងភ្នែកអ្នកជំងឺឲ្យខូចខ្វាក់

៥) ផ្នែកធ្មេញ ត្រូវចាក់ថ្នាំឲ្យអ្នកជំងឺធ្វើទុក ទៅជាល្ងីល្ងើ

ពេលនោះ ឈ្មោះ ម៉ៅ ដែលទទួលបន្ទុកផ្នែកផ្ទះបាយជាមួយខ្ញុំ បានផ្តល់យោបល់ឲ្យប្រើថ្នាំអង់ទ្រីនជំនួសម្សៅដេដេតេវិញ។ សី ក៏យល់ព្រមដែរ។ ពីរថ្ងៃក្រោយមក ម៉ៅ បានហៅខ្ញុំ និងមិត្តដែលធ្វើការក្នុងផ្ទះបាយពីរនាក់ទៀត មកនិយាយពីផែនការយកអង់ទ្រីនទៅដាក់ក្នុងទឹកសម្រាប់ដាំស្ល។ ស្អែកឡើងពេលល្ងាច យើងទាំងបីបានយកថ្នាំទៅដាក់ក្នុងទឹកនៅពេលអ្នកដាំបាយមិននៅកន្លែង។ ដល់ថ្ងៃឡើង អ្នកជំងឺនៅជាន់ទី៤ និងពេទ្យដែលហូបបាយទាំងប៉ុន្មាន ពុលទាំងអស់ ប៉ុន្តែត្រូវបានគេព្យាបាលទាន់។ ក្រោយមក ខ្ញុំបានឮថាឈ្មោះ ភា នៅខាងផ្នែកជំងឺទូទៅ បានចាក់ថ្នាំសម្លាប់អ្នកជំងឺអស់៥នាក់។

ខែឧសភា ឆ្នាំ១៩៧៦ ម៉ៅ កោះប្រជុំម្តងទៀត និយាយពីរឿងដាក់ថ្នាំក្នុងទឹកដដែល។ ពីរថ្ងៃក្រោយមក ម៉ៅ យកថ្នាំមកឲ្យខ្ញុំយកទៅដាក់ក្នុងខ្ទះទឹក នៅពេលយប់គ្មានមនុស្សនៅ។ ព្រឹកឡើង ខ្ញុំបានប្រាប់ទៅខ្មែររយៈដែលនៅដាំបាយមិនឲ្យដងទឹកចេញច្រើនពេកទេ ព្រោះខ្លាចអស់ជាតិថ្នាំ។ ពេលហូបបាយខ្ញុំក៏ប្រាប់ឲ្យអ្នកដួសបាយដួសឆ្នាំងដែលមានថ្នាំមុនគេ។ អ្នកដែលមកហូបបាយទាំងប៉ុន្មានសុទ្ធតែពុលក្បែរនឹងស្លាប់។

ក្រោយមកទៀត ម៉ៅ ហៅខ្មែររយៈចាស់ៗមកប្រជុំ ដើម្បីណែនាំឲ្យស្គាល់ជាមួយខ្មែររយៈថ្មី ៥នាក់ទៀតនៅមន្ទីរពេទ្យព-១៧នេះ។ លើកនេះ ម៉ៅ លែងយកអង់ទ្រីនទៅបង់ក្នុងទឹកទៀតហើយ។ ម៉ៅ បានបញ្ជាក់ថា មិត្តត្រូវយកថ្នាំចាក់ទៅលាយជាមួយអង់ទ្រីនសិន សឹមចាក់ឲ្យអ្នកជំងឺ។ ចំពោះថ្នាំគ្រាប់ មិត្តត្រូវយកទៅប្រឡាក់ឲ្យជាប់នឹងទឹកអង់ទ្រីន មុននឹងយកទៅចែកឲ្យអ្នកជំងឺ។ អ្នកនៅចិញ្ចឹមសត្វ ត្រូវដាក់ថ្នាំបំពុលជ្រូក ឬទាញកទាឲ្យងាប់។ ចំណែកអ្នកដាំស្លចាំបំផ្លាញចាន ឆ្នាំង និងសម្ភារផ្សេងៗ។ ក្រោយពីការប្រជុំ សកម្មភាពបំផ្លិចបំផ្លាញសម្ភារ និងសម្លាប់សត្វ ក៏កើតឡើងជាបន្តបន្ទាប់។

ដើមឆ្នាំ១៩៧៧ ខ្ញុំត្រូវបានដកពីកន្លែងដាំស្ល ទៅដាក់នៅកន្លែងចិញ្ចឹមសត្វវិញ។ ឯអ្វីដែលខ្ញុំត្រូវធ្វើគឺគ្មានអ្វីក្រៅពីការបំពុលជ្រូកទេ។ ខ្ញុំធ្វើឲ្យជ្រូកងាប់អស់១០ក្បាល និងមេជ្រូកមួយទៀតដែលកំពុងតែមានកូនក្នុងពោះ។

នៅខែមេសា ឆ្នាំ១៩៧៧ ខ្ញុំធ្លាក់ខ្លួនឈឺ ហើយត្រូវមកដេកពេទ្យព-១៧ ជាន់ទី៣។ សី បានប្រាប់ថា ពេលនៅមន្ទីរពេទ្យ ខ្ញុំត្រូវខូចសីលធម៌ជាមួយយុទ្ធជន ហើយបើមានឱកាសត្រូវចាក់ថ្នាំសម្លាប់អ្នកជំងឺ ឬធ្វើឲ្យអាប់សែ។

ពេលយប់ ខ្ញុំជួយយាមពេទ្យ។ ខ្ញុំបានលួចចូលមុងយុទ្ធជនពីរនាក់ដែលខ្ញុំមិនដែលស្គាល់ពីមុនសោះ។ យើងក៏បានខូចសីលធម៌ជាមួយគ្នាក្នុងយប់នោះ។ មកដល់ខែឧសភា ខ្ញុំបានទាក់ទងតាមសំបុត្រជាមួយយុទ្ធជន៣នាក់ទៀត។ ខ្ញុំក៏មានទំនាក់ទំនងជាមួយអ្នកទាំងបីនេះ ដូចយុទ្ធជន២នាក់ខាងលើដែរ។

មួយខែក្រោយមក ខ្ញុំបានចាក់ថ្នាំសម្លាប់នារី២នាក់ ដែលជាអ្នកជំងឺនៅជាន់ទី៣។ ពេលចេញពីពេទ្យ ត្រឡប់ទៅកន្លែងចិញ្ចឹមសត្វវិញ ខ្ញុំបានទៅបំផ្លាញវង់ស្ពៃ និងវាយទាដែលខ្ញុំចិញ្ចឹមផ្ទាល់ដៃងាប់អស់៧ក្បាល។

មកដល់ដើមឆ្នាំ១៩៧៧ ថ្ងៃមួយពេលខ្ញុំកំពុងដាក់ថ្នាំបំពុលជ្រូកជាមួយមិត្តម្នាក់ឈ្មោះ រ៉ុន ស្រាប់តែកុមារម្នាក់ឈ្មោះ ខន មកសួរថា ខ្ញុំកំពុងដាក់អ្វី? ខ្ញុំកុហកថា វាជាថ្នាំធ្វើឲ្យជ្រូកធាត់។ ក្មេងនោះនៅតែឈរមើលមិនព្រមដើរចេញសោះ។ ជ្រូកស៊ីចំណីតែមួយភ្លែតក៏ដួលងាប់អស់ ក្មេងនោះក៏រត់រាយការណ៍ជូនអង្គការ។

៣ថ្ងៃក្រោយ អង្គការក៏ចាប់ខ្លួនខ្ញុំ។ ថ្ងៃនេះគឺ ថ្ងៃព្រហស្បតិ៍ ទី៩ ខែកុម្ភៈ ឆ្នាំ១៩៧៨ ហើយសំណេរខាងលើ ជាចម្លើយសារភាពរបស់ខ្ញុំ។ ព្រាំ ធី។

*ទ្រី សុជាតា*

**កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ ព្រាំ ធី ពិតឬយ៉ាងណានោះទេ។**

# កាលវិភាគបញ្ចាំងខ្សែភាពយន្តឯកសារ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា



បញ្ចាំងរៀងរាល់ថ្ងៃសុក្រ
វេលាម៉ោង១០:០០ ព្រឹក
ទីតាំងនៅវិចិត្រសាលសិល្បៈ
សហសម័យវិទ្យាស្ថានស្លឹករឹត
អគារ H នៃវិទ្យាស្ថានជាតិអប់រំ
(មហាវិថីព្រះសីហនុ
រាជធានីភ្នំពេញ)










វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលមានទីតាំងស្ថិតនៅក្នុងអគារ H នៃវិទ្យាស្ថានជាតិអប់រំ ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដែលដាក់បង្ហាញពីស្នាដៃសិល្បៈ និងវប្បធម៌តាមរយៈការតាំងពិព័រណ៍ ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញរបស់វាគ្មិននានា។ ជារួម វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើកកម្ពស់និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់កសាងឡើងក្នុងរដ្ឋកាលបារាំង សម្រាប់ការដាក់តាំងពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង ស៊ាង ចិន្តា ទូរសព្ទលេខ ០២៣ ២១១ ៨៧៥ អ៊ីម៉ែល truthchenda.s@dccam.org

# របកគំហើញថ្មីចំពោះកិច្ចការស្រាវជ្រាវពីទីតាំងសម្លាប់មនុស្សក្នុងរបបខ្មែរក្រហម

ជាមួយនឹងកិច្ចការស្វែងរកយុត្តិធម៌របស់តុលាការខ្មែរក្រហមកាន់តែថមថយពីមួយថ្ងៃទៅមួយថ្ងៃ ប្រជាជនកម្ពុជាដែលជាអតីតជនរងគ្រោះក្នុងរបបខ្មែរក្រហម នៅតែទាមទាររកយុត្តិធម៌បន្ថែមទៀតហើយក្មេងៗដែលមានចំនួនច្រើនជាង៧០ភាគរយនៃដង់ស៊ីតេប្រជាជនកម្ពុជាទាំងអស់ កំពុងស្វែងរកឯកសារបន្ថែម និងភ័ស្តុតាងបន្ថែមជាច្រើនទៀតទាក់ទងនឹងព្រឹត្តិការណ៍ក្នុងរបបខ្មែរក្រហមៗ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាស្ថាប័នស្រាវជ្រាវឯករាជ្យនៅកម្ពុជា បានបំពេញតម្រូវការរបស់តុលាការខ្មែរក្រហម ក្នុងការផ្តល់ទិន្នន័យជាច្រើនដែលខ្លួនមាន ក្នុងនោះរួមទាំងការបញ្ជូនឯកសារស្តីពី ព័ត៌មានដាក់ស្តែងចេញពីទីតាំងរាលពិឃាតរបស់ខ្មែរក្រហមក្នុងក្តីសង្ឃឹមថា តុលាការនេះនឹងបន្តកិច្ចការងារស្រាវជ្រាវតាមលក្ខណៈវិទ្យាសាស្ត្របន្ថែមទៀត ដើម្បីបង្កើនភ័ស្តុតាងក្នុងការនាំយកមេដឹកនាំកំពូលខ្មែរក្រហមឲ្យទទួលកំហុសពីសកម្មភាព និងតួនាទីរបស់ខ្លួនដែលបង្កឲ្យប្រជាជនប្រមាណច្រើនជាង២លាននាក់ ស្លាប់ក្រោមការដឹកនាំរបស់ខ្លួនៗ

ក្នុងអំឡុងពេលដំណើរការតុលាការនេះ ព័ត៌មានបន្ថែមស្តីពីរាលពិឃាតក្នុងរបបខ្មែរក្រហមនៅតែត្រូវបានបង្ហាញតាមរយៈការរកឃើញរបស់អ្នកភូមិ ហើយត្រូវបានបញ្ជូនមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមវិធីផ្សេងៗៗ ព័ត៌មានទាំងនេះ ត្រូវបានធ្វើបច្ចុប្បន្នភាពទៅលើទិន្នន័យដែល


លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា និងគ្រូៗ អានទស្សនាវដ្តីស្វែងរកការពិត

មានស្រាប់។

នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៨ របកគំហើញថ្មីមួយត្រូវបានបង្ហាញតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីសន្ធាន មួយពីការមើលឃើញឆ្អឹងសាកសពជនរងគ្រោះ ស្លាប់ក្នុងរបបខ្មែរក្រហម ដែលកំពុងស្ថិតនៅក្នុងរណ្តៅដែលមិនទាន់ទទួលរងការគាស់បំផ្លាញកាលពីពេលកន្លងមក។ សូមបញ្ជាក់ថា រណ្តៅសាកសពមួយចំនួនត្រូវបានគាស់កកាយ ក្នុងគោលបំណងស្វែងរកវត្ថុមានតម្លៃចេញពីសាកសពដែលខ្មែរក្រហមបានសម្លាប់ក្នុងចន្លោះឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៨។ ការគាស់កកាយនេះ ភាគច្រើនស្ថិតនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។ មជ្ឈមណ្ឌលឯកសារកម្ពុជា ធ្វើការសហការជាមួយក្រុមហ៊ុន ស្ប៉ារ៉ូហក ហ្វារអ៊ីស ដែលជាក្រុមហ៊ុនរបស់អាមេរិកមានទីតាំងនៅក្នុងទីក្រុងភ្នំពេញ ក្នុងកិច្ចការស្រាវជ្រាវជាលក្ខណៈវិទ្យាសាស្ត្រសុទ្ធសាធ ទៅលើរណ្តៅសាកសពដែលមិនទាន់ទទួលរងការគាស់បំផ្លាញ។ ម៉ៃ ហេនសហ៍ ដែលជានាយកប្រតិបត្តិរបស់ក្រុមហ៊ុន បានប្រាប់ពីសមត្ថភាពរបស់ម៉ាស៊ីន RD 1500 ថា ម៉ាស៊ីននេះមិនត្រឹមតែអាចវាស់វែងពីជម្រៅ កម្ពស់ បណ្តោយ និងទទឹងនៃរណ្តៅនីមួយៗប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចបង្ហាញពីឆ្អឹងរបស់ជនរងគ្រោះដែលត្រូវបានកប់ក្នុងរណ្តៅកាលពី៤០ឆ្នាំមុនទៀតផង។

វិទ្យាល័យ មេសាង ស្ថិតក្នុងភូមិជីផុច ឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង។ វិទ្យាល័យនេះ គឺជាទីតាំងដំបូងបង្អស់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើបនេះ។ រណ្តៅសាកសពធំៗចំនួនពីរដែលមានទីតាំងស្ថិតនៅប៉ែកខាងជើងក្នុងបរិវេណវិទ្យាល័យ ត្រូវស្ថិតនៅក្រោមការសិក្សាស្រាវជ្រាវ។ ព័ត៌មានបឋមដែលទទួលបានពីការត្រួតពិនិត្យរបស់ម៉ាស៊ីន RD1500 បានបង្ហាញថា ពិតជាមានឆ្អឹងសាកសពនៅក្នុងរណ្តៅជម្រៅចាប់ពី១ម៉ែត្រកន្លះទៅ៨ម៉ែត្រ។ ទិន្នន័យច្បាស់លាស់ និងអាចមើលឃើញជាក់ស្តែង បន្ទាប់ពីទិន្នន័យបឋមទាំងនេះត្រូវបានវិភាគតាមរយៈការប្រើប្រាស់កម្មវិធីGIS និងGoogle Earth។

កិច្ចការនេះ និងបញ្ចប់ក្នុងរយៈពេល២ថ្ងៃ នៅក្នុងបរិវេណវិទ្យាល័យមេសាង ហើយនឹងបន្តទៅកាន់កន្លែងមួយចំនួនផ្សេងទៀត។ **ផេង ពង្សរ៉ាស៊ី**



ក្រុមស្រាវជ្រាវមកពីក្រុមហ៊ុន ស្ប៉ារ៉ូហក ហ្វារអ៊ីស និងនាយកវិទ្យាល័យមេសាង



ទីតាំងរណ្តៅសាកសពនៅក្នុងបរិវេណវិទ្យាល័យមេសាង ដែលត្រូវស្រាវជ្រាវ

# ចំណាប់អារម្មណ៍របស់សិស្សសាលាអន្តរជាតិភ្នំពេញ ចំពោះខ្សែភាពយន្តឯកសារ «កុមារកម្ពុជា»

នៅរសៀលថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ សិស្សានុសិស្សថ្នាក់អនុវិទ្យាល័យមកពីសាលាអន្តរជាតិភ្នំពេញ ចំនួន៥៩នាក់ បានចាប់អារម្មណ៍មកធ្វើទស្សនកិច្ចសិក្សា នៅវិចិត្រសាលសិល្បៈសហសម័យនៃវិទ្យាស្ថានស្លឹករឹត ដែលស្ថិតក្នុងបរិវេណវិទ្យាស្ថានជាតិអប់រំ នៃអគារ H ដើម្បីធ្វើការសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ចន្លោះពីឆ្នាំ១៩៧៥-៧៩។

ក្នុងអំឡុងទស្សនកិច្ចសិក្សានេះ សិស្សានុសិស្សក៏បានទស្សនាខ្សែភាពយន្តឯកសារ «កុមារកម្ពុជា» ដែរ។ ខ្សែភាពយន្តនេះ គឺជាខ្សែភាពយន្តប្រវត្តិសាស្ត្រដែលបានបង្ហាញពីស្ថានភាពរបស់កុមារកម្ពុជាដែលបានរសាត់អណ្តែត គ្មាន


សិស្សសាលាអន្តរជាតិភ្នំពេញទស្សនាខ្សែភាពយន្តឯកសារកុមារកម្ពុជា

គោលដៅច្បាស់លាស់ ដោយសារឪពុកម្តាយរបស់កុមារទាំងនេះ បានស្លាប់បាត់បង់ជីវិតក្នុងអំឡុងរបបខ្មែរក្រហម។ នៅក្នុងខ្សែភាពយន្តឯកសារនេះ បានបង្ហាញពីសកម្មភាពរបស់កុមារកម្ពុជាមួយចំនួនដែលកំពុងស្វែងរកម្ហូបអាហារ


កុមារកំព្រាដែលឪពុកម្តាយត្រូវបានសម្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩)

ហើយកុមារខ្លះទៀតបានបេះស្លឹកឈើហូបនៅតាមដងផ្លូវនិងមានកុមារមួយចំនួនទៀត កំពុងអង្គុយហូបបាយដែលគ្មានម្ហូបអាហារ ព្រមទាំងមានសត្វរុយរោមចានបាយទៀតផង។ ភាពយន្តឯកសារនេះបានឆ្លុះបញ្ចាំងអំពីស្ថានភាពអត់ឃ្លាន ភាពទុរគត និងការដែលមិនបានទទួលការអប់រំរបស់កុមារកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំភ្លាមៗ ដោយអ្នក

ផលិតភាពយន្តឯកសារបានធ្វើការប្រៀបធៀបកុមារកម្ពុជាទាំងនោះ ជាមួយនឹងស្ថានភាពកុមារមួយចំនួននៅបណ្តាប្រទេសអឺរ៉ុបខាងកើត។

សាលាអន្តរជាតិភ្នំពេញ គឺជាសាលាដែលផ្តល់ការអប់រំជាភាសាអង់គ្លេសលើគ្រប់មុខវិជ្ជាដល់សិស្សានុសិស្ស ក្នុងចំណោមសាលាអន្តរជាតិដទៃទៀតក្នុងប្រទេសកម្ពុជា។ សាលានេះក៏មានកម្មវិធីសម្រាប់សិស្សចុះទស្សនកិច្ចដែរ។ តាមរយៈទស្សនកិច្ចសិក្សានេះ សិស្សអាចបង្កើននូវសមត្ថភាពលើមុខវិជ្ជាដែលខ្លួនកំពុងរៀន ភាសាកំណើតរបស់ខ្លួន អាកប្បកិរិយា ឥរិយាបថ វប្បធម៌ រួមទាំងប្រវត្តិសាស្ត្ររបស់ខ្លួនថែមទៀត។

បន្ទាប់ពីសិស្សានុសិស្សបានទស្សនាខ្សែភាពយន្តឯកសារ «កុមារកម្ពុជា» រួចមក សិស្សានុសិស្សមួយចំនួនបានចាប់អារម្មណ៍ និងចោទជាសំណួរសួរទៅកាន់អ្នកស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រខ្មែរក្រហមមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដូចខាងក្រោម ៖

១) តើកុមារកំព្រានៅក្នុងខ្សែភាពយន្តឯកសារនេះ កំពុងហូបស៊ីកអ្វី?

២) តើនរណាជាអ្នកផលិតខ្សែភាពយន្តឯកសារនេះឡើង?

៣) តើហេតុអ្វីបានជាក្មេងៗទាំងនេះកាន់កាំភ្លើង?

៤) តើអ្នកណាជាអ្នកផ្តួលរំលំរបបខ្មែរក្រហម?

៥) បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ តើអ្នកដែលនៅរស់រានមានជីវិតភាគច្រើនជានរណា?

៦) តើកុមារកំព្រាដែលមាននៅក្នុងខ្សែភាពយន្តឯកសារនេះ សព្វថ្ងៃពួកគាត់មានស្ថានភាពយ៉ាងដូចម្តេច?


សិស្សសាលាអន្តរជាតិភ្នំពេញទស្សនាខ្សែភាពយន្តឯកសារកុមារកម្ពុជា នៅវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស៊ីករីត

៧) តើហេតុអ្វីបានជាខ្មែរក្រហមឡើងកាន់កាប់អំណាច?

៨) តើការរៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យខ្មែរក្រហមយ៉ាងដូចម្តេច?

សំណួរទាំងនេះ បានបង្កើតឲ្យមានការពិភាក្សាគ្នាក្នុងចំណោមសិស្សានុសិស្សដែលបានចូលរួម និងធ្វើឲ្យសិស្សទាំងនេះមានការយល់ដឹងបន្ថែមពីប្រវត្តិសាស្ត្រខ្មែរក្រហម។

ហូ ថុនា

# ព្រឹត្តិការណ៍នៃការសម្លាប់រង្គាលនៅកោះជេជូ នៃប្រទេសកូរ៉េខាងត្បូង

ការអភិវឌ្ឍន៍លើទឹកដីដែលធ្លាប់តែមានរឿងរ៉ាវអតីតកាលដ៏ខ្មៅងងឹតឲ្យក្លាយជាទីកន្លែងដ៏រីកចម្រើន និងមានភាពស្រស់ស្អាត មិនបានធ្វើឲ្យយើងបំភ្លេចនូវប្រវត្តិសាស្ត្ររបស់ទីកន្លែងនោះទេ។ ផ្ទុយទៅវិញ វាបានរំឭក និងធ្វើឲ្យយើងកាន់តែចង់ស្វែងយល់អំពីអតីតកាលទាំងនោះក្នុងរូបភាពដ៏ស្រស់ស្អាតនាពេលបច្ចុប្បន្ន និងជាវិធីសាស្ត្រមួយអាចធ្វើឲ្យមនុស្សជាតិចងចាំពីអតីតកាលរបស់ខ្លួនតាមវិធីសាស្ត្របែបទំនើបមួយ។

កោះដេជូ គឺជាកោះដ៏ស្រស់ស្អាតមួយ ស្ថិតក្នុងប្រទេសកូរ៉េខាងត្បូង ដែលមានសំណង់អគារខ្ពស់ៗ ហេដ្ឋារចនាសម្ព័ន្ធល្អប្រណិត បរិយាកាសល្អបរិសុទ្ធ និងការរស់នៅរបស់ប្រជាជនមានភាពហ៊ឺហា និងស៊ីវិល័យ ដែលយើងស្ទើរតែមិនចង់ជឿថា កោះដ៏ស្រស់ស្អាតនេះ ធ្លាប់ជាកន្លែងដែលអ្នកគាំទ្រចលនាកុម្មុយនីស្តនៅក្នុងសម័យសង្គ្រាមត្រជាក់ ហើយដែលបានធ្វើបាតុកម្មហិង្សាប្រឆាំងនឹងរដ្ឋាភិបាលរបស់កូរ៉េខាងត្បូងកាលពី៧០ឆ្នាំមុន និងឈានទៅដល់ការបះបោរទ្រង់ទ្រាយធំ រហូតធ្វើឲ្យប្រជាជនស្លាប់ប្រមាណ ៣០០.០០០ នាក់។

នៅចន្លោះថ្ងៃទី៤ ដល់៦ ខែតុលា ឆ្នាំ២០១៨ វិទ្យាស្ថានស្រាវជ្រាវដេជូ៤.៣ ដែលស្ថិតនៅលើកោះដេជូ ក្នុងប្រទេសកូរ៉េខាងត្បូង បានរៀបចំសន្និសីទអន្តរជាតិសម្រាប់ខួបលើកទី៧០ ដើម្បីរំឭកដល់ព្រឹត្តការណ៍នៃការសម្លាប់រង្គាល ដែលបានកើតឡើងនៅកំឡុងថ្ងៃទី៣ ខែមេសា ឆ្នាំ១៩៤៨ ដល់ខែឧសភា ឆ្នាំ១៩៤៩ គឺជាថ្ងៃដែលរដ្ឋាភិបាលកូរ៉េខាងត្បូងបានធ្វើយុទ្ធនាការប្រឆាំងនឹងក្រុមកុម្មុយនីស្ត ដើម្បីបង្ក្រាបការបះបោររបស់ប្រជាជនដែលរស់នៅលើកោះដេជូ និង



អ្នកចូលរួមសន្និសីទថ្នាក់អន្តរជាតិនៅកោះដេជូ ប្រទេសកូរ៉េខាងត្បូងថតរូបជុំគ្នា នៅកន្លែងប្រជុំរួម

ឈានទៅដល់ការសម្លាប់ទាំងក្មេង និងមនុស្សចាស់យ៉ាងសាហាវព្រៃផ្សៃ។ មូលហេតុចម្បងនៃការបះបោរនេះ គឺពាក់ព័ន្ធនឹងការបោះឆ្នោតដែលគ្រោងធ្វើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៤៨ ដែលរៀបចំឡើងដោយគណៈកម្មការបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិ នៅប្រទេសកូរ៉េ ដើម្បីបង្កើតរដ្ឋាភិបាលថ្មីមួយសម្រាប់ប្រទេសកូរ៉េទាំងពីរ។ ការបោះឆ្នោត ត្រូវបានគ្រោងសម្រាប់ភាគខាងត្បូងនៃប្រទេសដែលពាក់កណ្តាលនៃឧបទ្វីបកូរ៉េ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មការបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅប្រទេសកូរ៉េ។ ការភ័យខ្លាចថា ការបោះឆ្នោតនឹងពង្រឹងកងពលធំបន្ថែមទៀត ក្រុមអ្នកបះបោរបានប្រតិកម្មដោយហិង្សា ដោយធ្វើការវាយប្រហារទៅលើក្រុមប៉ូលីសក្នុងស្រុក និងក្រុមយុវជនស្តាំនិយមដែលឈរជើងនៅលើកោះជេជូ។

សន្និសីទថ្នាក់អន្តរជាតិសម្រាប់ខួបលើកទី៧០នេះ ត្រូវបានប្រារព្ធធ្វើឡើង នៅក្នុងបរិវេណសណ្ឋាគារនៃក្រុមហ៊ុនអាកាសចរណ៍កូរ៉េ ស្ថិតលើកោះជេជូនៃឧបទ្វីបកូរ៉េខាងត្បូង ក្រោមប្រធានបទ«ការពិត និង យុត្តិធម៌៖ ដំណើរឆ្ពោះទៅរកយុត្តិធម៌ប្រកបដោយនិរន្តរភាព»។ ការរៀបចំសន្និសីទនេះក្នុងគោលបំណងផ្តល់នូវវេទិកាមួយសម្រាប់ការណែនាំអំពីរបៀបដោះស្រាយបញ្ហាដោយការចែករំលែកគំនិត និងការពិភាក្សាទៅលើករណីស្រដៀងគ្នា ដែលបានកើតឡើងក្នុងប្រទេសដ៏ទៃទៀត។ កម្មវិធីនេះ ក៏នឹងធ្វើការពិភាក្សាទៅលើការទទួលខុសត្រូវ និងតួនាទីរបស់រដ្ឋាភិបាលនៃប្រទេសកូរ៉េខាងត្បូង និងសហរដ្ឋអាមេរិក ទៅលើការស្លាប់របស់ប្រជាជនកូរ៉េ ក្នុងខណៈពេលដែលមានការបះបោររបស់ប្រជាជនកូរ៉េនៅលើកោះជេជូ ចន្លោះពីឆ្នាំ១៩៤៨ និង១៩៤៩។

សន្និសីទថ្នាក់អន្តរជាតិ សម្រាប់ខួបលើកទី៧០ នៃការរំឭកដល់ព្រឹត្តការណ៍ ដែលបានកើតឡើងនៅថ្ងៃទី៣ ខែមេសា ត្រូវបានបែងចែកជាសម័យប្រជុំធំៗ៣គឺ ៖

១) សម័យប្រជុំទី១ នៅថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៨ ការប្រជុំបានពិភាក្សាលើប្រធានបទ«សង្គ្រាមត្រជាក់ អំពើប្រល័យពូជសាសន៍ និងតួនាទីរបស់សហរដ្ឋអាមេរិក»។ ការពិភាក្សាលើប្រធានបទនេះ បានស្វែងយល់បន្ថែមអំពីរបៀបដែលសោកនាដកម្មបានកើតឡើងនៅក្នុងបរិបទសង្គ្រាមត្រជាក់ក្រោមការធ្វើអន្តរាគមន៍របស់សហរដ្ឋអាមេរិក និងការសម្លាប់រង្គាល ក្នុងកំឡុងសង្គ្រាមត្រជាក់ និងតួនាទីរបស់សហរដ្ឋមេរិក។ សហរដ្ឋអាមេរិក និងសង្គ្រាមស៊ីវិល ដែលបានកើតឡើងនៅក្នុងប្រទេសក្រិចចន្លោះពីឆ្នាំ១៩៤៦ ដល់ ឆ្នាំ១៩៤៩ និងការបង្ហាញអំពីការសម្លាប់រង្គាលនៅលើកោះជេជូនៃឧបទ្វីបកូរ៉េខាងត្បូង ដែលបានកើតឡើងនៅក្នុងខណៈពេលប្រហាក់ប្រហែលគ្នាដែរ។

២) សម័យប្រជុំទី២ ថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៨ បានផ្តោតសំខាន់ទៅលើ «ការតស៊ូប្រឆាំងអំពើប្រល័យពូជសាសន៍ និងការទទួលខុសត្រូវរបស់រដ្ឋាភិបាល»។ លោក Nai Wei Cheng អ្នកស្រាវជ្រាវនៅសាលមហោស្រពជាតិ បានធ្វើការពិភាក្សាអំពី «ការស្តារឡើងវិញនូវឧបទ្ទវហេតុ ២.២៨ តៃវ៉ាន់»។ បន្ទាប់មកលោក Gu-Byeong មកពីសាកលវិទ្យាល័យ Ajou បានបកស្រាយអំពី«សង្គ្រាមត្រជាក់និងអំពើប្រល័យពូជសាសន៍នៅប្រទេសហ្គាតេម៉ាឡា៖ការសម្លាប់រង្គាលលើជនជាតិភាគតិច នៅដើមទសវត្សរ៍ឆ្នាំ១៩៨០»។ Park Chan មកពីមជ្ឈមណ្ឌលសិក្សាអំពីកោះជេជូ៤.៣ ក៏បានរៀបរាប់អំពី «ប្រវត្តិសាស្ត្រនៃការតស៊ូរបស់សហគមន៍នៅលើកោះជេជូ»។ ជាចុងក្រោយ ក៏មានវាគ្មិន២រូបទៀត ដែលជាអ្នកពិគ្រោះយោបល់គឺ Kim Yoon-Kyung មកពីសាកលវិទ្យាល័យសេអ៊ូល និងលោក Jeong Sim Yang មកពីសាកលវិទ្យាល័យ Ihwa Women's University។

៣) សម័យប្រជុំទី៣ បានប្រារព្ធធ្វើឡើងនៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៨ ដោយមានការពិភាក្សាអំពីប្រធានបទ

«ការពិត យុត្តិធម៌ និងសាមគ្គីភាព ៖ ផ្តោតសំខាន់លើកិច្ចការ និងសកម្មភាពការងាររបស់អង្គការក្រៅរដ្ឋាភិបាល»។

លោក ឆាំង យុ នាយកប្រតិបត្តិនៃវិទ្យាស្ថានស្លឹករឹត ជាវាគ្មិនមួយរូបមកពីប្រទេសកម្ពុជា បានចូលរួមចែករំលែកអំពីហេតុការណ៍ ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជា ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹងហេតុការណ៍ ដែលបានកើតឡើងនៅលើកោះជេជូនៃប្រទេសកូរ៉េខាងត្បូង និងប្រទេសក្រោយជម្លោះដ៏ទៃទៀត។ លោក ឆាំង យុ ក៏បានចែករំលែកបទពិសោធន៍ការងារនិងបកស្រាយលើប្រធានបទ«ការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជា ក្នុងបរិបទជាសាកល ៖ គម្រោងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៩ ដល់ ឆ្នាំ២០២១»។ លោកបានធ្វើបទបង្ហាញទៅលើប្រធានបទទាំងនេះ ជាភាសាខ្មែរនៅក្នុងការប្រជុំនៅលើកោះជេជូថា ៖

ក្រុមចលនាកុម្មុយនីស្តនៅក្នុងប្រទេសកម្ពុជា មានដើមកំណើតតាំងពីឆ្នាំ១៩៤៥ គឺប្រហាក់ប្រហែលនឹងដើមកំណើតដែលបានកើតឡើងនៅប្រទេសកូរ៉េខាងត្បូងដែរ។ នៅក្នុងប្រទេសកម្ពុជា ចលនាកុម្មុយនីស្តបានតស៊ូ រួបរួម និងបានចំណាយពេលវេលាអស់ប្រហែល៣០ឆ្នាំ ដើម្បីទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ នៅពេលដែលចលនាកុម្មុយនីស្តទទួលបានជ័យជម្នះភ្លាម យើងគិតថា ប្រទេសជាតិទទួលបានសន្តិភាពពេញលេញ ពីព្រោះនៅក្នុងប្រទេសកម្ពុជា យើងមិនដែលជួបប្រទះសង្គ្រាមការបាក់បែក ទោះបីជាយើងស្ថិតក្រោមអាណានិគមបរទេសអស់រយៈពេលប្រហែល១សតវត្សរ៍យ៉ាងណាក៏ដោយ។ ប៉ុន្តែផ្ទុយទៅវិញ នៅពេលដែលចលនាកុម្មុយនីស្តឡើងកាន់អំណាច នៅក្នុងប្រទេសកម្ពុជា ដែលមនុស្សជាតិស្គាល់ថា របបខ្មែរក្រហម ដោយរឿងរ៉ាវដំបូងដែលក្រុមកុម្មុយនីស្តបានធ្វើ គឺបណ្តេញប្រជាជនចេញពីទីក្រុងភ្នំពេញទាំងអស់ និងក្នុងរយៈពេលប្រហែលត្រឹមតែ៤ឆ្នាំប៉ុណ្ណោះ មនុស្សជាង២លាននាក់បានស្លាប់បាត់បង់ជីវិត និងបន្សល់ទុកគុកជិត២០០កន្លែង កន្លែងតម្កល់សពមានជាង១០០កន្លែង និងប្រជាជនប្រហែល២៥ភាគរយ ដែលជាជនរងគ្រោះមានជំងឺបាក់ស្បាត។

លោក ឆាំង យុ បានបង្ហាញរឿងរ៉ាវទាំងនេះចេញពីបរិបទសាកលថា ក្នុងករណីប្រទេសកម្ពុជា និងការពិនិត្យមើលប្រទេសផ្សេងៗ វាមានលក្ខណៈប្រហាក់ប្រហែលគ្នា។ នៅពេលដែល រដ្ឋាភិបាលចាប់ផ្តើមសម្លាប់ប្រជាជនខ្លួនឯង តែងតែមានកងកម្លាំងខាងក្រៅចូលមកធ្វើអន្តរាគមន៍ ហើយដែលជាទូទៅស្ថិតនៅក្រោមរូបភាពពីរ ៖ ឈ្លានពាន និងជួយរំដោះ។ ក្នុងករណីនេះ ប្រជាជនតែងតែមើលឃើញរូបភាពពីរផ្សេងគ្នាគឺ១)ប្រជាជនមួយចំនួនគិតថាកងកម្លាំងខាងក្រៅចូលមកជួយរំដោះប្រជាជន ពីការសម្លាប់របស់រដ្ឋាភិបាល និង ២) វាជាការឈ្លានពាន និងឆ្លៀតឱកាសពីបរទេស។ បន្ទាប់ពីការរំដោះ និងអន្តរាគមន៍ពីកងទ័ព យើងក៏មានការរំឭកដល់ការដាក់ទណ្ឌកម្ម និងការស្វែងរកយុត្តិធម៌ គឺជាជំហានទី២។ នៅក្នុងបរិបទរបស់ប្រទេសកម្ពុជា បន្ទាប់ពីមានសង្គ្រាម មានការលុកលុយ ដែលឈានដល់ការបង្កើតឲ្យមានការពិភាក្សាគ្នាពីបញ្ហាយុត្តិធម៌ និងបន្ទាប់ពីតម្រូវការនៃយុត្តិធម៌ មនុស្សជាតិក៏បានចាប់ផ្តើមនិយាយអំពីការផ្សះផ្សា។ លោកចង់បង្ហាញអំពីការពិតនៃជីវិត និងភាពផ្ទុយគ្នារវាងភាពអាក្រក់ និងល្អ។ នៅពេលដែលយើងគិតពីអតីតកាល និងភាពសោកសៅគឺមិនមែនដើម្បីសងសឹក មិនមែនដើម្បីរស់នៅក្នុងអតីតកាលនោះទេ ប៉ុន្តែយើងត្រូវរកភាពវិជ្ជមានដើម្បីបោះជំហានទៅមុខ។

លោក ឆាំង យុ ក៏បានរៀបរាប់អំពីកិច្ចការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំពោះការឆ្លើយតបទៅនឹងអំពើប្រល័យពូជសាសន៍នៅប្រទេសកម្ពុជាក្នុងបរិបទជាសាកល៖ គម្រោងយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០១៩ ដល់ឆ្នាំ២០២១។ គម្រោងយុត្តិសាស្ត្រនេះ បង្ហាញពីជំហានបន្ទាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីចូលរួមដោះស្រាយទៅលើស្រមោលអន្ធការនៃភាពតក់ស្លុត ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម និងប្រែក្លាយសង្គមកម្ពុជាឲ្យមានអនាគត

ភ្ញីស្វាងឡើងវិញតាមរយៈគោលគំនិតសំខាន់ៗ៣គឺ ៖

១) កេរដំណែលជាក់ស្តែង ៖ ការសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវពីអំពើប្រល័យពូជសាសន៍អចិន្ត្រៃយ៍

២) កេរដំណែលនៃការចងចាំ ៖ ការអប់រំពីអំពើប្រល័យពូជសាសន៍ ការចងចាំអំពីប្រវត្តិរបស់ជនរងគ្រោះ និងដំណើរការពិភាក្សាលើការចងចាំ

៣) កេរដំណែលយុត្តិធម៌ ៖ រឿងរ៉ាវពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អតីតកាលដែលត្រូវបានលាតត្រដាង និងដំណើរការនៃការដាក់ឲ្យប្រើប្រាស់ឯកសារប្រវត្តិសាស្ត្រជាសាកល។

បន្ទាប់មក កញ្ញា Nisrina Nadhifah Rahman ជាវាគ្មិនមកពីប្រទេសឥណ្ឌូនេស៊ីបានរៀបរាប់អំពី «ភាពចលាចលនៃយុត្តិធម៌នៅក្នុងប្រទេសឥណ្ឌូនេស៊ីក្នុងរយៈពេល២០ឆ្នាំនៃកំណែទម្រង់» និងវាគ្មិន Takazato Suzuyo មកពីតំបន់អូគីណាវ៉ានៃប្រទេសជប៉ុន បានបកស្រាយលើប្រធានបទ «ប្រវត្តិនៃការតស៊ូរបស់តំបន់អូគីណាវ៉ាចំពោះការរើសអើង និងការគាបសង្កត់។ Yung Sun Heo នាយកនៃវិទ្យាស្ថានស្រាវជ្រាវជេជូ ៤.៣ ក៏បានបកស្រាយអំពីដំណើរឆ្ពោះទៅកាន់ប្រវត្តិសាស្ត្រនៃការពិត និងយុត្តិធម៌ និង Ho Jin Kang គណៈកម្មការនៃការចងចាំសម្រាប់ខួបលើកទី៧០ នៃការបះបោរ និងការសម្លាប់ ក្នុងថ្ងៃទី៣ ខែមេសា នៅកោះជេជូ បានលើកឡើងអំពីការរស់នៅដោយសាមគ្គីភាពអស់រយៈពេល ៧០ឆ្នាំនៃជេជូ៤.៣ ដែលនេះជាពេលវេលាមួយសម្រាប់ធ្វើការទាពេលបច្ចុប្បន្ន។

នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៨ អ្នកចូលរួមទាំងអស់ក៏បានធ្វើដំណើរទស្សនកិច្ចទៅកាន់សារមន្ទីរជេជូ៣ មេសា និងវាលពិឃាតនៅក្នុងភូមិមួយជាប់មាត់សមុទ្រ។

សន្និសីទអន្តរជាតិសម្រាប់ខួបលើទី៧០នៃការរំឭកដល់ព្រឹត្តការណ៍ ដែលបានកើតឡើងនៅថ្ងៃទី៣ ខែមេសា គឺជាកម្មវិធីមួយសម្រាប់ការរំឭកអំពីប្រវត្តិសាស្ត្ររបស់កោះជេជូ ការចែករំលែកអំពីបទពិសោធន៍ការងារ និងផ្លាស់ប្តូរគំនិតគ្នារវាងស្ថាប័នជាតិ និងអន្តរជាតិដែលបានប្រឈមមុខនឹងបញ្ហាដែលបានបន្សល់ទុកក្នុងពេលអតីតកាលដែលនៅបន្តរហូតដល់បច្ចុប្បន្ន។

**អ៊ុន សុដាវី**



អគារនៅលើកោះជេជូ ប្រទេសកូរ៉េខាងត្បូង

# ហេតុការណ៍ដ៏ឃោរឃៅនៅតែដិតជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំ

ខ្ញុំឈ្មោះ បឿក បឹត អាយុ៦៥ឆ្នាំ មានស្រុកកំណើត នៅភូមិគោកចាស់ ឃុំសំបួរ ស្រុក ក្រឡាញ់ ខេត្តសៀមរាប។ ខ្ញុំបានរៀបការជាមួយប្រពន្ធឈ្មោះ អ៊ុច សាត នៅខែពិសាខ ឆ្នាំ១៩៧៥ មួយខែក្រោយពេលដែលខ្មែរក្រហមកាន់កាប់ ទីក្រុងភ្នំពេញ។ ពេលនោះ ខ្ញុំមានអាយុ ២៤ឆ្នាំ ចំណែក ប្រពន្ធរបស់ខ្ញុំមានអាយុ២២ឆ្នាំ។ ខ្ញុំមានកូន១២នាក់ ប្រុស ៤នាក់ ស្រី៨នាក់។ កូនស្រី២នាក់ និងកូនប្រុសម្នាក់របស់ខ្ញុំ បានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ដោយសារ កើតជំងឺកញ្ជ្រិល និងមិនមានទឹកដោះបៅគ្រប់គ្រាន់។ សព្វថ្ងៃ នេះ ខ្ញុំរស់នៅឃុំលំទង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ ដោយប្រកបរបរធ្វើស្រែ ដាំដំឡូងមី និងនេសាទត្រី។

នៅមុនរបបប្រជាធិបតេយ្យ ខ្ញុំរស់នៅស្រុកកំណើត នៅក្នុងខេត្តសៀមរាប ដោយប្រកបមុខរបរធ្វើស្រែចម្ការ ជាមួយឪពុក និងបងប្អូន។ បើទោះបីជាខ្មែរក្រហមបានឡើង គ្រប់គ្រង អំណាចអស់រយៈពេល១ខែមកហើយក៏ដោយ ក៏ខ្ញុំ នៅប្រកបរបររកស៊ីជាធម្មតានៅក្នុងភូមិដដែល។ ក្រោយ មក ទើបកម្មាភិបាលខ្មែរក្រហម ចាប់ផ្ដើមជម្លៀសខ្ញុំចេញពី ប្រពន្ធ និងឪពុក ម្ដាយឲ្យទៅធ្វើការតាមការដ្ឋាន។

ជារៀងរាល់ថ្ងៃ ខ្ញុំត្រូវក្រោកពីព្រលឹម ងូតទឹក រៀបចំ ខ្លួនដើម្បីទៅធ្វើការតាមការបង្គាប់ បញ្ជារបស់ប្រធានកង។ ខ្ញុំត្រូវចេញទៅធ្វើការចាប់ពីម៉ោង៦ព្រឹក ដល់ម៉ោង១១ថ្ងៃ ត្រង់។ បន្ទាប់ពីសម្រាកហូបអាហារថ្ងៃត្រង់ ខ្ញុំបានចាប់ផ្ដើម ចូលធ្វើការនៅម៉ោង១រសៀល រហូតដល់ម៉ោង ៥រសៀល ទើបឈប់។ ការងារដែលខ្ញុំធ្វើជាប្រចាំថ្ងៃ មានដូចជា ជីក


បឿក បឹត នៅផ្ទះរបស់គាត់ក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ


តូបលក់ដូរតាមផ្លូវក្នុងស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

ប្រឡាយ លើកភ្លឺស្រែ និងដកស្ទូងៗ រាល់ថ្ងៃ ប្រធានកងតម្រូវឲ្យកងចល័តម្នាក់លើកភ្លឺស្រែឲ្យបាន ២០ម៉ែត្រក្នុងមួយថ្ងៃ។ ប្រសិនបើនរណាម្នាក់លើកភ្លឺស្រែរួចរាល់នៅមុនពេលម៉ោង ២ ឬ ៣ រសៀល នៅថ្ងៃបន្ទាប់ប្រធានកងនឹងបន្ថែមឲ្យអ្នកនោះលើកភ្លឺស្រែ១០ម៉ែត្របន្ថែមទៀត ដែលសរុបទាំងអស់ ៣០ម៉ែត្រក្នុងមួយថ្ងៃ។ ប៉ុន្តែប្រសិនបើកងចល័តលើកភ្លឺស្រែ ២០ម៉ែត្រ រួចនៅម៉ោង ៤ៈ០០ ឬ ៤ៈ៣០នាទី រសៀល នោះប្រធានកងមិនបន្ថែមការងារឲ្យឡើយ។ ដោយសារតែនៅក្នុងភូមិគោកចាស់ ស្រុកក្រឡាញ់ មិនសូវមានដីស្រែច្រើន ប្រធានកងបានចាត់តាំងខ្ញុំ ព្រមទាំងសមាជិកកងចល័តដទៃទៀតឲ្យទៅដាំបន្លែនៅឯឃុំកំពង់ថ្កូវវិញ។ នៅរដូវវស្សា ពេលដែលទឹកជន់លិចភូមិកំពង់ថ្កូវ អង្គការបានចល័តខ្ញុំទៅភូមិសំរោង ឃុំស្នួល ស្រុកក្រឡាញ់ ដើម្បីដាំបន្លែវិញ។ អង្គការបានចកែមនុស្ស២០នាក់ឲ្យដាំបន្លែក្នុងទំហំដីមួយហិចតា។ ខ្ញុំមិនបានចាំថា អង្គការកំណត់ទិន្នផលបន្លែឲ្យបានប៉ុន្មាននោះទេ គ្រាន់តែចាំថាត្រូវធ្វើយ៉ាងណាដាំដំណាំឲ្យបានផលច្រើនៗ

កាលនោះ មានកងដាំបន្លែមួយកង បានដាំដំណាំបានទិន្នផលតិចដោយសារដីពុំសូវមានជីវជាតិ ហើយទោះបីជាប្រធាន និងសមាជិកកងដាំបន្លែនោះខិតខំពន្យល់យ៉ាងណាក៏ដោយ ក៏កម្មាភិបាលខ្មែរក្រហមមិនស្តាប់ដែរ ថែមទាំងស្តីបន្ទោស និងបង្អត់បាយកងដាំបន្លែមួយថ្ងៃទៀតផងៗ បន្ទាប់មក អង្គការបានចល័តកងដាំដំណាំនោះឲ្យទៅដាំបន្លែនៅឃុំផ្សេងទៀត ដោយមិនឲ្យសម្រាកឡើយ ថែមទាំងកំណត់ឲ្យដាំដំណាំក្នុងផ្ទៃដីទំហំ៥ហិចតា ឲ្យហើយក្នុង១សប្តាហ៍។ ខ្ញុំអាណិតសមាជិកកងដាំណាំទាំងនោះខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនអាចជួយពួកគេបាន។ ដោយបានឃើញរឿងបែបនោះហើយ ទើបខ្ញុំខិតខំប្រឹងប្រែងធ្វើការ ទោះជានឿយហត់ ឬលំបាកយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនទម្រន់ និងត្អូញត្អែរដែរ ពីព្រោះខ្ញុំដឹងថា ខ្មែរក្រហមតែងតែចាត់ឈ្លបឲ្យឃ្លាំមើលខ្ញុំ និងសមាជិកកងគ្រប់ពេល។ ប្រសិនបើខ្មែរក្រហមដឹងថានរណាម្នាក់ហ៊ានត្អូញត្អែរ ខ្មែរក្រហមនឹងយកអ្នកទាំងនោះទៅរៀនសូត្រភ្លាមៗ

ក្រៅពីដាំបន្លែ លើកភ្លឺស្រែ ជីកប្រឡាយ និងដកស្ទូង ខ្ញុំធ្លាប់ត្រូវបានខ្មែរក្រហមចាត់ឲ្យទៅកាប់ខស ដោយខ្មែរក្រហមតម្រូវឲ្យខ្ញុំទៅកាប់ខសជាក្រុមដែលមានសមាជិក៤នាក់ ជាមួយនឹងរទេះគោ៤គ្រឿងសម្រាប់ដឹកខសត្រឡប់មកសហករណ៍វិញ។ ការកាប់ខសនោះ ខ្មែរក្រហមតម្រូវឲ្យខ្ញុំកាប់ខសឲ្យបានពេញមួយរទេះ ទើបអាចត្រឡប់មកសហករណ៍វិញ។ ពេញមួយថ្ងៃនោះ ខ្ញុំមិនបានសម្រាកសូម្បីតែពេលហូបបាយថ្ងៃពីព្រោះព្រៃក្រាស់ សម្បូរសត្វសាហាវ ដូច្នេះកងរបស់ខ្ញុំទាំង៤នាក់ខំប្រឹងធ្វើការយ៉ាងណាកាប់ខសឲ្យបានពេញរទេះរៀងៗខ្លួន រួចហើយទើបរួតរះដាំបាយហូប និងត្រូវត្រឡប់មកសហករណ៍វិញនៅវេលាម៉ោងប្រហែលជា ៧យប់។ បន្ទាប់ពីមកដល់សហករណ៍ កម្មាភិបាលខ្មែរក្រហមក៏ដើរមកបញ្ជាឲ្យកងរបស់ខ្ញុំជញ្ជូនខសចេញពីរទេះទាល់តែអស់ទើបអនុញ្ញាតឲ្យទៅសម្រាកៗរីឯការហូបចុកខ្មែរក្រហមបានកំណត់ឲ្យសមាជិកកងហូបតែពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ គឺនៅពេលថ្ងៃត្រង់ និងពេលល្ងាចៗ អាហារនោះ គឺគ្មានអ្វីក្រៅពីបបរសពីរវែក ដែលមានតែទឹកលាយជាមួយអង្ករប្រហែល២០គ្រាប់ប៉ុណ្ណោះៗ ដោយហេតុតែស្រេកឃ្លានខ្លាំងពេក នៅពេលយប់ ខ្ញុំបានទៅលួចបេះត្រកួន និងព្រលិតយកមកបបរជាមួយស្រូវដើម្បីហូបចម្អែតក្រពះៗ ការលួចអាហារហូបនោះ គឺខ្ញុំអាចលួចបានតែម្តងទៅពីរដងប៉ុណ្ណោះក្នុងមួយសប្តាហ៍ និងពេលខ្លះខ្ញុំមិនបានទៅលួចទេ ព្រោះខ្មែរក្រហមបានចាត់ឲ្យកងឈ្លបតាមស៊ើបរកអ្នកលួចអាហារ។

ខ្ញុំបានរស់នៅក្នុងភាពភ័យខ្លាច តក់ស្លុតគ្រប់ពេលវេលាដូចចាស់ៗតែងនិយាយពេលព្រលឹមរស់បានមួយយប់ ពេលព្រលប់រស់បានមួយថ្ងៃដូច្នេះដែរ។ ម្យ៉ាងទៀត រឿងរ៉ាវតក់ស្លុត មួយចំនួននៅតែវិលវល់ និងដិតដាមជាប់នៅក្នុងចិត្តខ្ញុំរហូតមកដល់សព្វថ្ងៃនេះ គឺការសម្លាប់រង្គាលរបស់ខ្មែរ-ក្រហមទៅលើប្រជាជននៅបត់ត្រង់ គោកស្វាយ និងភូមិស្នួល ស្រុកក្រឡាញ់។ ខ្ញុំបានឃើញខ្មែរក្រហមហៅប្រជាជនដែល

រស់នៅក្នុងភូមិទាំងនោះយកទៅកសាង (រៀនសូត្រ) ម្ដង១០០ គ្រួសារ តាមពិតខ្មែរក្រហមយកអ្នកទាំងនោះ ទៅសម្លាប់ចោលទាំងអស់។ ខ្មែរក្រហមបានចងអ្នកទាំងនេះជាមួយខ្សែស្មើងជាប់គ្នា ដោយមានកម្មាភិបាលតូចៗពីរនាក់ស្ពាយកាំភ្លើងអូសដី បណ្ដើរយកទៅវាយសម្លាប់ចោលដោយចោទប្រកាន់ប្រជាជនទាំងនោះថា ជាជនក្បត់។ ខ្មែរក្រហមបានវាយសម្លាប់ប្រជាជនទាំងនោះម្ដងម្នាក់ៗ រួចរុញទម្លាក់ចូលទៅក្នុងរណ្ដៅដែលមានអង្គាមនៅខាងក្រោម។ បន្ទាប់មកខ្មែរក្រហមដុតសាកសពអ្នកទាំងនោះ ដែលអ្នកខ្លះនៅមានដង្ហើមនៅឡើយ។ ពេលនោះខ្ញុំបានឮប្រជាជនខ្លះបានស្រែកទ្រហោយំកងរំពងដោយសេចក្ដីឈឺចាប់ខ្លោចផ្សា ធ្វើឲ្យខ្ញុំភ័យខ្លាចរយៈពេលបីយប់។ នៅពេលខ្លះខ្ញុំធ្វើការបណ្ដើរហូរទឹកភ្នែកបណ្ដើរ ដោយអាណិតអាសូរជនរងគ្រោះទាំងនោះ។ ហេតុការណ៍ដ៏សែនតក់ស្លុត និងព្រៃផ្សៃនេះនៅតែជាប់ដិតដាមនៅក្នុងអារម្មណ៍របស់ខ្ញុំមកដល់សព្វថ្ងៃ។

ខ្ញុំត្រូវបានកងទ័ពរណសិរ្សដែលគាំទ្រដោយវៀតណាមចូលមករំដោះ នៅថ្ងៃ៧ ខែមករា ឆ្នាំ១៩៧៩ រួមទាំងប្រជាជនកម្ពុជាផ្សេងទៀត។ ខ្ញុំត្រេកអរយ៉ាងខ្លាំង និងមានអារម្មណ៍ថាបានកើតជាថ្មី។ ខ្ញុំបានរត់តាមប្រជាជនដ៏ទៃទៀតត្រឡប់ទៅរកក្រុមគ្រួសារជាទីស្រឡាញ់របស់ខ្ញុំ និងបានកសាងជីវិតគ្រួសារជាថ្មីឡើងវិញ។ រយៈពេល២៣ឆ្នាំក្រោយមកទើបខ្ញុំ ព្រមទាំងក្រុមគ្រួសារបានសម្រេចចិត្តផ្លាស់ប្ដូរទីលំនៅមករស់នៅក្នុងស្រុកអន្លង់វែង ខេត្តឧត្តមានជ័យ ដោយសារគ្រួសារខ្ញុំមានសមាជិកច្រើន បូករួមទាំងស្ថានភាពនៅអន្លង់វែង អំណោយផលដល់ការប្រកបរបររកស៊ីនិងធ្វើសម្រែចម្ការដើម្បីចិញ្ចឹមជីវិត។ ខ្ញុំសូមផ្ដាំផ្ញើទៅក្មេងជំនាន់ក្រោយត្រូវខិតខំរៀនសូត្រឲ្យមានចំណេះដឹងជ្រៅជ្រះ ដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេសឲ្យរីកចម្រើនព្រមទាំងមានឆន្ទៈស្នេហាប្រទេសជាតិការពារកុំឲ្យប្រទេសជាតិយើងជួបសង្គ្រាមដ៏ជូរចត់ និងជួបអំពើឃោរឃៅយង់ឃ្នងដូចក្នុងរបបខ្មែរក្រហមម្ដងទៀត។ **អោក លីណា**



ក្រុមនិសិត្សស្ម័គ្រចិត្តចុះសម្ភាសន៍ប្រជាជនតាមភូមិនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ

# អ្នកជំងឺឃ្លង់នៅក្នុងភូមិត្រើង

ខ្ញុំពិតជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលខ្ញុំបានមករស់នៅភូមិត្រើងដំបូង ដោយប្រជាជនភាគច្រើននៅក្នុងភូមិនេះបានកើតជំងឺឃ្លង់។ ជំងឺឃ្លង់នេះបានធ្វើឲ្យអ្នកជំងឺមានរោគសញ្ញាសលើស្បែក ក្រញង់ និងខ្វិនដៃជើង។ អ្នកជំងឺឃ្លង់ទាំងនេះ មកពីតំបន់ផ្សេងៗ និងបានប្រមូលផ្តុំគ្នារស់នៅក្នុងភូមិមួយ គឺ «ភូមិត្រើង»។ កាលពីសម័យមុន អ្នកកើតជំងឺឃ្លង់នៅក្នុងភូមិត្រើង មានការរើសអើងខ្លះពីប្រជាជនដែលរស់នៅភូមិក្បែរៗនោះ ហើយសូម្បីតែការជ្រើសរើសគូស្រករក៏ប្រជាជននៅភូមិក្បែរនោះមិនជ្រើសរើសយកកូនក្រមុំ ឬកូនកម្លោះដែលរស់នៅក្នុងភូមិត្រើងដែរ។ ប៉ុន្តែទោះបីមានការរើសអើងយ៉ាងណាក៏ដោយ ក៏អ្នកជំងឺឃ្លង់នៅក្នុងភូមិនេះ នៅតែស្រឡាញ់រាប់អានសាមគ្គីគ្នា និងរស់នៅយ៉ាងសុខសាន្តដែរ។

ខ្ញុំឈ្មោះ ទ្រី ស៊ិន អាយុ៨៤ឆ្នាំ មានស្រុកកំណើតនៅខេត្តកំពត។ ខ្ញុំត្រូវបានរដ្ឋាភិបាលរបបសង្គមរាស្ត្រនិយមបញ្ជូនឲ្យមករស់នៅភូមិត្រើង ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម នៅឆ្នាំ១៩៥៥ ដោយសារខ្ញុំមានរោគសញ្ញាស្ពឹកលើរាងកាយ ដែលសង្ស័យថា ជាជំងឺឃ្លង់ (បច្ចុប្បន្នហៅថា ជំងឺហង់សិន)។ ខ្ញុំបានរស់នៅភូមិត្រើងនេះ ក្រោមការជួយឧបត្ថម្ភប្រាក់ពីឪពុកខ្ញុំឈ្មោះ ភូជា យុក មានមុខរបរជាជាងធ្វើគ្រឿងសង្ហារឹម និងម្តាយខ្ញុំឈ្មោះ ជ្រុន សុហួយ គឺជាអ្នកលក់បន្លែ ត្រី សាច់ នៅផ្សារកំពត។

នៅក្នុងភូមិត្រើង ខ្ញុំបានជួបជាមួយប្រជាជនជាច្រើនដែលកើតជំងឺឃ្លង់ មកពីគ្រប់ខេត្តក្រុងក្នុងប្រទេសកម្ពុជា។ ខ្ញុំ និងអ្នកជំងឺឃ្លង់ទាំងនេះ ត្រូវបានបញ្ជូនឲ្យមករស់នៅក្នុងភូមិត្រើងនេះដើម្បីងាយស្រួលក្នុងការតាមដាន ព្យាបាល និងការពារទប់ស្កាត់ កុំឲ្យឆ្លងជំងឺទៅសមាជិកក្រុមគ្រួសាររបស់ខ្លួនទៀត។ រាជរដ្ឋាភិបាលរបបសង្គមរាស្ត្រនិយម បានយកចិត្តទុកដាក់ព្យាបាលអ្នកជំងឺឃ្លង់យ៉ាងខ្លាំង ដោយបានសាងសង់ផ្ទះដែលមានបណ្តោយវែងៗ សម្រាប់ឲ្យអ្នកជំងឺស្នាក់នៅ និងបានធ្វើការបែងចែកអ្នកជំងឺជាពីរប្រភេទ គឺ ១) អ្នកជំងឺដែលមានអាការធ្ងន់ធ្ងរ (មានដំបៅ កំបុតម្រាមដៃ ឬម្រាមជើង ពិការ និង ក្រញង់ដៃជើង) ដាក់ឲ្យស្នាក់នៅក្នុងផ្ទះចាស់ និង ២) អ្នកជំងឺដែលមានអាការស្រាលៗ (អ្នកដែលពេទ្យបានកំណត់រោគសញ្ញាថា កើតជំងឺឃ្លង់) ដាក់ឲ្យស្នាក់នៅរោងដែលទើបសង់ថ្មីៗ។ ចំណែកម្ហូបអាហារវិញ រាជរដ្ឋាភិបាលបានចែកអង្ករ និងម្ហូប សម្រាប់អ្នកជំងឺទៅតាមថ្ងៃ ដូចជា ថ្ងៃច័ន្ទ សុក្រ និង សៅរ៍ ទទួលបានត្រីស្រស់។ ថ្ងៃអង្គារ៍ និង ថ្ងៃពុធ ទទួលបានត្រីងៀត។ ថ្ងៃព្រហស្បតិ៍ ទទួលបានសាច់គោ និងថ្ងៃអាទិត្យ ទទួលបានសាច់ជ្រូក ចំណែកអង្ករ



ទ្រី ស៊ិន

សម្រួប អ្នកជំងឺឃ្លង់ទទួលបានប្រាំបីខាំសម្រាប់ហូបរយៈពេលពីរថ្ងៃ។ រីឯថ្នាំសម្រាប់លេបព្យាបាលជំងឺនេះ ក៏មិនខ្វះដែរសម័យនោះ។ ការមកសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យក្នុងភូមិត្រើងនេះ បានធ្វើឲ្យខ្ញុំធូរស្បើយ លែងស្ពឹកដៃជើង ហើយរោគសញ្ញាចេញលើត្រចៀកពណ៌សៗក៏រលុបបាត់ដែរ។ នៅភូមិត្រើងក៏មានសាលារៀនសម្រាប់អ្នកជំងឺឃ្លង់ដែរ ប៉ុន្តែខ្ញុំមិនបានចូលរៀនទេព្រោះខ្ញុំរស់នៅម្នាក់ឯង និងនៅក្មេងមិនមានអ្នកដាំបាយឲ្យហូប។ ក្រោយមកខ្ញុំបានទៅសុំ តាសុង រស់នៅជាមួយ។ គាត់ក៏កើតជំងឺឃ្លង់ដូចខ្ញុំដែរ។ គាត់មានតួនាទីជាប្រធានចែកអង្ករ និងម្ហូប ដែលមានស្រុកកំណើតនៅខេត្តកំពត។ ខ្ញុំរស់នៅជាមួយគាត់ បានហូបចុកគ្រប់គ្រាន់ដោយគ្រាន់តែជួយធ្វើការងារគាត់បន្តិចបន្តួចប៉ុណ្ណោះ។

ក្រោយមកនៅឆ្នាំ១៩៦០ ខ្ញុំបានរៀបការប្រពន្ធឈ្មោះ ឆាយ ស៊ីវ៉ា មានជំងឺឃ្លង់ដូចខ្ញុំដែរ មានស្រុកកំណើតនៅខេត្តកំពង់ឆ្នាំង។ ចំណងអាពាហ៍ពិពាហ៍របស់យើងទាំងពីរមានកូនចំនួនពីរនាក់ ស្រីមួយ និងប្រុសមួយ។ ក្រោយរៀបការខ្ញុំ និងប្រពន្ធរបស់ខ្ញុំបាននាំគ្នារកស៊ីលក់ដូរបន្តិចបន្តួចនៅផ្ទះដើម្បីបានប្រាក់ខ្លះសម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ។

ក្រោយរដ្ឋប្រហារទម្លាក់សម្ដេចព្រះ នរោត្តម សីហនុ មក ទោះបីជារបបនយោបាយដឹកនាំមានការប្រែប្រួលយ៉ាងណាក្ដី ក៏ការឧបត្ថម្ភស្បៀងអាហារ និងថ្នាំសម្រាប់អ្នកកើតជំងឺឃ្លង់នៅក្នុងភូមិត្រើងពីសំណាក់រដ្ឋាភិបាលនៃរបបសាធារណរដ្ឋខ្មែរនៅតែមានដដែល។ នៅពេលមានការវាយប្រយុទ្ធគ្នារវាងកងកម្លាំងខ្មែរក្រហម និងកងទ័ព លន់ នល់ កងកម្លាំង



ទីតាំងមន្ទីរពេទ្យចាស់សម្រាប់ព្យាបាលអ្នកកើតជំងឺឃ្លង់

ខ្មែរក្រហមបានគ្រប់គ្រង និងកាត់ផ្ដាច់ផ្លូវជាតិលេខ៦អា ដែលបង្កឲ្យមានការលំបាកដល់រដ្ឋាភិបាលសាធារណរដ្ឋខ្មែរក្នុងការដឹកជញ្ជូនអង្ករ និងស្បៀងអាហារសម្រាប់អ្នកជំងឺឃ្លង់ក្នុងភូមិត្រើង។ ក្រោយមក ការដឹកជញ្ជូនស្បៀងនេះត្រូវបានកាត់ផ្ដាច់ទាំងស្រុង ដោយសារតែភូមិត្រើងជាសមរភូមិប្រយុទ្ធរវាងកងទ័ព លន់ នល់ និងកងកម្លាំងខ្មែរក្រហម។

បន្ទាប់ពីកងកម្លាំងរបស់ខ្មែរក្រហមវាយកាន់កាប់បានភូមិត្រើង ខ្មែរក្រហមក៏បានជម្លៀសប្រជាជនក្នុងភូមិនេះ រួមទាំងអ្នកកើតជំងឺឃ្លង់ឲ្យទៅរស់នៅភូមិទំនប់ (ភូមិនេះពុំមានប្រជាជនរស់នៅទេ នៅសម័យសង្គមរាស្ត្រនិយម រាជរដ្ឋាភិ-បាលសាងសង់ទំនប់នេះឡើងដើម្បីរក្សាទឹកទុកប្រើប្រាស់)។ នៅពេលនោះ ប្រជាជនត្រូវសាងសង់ខ្ទមក្នុងព្រៃសម្រាប់ស្នាក់នៅ និងត្រូវកាប់ឆ្ការព្រៃដើម្បីធ្វើស្រែ។ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅភ្ជួរស្រែ ព្រោះដៃជើងរបស់ខ្ញុំមិនក្រញង់ ចំណែកយុវជនផ្សេងទៀតត្រូវបានចាត់តាំងឲ្យលើកទំនប់ទួលពោន ស្ថិតនៅក្នុងភូមិផ្កាយព្រឹក ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម។

ក្រោយពីជម្លៀសប្រជាជនចេញពីភូមិអស់ ខ្មែរក្រហមបានយកទីតាំងភូមិត្រើងធ្វើជាមន្ទីរពេទ្យ។ នៅពេលដែលប្រ-ជាជននៅតាមសហករណ៍ឈឺថ្កាត់ ខ្មែរក្រហមបានបញ្ជូនអ្នកជំងឺទាំងនោះមកព្យាបាលនៅមន្ទីរពេទ្យភូមិត្រើង ដោយឡែកអ្នកជំងឺដែលមានស្ថានភាពធ្ងន់ធ្ងរ គឺខ្មែរក្រហមបានយកទៅសម្លាប់ចោលតែម្តង។ ក្នុងសម័យនោះ អ្នកជំងឺដែលបញ្ជូនមកសម្រាកនៅមន្ទីរពេទ្យត្រើងភាគច្រើនកម្រគេចផុតពីសេចក្ដីស្លាប់ណាស់ គឺស្លាប់ដោយសារជំងឺ និងស្លាប់ដោយសារការយកទៅសម្លាប់ចោល។ ខ្ញុំធ្លាប់ត្រូវបានខ្មែរក្រហមនាំយកទៅសម្លាប់ចោលដែរ ប៉ុន្តែដោយសារចំនួនប្រជាជនដែលខ្មែរក្រហមគ្រោងយកទៅសម្លាប់គ្រប់តាមចំនួនកំណត់ ទើបខ្មែរក្រហមបានបញ្ជូនខ្ញុំត្រឡប់មកធ្វើស្រែដូចមុន។

នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានរៀបចំប្រជាជនដែលបានជម្លៀសទៅនៅភូមិទំនប់ ទៅជាសហករណ៍។ ពេលនោះ ទោះបីជាប្រជាជនដែលរស់នៅក្នុងភូមិនោះ ភាគច្រើនកើតជំងឺឃ្លង់ក៏ដោយ ក៏ខ្មែរក្រហមនៅតែបញ្ជាឲ្យធ្វើការដូចប្រជាជនធម្មតាដែរ។ អ្នកកើតជំងឺឃ្លង់ទាំងនោះ មានអាការស្ពឹកប្រព័ន្ធប្រសាទ ហើយនៅពេលប៉ះ ឬកំរលាកភ្លើង ក៏មិនដឹងខ្លួនដែរ ប៉ុន្តែបណ្ដាលឲ្យអ្នកជំងឺកើតពងបែកនៅលើស្បែក និងក្លាយទៅជាដំបៅរលួយ។ អ្នកជំងឺឃ្លង់ខ្លះដែលមិនអាចទ្រាំទ្របានចំពោះស្ថានភាពដ៏លំបាកនេះ ក៏បានយកពូថៅ និងកាំបិតមកកៀរដំបៅរលួយចេញពីម្រាមដៃជើង ដើម្បីឲ្យឆាប់ជាមុខរបួស។ ចំពោះអ្នកពិការ និងអ្នកខស្សាហ៍ឈឺថ្កាត់ញឹកញាប់ ខ្មែរក្រហមបានបញ្ជូនឲ្យទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យ ប៉ុន្តែកម្រឃើញអ្នកជំងឺនោះត្រឡប់មកវិញណាស់។ ខ្មែរក្រហមមានគម្រោងយកអ្នកកើតឃ្លង់ទាំងអស់យកទៅសម្លាប់ចោល ព្រោះជាជំងឺដែលពិបាកព្យាបាល និងមិនមានផលប្រយោជន៍សម្រាប់ខ្លួន។

ប្រជាជនដែលកើតជំងឺឃ្លង់កាលក្នុងសម័យសង្គមរាស្ត្រនិយម និង លន់ នល់ មានជាង១០០គ្រួសារ ក្រោយពេលខ្មែរក្រហមដួលរលំប្រជាជនកើតជំងឺឃ្លង់នៅរស់រានមានជីវិតប្រមាណ៥០គ្រួសារប៉ុណ្ណោះ ព្រោះអ្នកកើតឃ្លង់មួយចំនួនត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅភូមិស្គន់ ព្រៃកុង ក្នុងខេត្តកំពង់ចាម។

ខ្ញុំបានទទួលដំណឹងគ្រួសាររបស់ខ្ញុំនៅក្រោយខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ប្អូនប្រុសខ្ញុំឈ្មោះ ស៊ុន ហ៊ន ត្រូវបានខ្មែរក្រហមយកទៅសម្លាប់ព្រោះខ្មែរក្រហមចោទប្រកាន់ថា ប្អូនប្រុសខ្ញុំធ្វើពុតជាឈឺចុកពោះញឹកញាប់ ចំណែកប្អូនម្នាក់ទៀតឈ្មោះ ស៊ុន ភាន់ ជានិស្សិត និងឪពុកខ្ញុំក៏ត្រូវបានខ្មែរក្រហមយកទៅលត់ដំ និងសម្លាប់ចោលដែរ។ ខ្ញុំមិនបានចោទប្រកាន់ឬគុំគួនចំពោះយោធានិងកម្មាភិបាលខ្មែរក្រហមដែលបានសម្លាប់គ្រួសារខ្ញុំទេ ព្រោះខ្ញុំគិតថាអ្នកទាំងនោះទទួលបញ្ជាពីថ្នាក់លើ ប៉ុន្តែខ្ញុំនៅតែចង់ឲ្យអ្នកទាំងនោះនិយាយការពិត។

ដារ៉ារដ្ឋ មេត្តា

# ពាក្យស្លោកសំខាន់ពីរ ដើម្បីរំឭកពីការចងចាំ និងការទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា

ក្រសួងអប់រំយុវជន និង កីឡា សហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកសម្ពោធផ្ទាំងពាក្យស្លោកស្តីពីការចងចាំ និងទប់ស្កាត់អំពើប្រល័យពូជសាសន៍នៅកម្ពុជា ដែលប្រព្រឹត្តទៅនៅវិទ្យាល័យសម្តេចពញាចក្រី ហេង សំរិន អន្លង់ជ្រៃ ស្ថិតក្នុងឃុំកក់ ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨។

ពាក្យស្លោកទាំងពីរឃ្លានេះ មានខ្លឹមសារថា«រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺរៀនពីការទប់ស្កាត់អំពើប្រល័យពូជសាសន៍» និង «និយាយពីការរស់នៅក្នុងសម័យខ្មែរក្រហម គឺនិយាយពីការផ្សះផ្សា អប់រំកូនចៅឲ្យអត់ខិនអធ្យាស្រ័យគ្នា»។

លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ដែលបានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធនេះ បានមានប្រសាសន៍ថា៖ «យុវជនជំនាន់ក្រោយត្រូវខិតខំរៀនសូត្រ ដោយការយល់ឲ្យច្បាស់លាស់ និងស៊ីជម្រៅ មិនមែនគ្រាន់តែទន្ទេញឲ្យចាំមាត់នោះទេ។ ក្រៅពីឯកសារជាច្រើនអំពីរបបខ្មែរក្រហម សិស្សានុសិស្សអាចស្វែងយល់បន្ថែមទៀតតាមរយៈឯកសាររស់ ពោលគឺ ឪពុកម្តាយ និងជីដូនជីតា ដែលសុទ្ធតែបានឆ្លងកាត់របបនេះ»។ លើសពីនេះទៀត លោកជំទាវបានបញ្ជាក់បន្ថែមពីកំណែទម្រង់ថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការដាក់បញ្ចូលកម្មវិធីសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមថា កម្រិតសិក្សាថ្នាក់បឋម ក៏ត្រូវសិក្សាពីប្រវត្តិសាស្ត្រខ្មែរក្រហមដែរ។

លោក ផេង ពង្សរ៉ាស៊ី នាយកមជ្ឈមណ្ឌលឯកសារភូមិ



លោកជំទាវ ទន់ សាអ៊ីម អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា



លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ភាគបូព៌ា និងគម្រោងស្រាវជ្រាវនិងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាបានឲ្យដឹងថា វិទ្យាល័យសម្តេចចក្រី ហេង សំរិន អន្លង់ជ្រៃនេះ គឺជាវិទ្យាល័យទី២៦ហើយ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា បានដាក់ពាក្យស្លោកអប់រំអំពីរបបកម្ពុជាប្រជាធិបតេយ្យ។ លោកនិយាយថា៖ «ការដាក់ពាក្យស្លោករំឭកពីការចងចាំនៅតាមវិទ្យាល័យនេះ មានគោលបំណង ឲ្យសិស្សានុសិស្សស្វែងយល់អំពីសារសំខាន់នៃការរៀនសូត្រអំពីប្រវត្តិកម្ពុជាប្រជាធិបតេយ្យ និងដើម្បីឧទ្ទិសដល់ព្រលឹងជនរងគ្រោះដែលបានបាត់បង់ជីវិត។ ខ្លឹមសារពាក្យស្លោកទាំងពីរ បានរំឭកយើងអំពីទំនាក់ទំនងស៊ីជម្រៅរវាងការអប់រំ ការចងចាំ និង ប្រវត្តិសាស្ត្រ ដើម្បីធ្វើយ៉ាងណាកុំឲ្យមានអំពើប្រល័យពូជសាសន៍កើតឡើងវិញ»។

ជាមួយគ្នានេះដែរ លោក ហុង ហន នាយកវិទ្យាល័យសម្តេចចក្រី ហេង សំរិន អន្លង់ជ្រៃ បានឲ្យដឹងថា ពាក្យស្លោកនោះអាចជំរុញឲ្យសិស្សានុសិស្សបង្កើតការសន្ទនាអំពីរបបខ្មែរក្រហមនៅក្នុងគ្រួសារ និងសាលារៀន។ លោកនិយាយថា៖ «វាជាការរំឭកមួយដ៏មានសារសំខាន់ ហើយបន្តឲ្យមានចម្ងល់ និងការគិតពិចារណាចំពោះពាក្យស្លោក។ ដូចនេះ ពាក្យស្លោកទាំងពីរ អាចធ្វើឲ្យសិស្សមានគំនិតចង់ស្វែងយល់បន្ថែមដោយខ្លួនឯង អញ្ចឹងគាត់អាចសាកសួរអ្នកដែលបានឆ្លងកាត់សម័យខ្មែរក្រហមដូចជាយាយតា ឬឪពុកម្តាយជាដើម។ បន្ទាប់មក មនុស្សជំនាន់មុននិងជំនាន់ក្រោយនឹងចាប់ផ្តើមសន្ទនាអំពីអំពើប្រល័យពូជសាសន៍»។



ពាក្យស្លោកនិយាយពីរបបខ្មែរក្រហម នៅវិទ្យាល័យសម្តេចពញាចក្រី ហេង សំរិន អន្លង់ជ្រៃ

កញ្ញា ហ៊ុន សុម៉ាលី ជាសិស្សថ្នាក់ទី១២ បានឲ្យដឹងក្រោយពីការចូលរួមពិធីសម្ពោធថា៖ «ពាក្យស្លោកទាំងពីរ ធ្វើឲ្យពួកខ្ញុំជាសិស្សចង់ស្វែងយល់បន្ថែមអំពីរបបខ្មែរក្រហម។ ខ្ញុំបានសិក្សាស្វែងយល់ខ្លះដែរតាមរយៈការនិយាយប្រាប់ពីឪពុកម្តាយ និងយាយតា អំពីរឿងរ៉ាវដែលកើតឡើងនៅក្នុង

សម័យនោះ។ ដូចនេះ នៅពេលដែលខ្ញុំបានរៀននៅសាលាផង និងផ្ទះផង ធ្វើឲ្យខ្ញុំយល់កាន់តែច្បាស់អំពីរបបខ្មែរក្រហម»។

គួររំឭកថា របបខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា របបកម្ពុជាប្រជាធិបតេយ្យដឹកនាំដោយ ប៉ុល ពត (១៩៧៥ ដល់១៩៧៩) បានធ្វើឲ្យប្រជាជនប្រមាណ ២លាននាក់ស្លាប់បាត់បង់ជីវិត តាមរយៈការធ្វើការហួសកម្លាំង សម្លាប់ និងអត់អាហារ។ ខ្មែរក្រហមបានប្រែក្លាយ សាលារៀន និងវត្តអារាម ទៅជាមន្ទីរសន្តិសុខ ក្រោលគោក្របី រោងសិប្បកម្ម ជង្រុកស្រូវ និងទីតាំងសម្រាប់និងកប់មនុស្ស។

ចាប់ពីឆ្នាំ១៩៩៥ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញមន្ទីរសន្តិសុខ ឬគុក នៅក្នុងសម័យខ្មែរក្រហមចំនួន ១៩៦កន្លែង ទីតាំងសម្លាប់មនុស្សមាន ៣៨៨កន្លែង ក្នុងនោះរណ្តៅសាកសពមានចំនួនប្រមាណ២ម៉ឺនរណ្តៅ និងស្តូប ឬបូជនីយដ្ឋានចំនួន ៨១ នៅទូទាំងប្រទេសកម្ពុជា។ ថ្មីៗនេះ មជ្ឈមណ្ឌលឯកសារកម្ពុជា សហការជាមួយក្រុមហ៊ុន ស្ប៉ាវ៉ូហក ហ្វាអ៊ីស បាននិងកំពុងបន្តដំណើរការស្រាវជ្រាវទៅលើរណ្តៅសាកសពជំនាន់ខ្មែរក្រហម តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីទំនើប ក្នុងការពិនិត្យមើលឆ្អឹងសាកសពជនរងគ្រោះដែលកំពុងស្ថិតនៅក្នុងក្រោមដីក្នុងរណ្តៅដែលបានបន្សល់ទុកតាំងពីក្រោយរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។ របកគំហើញថ្មីដែលចេញមកពីកិច្ចការស្រាវជ្រាវនេះ នឹងក្លាយជាមេរៀនថ្មីបន្ថែមទៀតបញ្ចូកបន្ថែមលើមេរៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលសិស្សានុសិស្សបាននិងកំពុងសិក្សា។ ក្រៅពីនេះឯកសារជាង១លាន២សែនទំព័រ រួមជាមួយនឹងប្រវត្តិរូបជនរងគ្រោះនិងកម្មាភិបាលប្រមាណ ៣ម៉ឺននាក់ អំពីរបបខ្មែរក្រហមត្រូវបានរក្សាទុកនៅមជ្ឈមណ្ឌលនេះ។

**សន ប៊ុនស៊ីម**



សិស្សានុសិស្សវិទ្យាល័យសម្តេចពញាចក្រី ហេង សំរិន អន្លង់វែង លោកគ្រូអ្នក និងបុគ្គលិកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ថតរូបជុំគ្នា។

# ឯកអគ្គរដ្ឋទូតអ៊ីស្រាអែលប្រចាំទីក្រុងបាងកក និងទីក្រុងភ្នំពេញ លើកឡើងពីកិច្ចសហការលើកម្មវិធីអប់រំប្រវត្តិសាស្ត្រជាមួយ មជ្ឈមណ្ឌលឯកសារកម្ពុជា

ក្រោយអង្គការសហប្រជាជាតិបានបោះឆ្នោតអនុញ្ញាតឲ្យជនជាតិជ្វីព បង្កើតប្រទេសអ៊ីស្រាអែលក្នុងឆ្នាំ១៩៤៨។ ប្រទេសអ៊ីស្រាអែល បានបង្កើតទំនាក់ទំនងការទូតជាមួយបណ្តាប្រទេសផ្សេងៗជុំវិញពិភពលោក ក្នុងនោះរួមមានប្រទេសកម្ពុជាផងដែរ។ ទំនាក់ទំនងប្រទេសកម្ពុជារវាងប្រទេសអ៊ីស្រាអែលបានចាប់ផ្តើមឡើងនៅក្នុងឆ្នាំ១៩៦០។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយទំនាក់ទំនងប្រទេសកម្ពុជា និងអ៊ីស្រាអែលបានកាត់ផ្តាច់ទំនាក់ទំនងការទូតទៅវិញនៅឆ្នាំ១៩៧៥ នៅពេលដែលរបបខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជាដោយធ្វើការដណ្តើមបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ។ របបខ្មែរក្រហមបានដួលរលំនៅឆ្នាំ១៩៧៩ ប៉ុន្តែសង្គ្រាមស៊ីវិលបានបន្តរហូតដល់មានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១។

ពីរឆ្នាំក្រោយមក អង្គការសហប្រជាជាតិបានរៀបចំឲ្យមានការបោះឆ្នោតជាសកលមួយក្នុងគោលបំណងស្វែងរកសន្តិភាពជូនប្រជាជនកម្ពុជា។ ប្រទេសកម្ពុជាបានខិតខំប្រឹងប្រែង និងរឹតចំណងមិត្តភាពការទូតឡើងវិញ ជាពិសេសទំនាក់ទំនងការទូតរវាងប្រទេសកម្ពុជា និងប្រទេសអ៊ីស្រាអែល ដោយបានចាប់ផ្តើមទំនាក់ទំនងការទូតជាថ្មីម្តងទៀតបន្ទាប់ពីបោះឆ្នោតនៅឆ្នាំ១៩៩៣។ អស់រយៈពេល២៥ឆ្នាំកន្លងមក ហើយដែលកម្ពុជាបានធ្វើកិច្ចសហប្រត្តិបត្តិការយ៉ាងល្អប្រសើរជាមួយប្រទេសអ៊ីស្រាអែល ទៅលើវិស័យអប់រំ ទេសចរណ៍ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងតាមរយៈការផ្តល់អាហារូបករណ៍របស់រដ្ឋាភិបាលអ៊ីស្រាអែលផ្តល់ដល់និស្សិតកម្ពុជាទៅសិក្សានៅប្រទេសអ៊ីស្រាអែល ជាពិសេសទៅលើវិស័យកសិកម្ម បរិស្ថាន និងសុខាភិបាល។

ក្រៅពីវិស័យទាំងនេះ ប្រទេសទាំងពីរក៏បានយកចិត្តទុកដាក់ទៅលើផ្នែកប្រវត្តិសាស្ត្រដូចរបត់នៃការសម្លាប់រង្គាលទៅលើជនជាតិជ្វីព កាលពីអំឡុងសង្គ្រាមលោកលើកទី២ ដោយរបបណាហ្ស៊ី និងការសម្លាប់ប្រជាជនស្លូតត្រង់ដោយក្រុមខ្មែរក្រហម។ ដូច្នេះហើយ ទើបនៅថ្ងៃទី១៩ខែវិច្ឆិកា ឆ្នាំ២០១៨ លោក មៀ ស្លូម៉ូ (Meir Shlomo) ឯកអគ្គរដ្ឋទូតអ៊ីស្រាអែលប្រចាំប្រទេសថៃ និងកម្ពុជា រួមដំណើរដោយលោកស្រី អ៊ិតធី មីសរ៉ាជិ (Etty Mizrachi) អគ្គកុងស៊ុលអ៊ីស្រាអែលប្រចាំប្រទេសថៃ និងប្រទេសកម្ពុជាបានមកធ្វើទស្សនកិច្ចមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាកន្លែងប្រមែប្រមូល ចងក្រង បោះពុម្ព និងផ្សព្វផ្សាយធំជាងគេពីរបបខ្មែរក្រហម។ នៅក្នុងដំណើរទស្សនកិច្ចនេះ លោកឯកអគ្គរដ្ឋទូត និងលោកស្រីអគ្គកុងស៊ុលអ៊ីស្រាអែល ក៏បានទស្សនកិច្ចវិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត ដែលជាវិទ្យាស្ថានអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថានស្លឹករឹត មានតួនាទីអប់រំបណ្តុះបណ្តាយ និងលើកកម្ពស់ប្រវត្តិសាស្ត្រនិងកេរដំណែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែងដាក់បង្ហាញស្នាដៃសិល្បៈ តាមរយៈការតាំងពិព័រណ៍រូបថត ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និងការធ្វើបទបង្ហាញពីស្នាដៃស្រាវជ្រាវរបស់វាគ្មិននានា ទៅដល់សាធារណជន។ ក្នុងឱកាសនោះលោក មៀ ស្លូម៉ូ ឯកអគ្គរដ្ឋទូត និងលោកស្រី អ៊ិតធី មីសរ៉ាជិ អគ្គកុងស៊ុលអ៊ីស្រាអែល ក៏បានទស្សនាការតាំងពិព័រណ៍រូបថត ស្តីអំពីសំណល់សង្គ្រាមនៅកម្ពុជា រួមមាន រូបថតជនពិការ សំណង់អគារបាក់បែកដែលទទួលរងការបំផ្លិចបំផ្លាញដោយសារសង្គ្រាម ជាមួយនឹងព័ត៌មានខ្លីដែលបានរៀបរាប់ពីរូបថតទាំងនេះ។ បន្ទាប់មក លោក មៀ ស្លូម៉ូ និងលោកស្រី អ៊ិតធី មីសរ៉ាជិ ក៏បានទស្សនាការតាំង

ពិព័រណ៍រូបគំនូរកោដ្ឋដែលមានចំណងជើងថា «មិនទាន់ផុតរលត់» ដែលរំឭកដល់ការចងចាំ និងទស្សនាការតាំងបង្ហាញពីប្លង់គោលរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែងនិងផែនការអភិវឌ្ឍតំបន់ប្រវត្តិសាស្ត្រអន្លង់វែង ឲ្យក្លាយជាតំបន់ដែលមានសក្តានុពលលើវិស័យទេសចរណ៍ ដោយផ្តោតសំខាន់ទៅលើការផ្សះផ្សា និងសន្តិភាព។

តមក គណប្រតិភូអ៊ីស្រាអែលបានទៅទស្សនាកោដ្ឋដលែមជុឈមណុឌលឯកសារកមុពុជាបានរកឃើញនៅខាងក្រោមបល្ល័ង្កព្រះពុទ្ធរូប ក្នុងព្រះវិហារនៃវត្តលង្កា។ កោដ្ឋទាំងនេះ បានបន្សល់ទុកមុនពេលដែលខ្មែរក្រហមឡើងកាន់អំណាច និងនៅក្រោយពេលដែលរបបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ក្រោយមក កោដ្ឋទាំងនេះត្រូវបានមជ្ឈ-មណ្ឌលឯកសារកម្ពុជាប្រមែប្រមូលដើម្បីរក្សាទុកក្នុងគោលបំណងផ្សព្វផ្សាយដល់សាធារណជនទូទៅឲ្យបានដឹង និងអ្នកដែលកំពុងស្វែងរកសាច់ញាតិ បងប្អូនរបស់ខ្លួន។ កោដ្ឋទាំងនេះមានចំនួនសរុប៤៦៤ ត្រូវបានបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជារៀបរៀងជាបញ្ជីឈ្មោះ និងចុះលេខកូដសម្គាល់ដើម្បីងាយស្រួយក្នុងការស្វែងរកអត្តសញ្ញាណ។ នៅក្នុងដំណើរទស្សនកិច្ចកោដ្ឋនៅវត្តលង្កា គណប្រតិភូអ៊ីស្រាអែលក៏បានស្វែងយល់អំពីប្រពៃណី វប្បធម៌ខ្មែរក្នុងការបូជាសពតាមព្រះពុទ្ធសាសនាពីព្រះសង្ឃដែរ។

បន្ទាប់មក គណប្រតិភូអ៊ីស្រាអែល បានជួបជាមួយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោក ឆាំង យុ បានស្វាគមន៍ចំពោះគណប្រតិភូអ៊ីស្រាអែល ដែលមានបំណងសហការលើកម្មវិធីអប់រំប្រវត្តិសាស្ត្រនៃប្រទេសទាំងពីរ រួមមាន ៖ អំពើប្រល័យពូជសាសន៍ ហូឡូខូសត៍ ដែលធ្វើឲ្យជនជាតិជ្វីពបាត់បង់ជីវិតប្រមាណ៦លាននាក់ក្នុងអំឡុងសង្គ្រាមលោកលើកទី២(១៩៣៩-១៩៤៥)និងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-៩១៧៩) ដែលបានធ្វើឲ្យប្រ-ជាជនស្លូតត្រង់បាត់បង់ជីវិតប្រមាណជា៣លាននាក់។ អំពើសាហាវយង់ឃ្នង់ដែលបានកើតឡើងធ្វើឲ្យមនុស្សជាតិបាត់បង់អាយុជីវិតព្រមទាំង បានជំរុញឲ្យមានការចង់ចាំ និងការផ្សះផ្សា វាក៏ជាមេរៀនដែលប្រទេសទាំងពីរគួរតែរៀនអំពីគ្នាទៅវិញទៅមកដើម្បីថវែក្សាសន្តិភាពក្នុងពិភពលោក។

**ដារ៉ារដ្ឋ មេត្តា**


លោក មៀ ស្វូម៉ូ ឯកអគ្គរដ្ឋទូត និងលោកស្រី អ៊ិតធី មីសរ៉ាជិ អគ្គកុងស៊ុលអ៊ីស្រាអែលប្រចាំប្រទេសថៃ និង ប្រទេសកម្ពុជា ទស្សនាសាលសិល្បសហសម័យ

# ដំណឹងជ្រើសរើសអ្នកស្រាវជ្រាវ

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសអ្នកស្រាវជ្រាវដែលគ្រូបង្រៀន ឬអតីតគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យាចំនួន២០នាក់ ឲ្យចូលរួមក្នុងការសរសេរសំណេរ«ប្រវត្តិសាស្ត្រចេញពីភូមិ» ទាក់ទងនឹងព្រឹត្តិការណ៍នៅក្នុងរបបខ្មែរក្រហម ចេញពីភូមិឃុំដែលខ្លួនកំពុង ឬធ្លាប់បំពេញភារកិច្ចជាគ្រូបង្រៀន។ កិច្ចការនេះ ជាកិច្ចការស្ម័គ្រចិត្តនៅក្នុងគម្រោងស្តីអំពី «ប្រវត្តិសាស្ត្រភូមិ» ហើយក៏ជាដំណាក់កាលទី២នៃការអនុវត្តកិច្ចការនេះដែរ។ សំណេររបស់អ្នកស្រាវជ្រាវ នឹងត្រូវបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា រួចប្រគល់ជូនវិញដើម្បីប្រើប្រាស់ជាសម្ភារឧបទ្ទេសក្នុងការបង្រៀន ឬប្រើប្រាស់ផ្ទាល់ខ្លួន។ មជ្ឈមណ្ឌលឯកសារកម្ពុជា ឧបត្ថម្ភជាថវិកាសម្រាប់ការស្រាវជ្រាវនេះ។

   

***លក្ខខណ្ឌជ្រើសរើស***

១) អ្នកស្រាវជ្រាវ ត្រូវតែជាអតីត ឬគ្រូបង្រៀនឯកទេសប្រវត្តិវិទ្យានៅក្នុងខេត្តព្រៃវែង, ស្វាយរៀង, ត្បូងឃ្មុំ, កណ្ដាល (ស្រុកមុខកំពូល, ល្វាឯម និងខ្សាច់កណ្ដាល) និងក្រចេះ (ស្រុកឆ្លូង) ដែលមិនជាប់តួនាទីជានាយកឬនាយករងនៃវិទ្យាល័យ ឬការងារដ៏ទៃទៀតដែលខ្លួនកំពុងធ្វើការ។

២) មានចំណេះដឹងអំពីវិធីសាស្ត្រក្នុងការធ្វើកិច្ចការស្រាវជ្រាវដូចជា ការធ្វើបទសម្ភាសន៍ទំនាក់ទំនងជាមួយអ្នកដែលត្រូវសម្ភាសន៍ វិភាគលើទិន្នន័យដើម និងសរសេរ។

៣) មានចំណេះដឹងសមរម្យក្នុងការប្រើប្រាស់កុំព្យូទ័រលើកម្មវិធី Microsoft Word & Excel និងមានកុំព្យូទ័រផ្ទាល់ខ្លួនដើម្បីធ្វើកិច្ចការនេះ។

៤) មានការប្ដេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចឲ្យបាននូវសំណេរតាមការកំណត់។

៥) មានភាពច្នៃប្រឌិតចំពោះការប្រើប្រាស់ឧបករណ៍ (ថតសំឡេង និងម៉ាស៊ីនថត) សម្រាប់កិច្ចការស្រាវជ្រាវ។

៦) មានសមត្ថភាពទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន។

***លក្ខខណ្ឌការងារ***

១) ធ្វើកិច្ចការស្រាវជ្រាវដោយមិនឲ្យប៉ះពាល់ដល់ម៉ោងបង្រៀនសិស្សនៅតាមវិទ្យាល័យដែលខ្លួនកំពុងបង្រៀន។

២) ប្រើប្រាស់ពេលវិស្សមកាល ឬពេលទំនេរពីការបង្រៀន ដើម្បីធ្វើកិច្ចការនេះ។

៣) បែងចែកពេលវេលាច្បាស់លាស់ពីដំណើរការប្រព្រឹត្តទៅនៃកិច្ចការស្រាវជ្រាវ រួចផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីការសហការ។ ឧទាហរណ៍៖ បង្ហាញគម្រោងផែនការជាដំណាក់កាលៗដូចជា៖ ប្រមូលធនធានសម្រាប់ ឯកសារយោង, កំណត់គោលដៅសម្រាប់សម្ភាសន៍, ការសម្ភាសន៍, វិភាគទិន្នន័យសម្ភាសន៍ និងសំណេរ។

៤) សរសេរកិច្ចការស្រាវជ្រាវឲ្យបានយ៉ាងហោចណាស់២០ទំព័រ។

៥) ផ្ញើសំណេរ និងកិច្ចសម្ភាសន៍ជាសំឡេងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីរក្សាទុក និងងាយស្រួលក្នុងការពិនិត្យផ្ទៀងផ្ទាត់ និងបោះពុម្ព។

ប្រសិនបើលោកគ្រូអ្នកគ្រូ និងប្រិយមិត្តដ៏ទៃទៀតមានការចាប់អារម្មណ៍លើកិច្ចការនេះ សូមដាក់ពាក្យស្នើសុំមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយភ្ជាប់មកជាមួយនូវ ៖ ១) ពាក្យស្នើសុំធ្វើកិច្ចការស្រាវជ្រាវប្រវត្តិភូមិ។ ២) ប្រវត្តិរូបសង្ខេប១ច្បាប់ និង ៣) សេចក្តីអធិប្បាយត្រួសៗពីប្រធានបទដែលចង់សរសេរ តាមអាសយដ្ឋាន ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬផ្ញើមកកាន់អ៊ីមែល៖ truthrasy.p@dccam.org។ ការទទួលពាក្យផុតកំណត់ត្រឹម ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៨។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកកាន់ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីស្រាវជ្រាវ និងអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា តាមទូរសព្ទ៖ ០១២ ៦៩៦៩៦១ ឬអ៊ីមែល៖ truthrasy.p@dccam.org ។

# នួន ជា និង ខៀវ សំផន ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ បានចេញសាលក្រមសម្រេចផ្តន្ទាទោស នួន ជា អតីតប្រធានសភាជាតិនៃរបបកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥-១៩៧៩) និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំផន អតីតប្រមុខរដ្ឋ (ប្រធានគណៈប្រធានរដ្ឋ) នៃរបបកម្ពុជាប្រជាធិប-តេយ្យឲ្យជាប់គុកអស់មួយជីវិត ។

### *សាវតារនៃសំណុំរឿង*

នួន ជា ត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចចាប់ឃុំខ្លួនបណ្តោះអាសន្នកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧។ ចំណែក ខៀវ សំផន ត្រូវបានចាប់ខ្លួននៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ជាមួយបទចោទប្រកាន់សំខាន់ៗដូចខាងក្រោម៖

- ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ៖ មនុស្សឃាត ការសម្លាប់ផ្តាច់ពូជ ការដាក់ក្នុងមន្ទីរ ឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត។
- ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍៖ ការសម្លាប់រង្គាលក្រុមជនជាតិវៀតណាម និងចាម។
- ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩៖ មនុស្សឃាតដោយចេតនា ការធ្វើទារុណកម្មឬការប្រព្រឹត្តអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រូបរាងកាយឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ក្តីដោយយុត្តិធម៌ ការបង្ខាំង និងការនិរទេសជនស៊ីវិលដោយខុសច្បាប់។
- អំពើមនុស្សឃាត៖ ការធ្វើទារុណកម្ម និងការធ្វើទុក្ខបុកម្នេញខាងផ្នែកសាសនា ដូច មានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦។

នួន ជា និង ខៀវ សំផន បានក្លាយជាជនជាប់ចោទក្នុងសំណុំរឿង០០២ ជាមួយនឹងមេដឹកនាំខ្មែរក្រហមពីររូបផ្សេងទៀតគឺ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា) និង អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច។ ប៉ុន្តែដោយសារតែជនជាប់ចោទ២រូបគឺ អៀង សារី និង អៀង ធីរិទ្ធ បានស្លាប់មុនពេលកាត់ទោស ទើបសំណុំរឿង០០២នេះ នៅសល់តែជនជាប់ចោទតែពីររូបប៉ុណ្ណោះគឺ នួន ជា និង ខៀវ សំផន។

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការបឋមលើសំណុំរឿង នួន ជា និង ខៀវ សំផន នៅខែមិថុនា ឆ្នាំ២០១១ ហើយមិនយូរប៉ុន្មានសំណុំរឿង០០២ ក៏ត្រូវបានបំបែកជាសំណុំរឿងពីរផ្សេងគ្នា គឺសំណុំរឿង០០២/០១ និង០០២/០២។ ការបំបែកសំណុំរឿង០០២នេះ ពីព្រោះតែទំហំ និងបញ្ហាស្មុគស្មាញនៃដីកាដំណោះស្រាយ និងវ័យចាស់ជរារបស់ជនជាប់ចោទ។

សំណុំរឿង០០២/០១ ត្រូវបានចាប់ផ្តើមបើកសវនាការនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ដោយមានជនជាប់ចោទតែ

២រូបគឺ នួន ជា និង ខៀវ សំផនៗ សំណុំរឿងនេះបានផ្តោតទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំឲ្យចាកចេញពីទីក្រុងភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥ និងការផ្លាស់ទីលំនៅដំណាក់កាលទី២ ក្នុងតំបន់ផ្សេងៗទៀតចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ៗ

នៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ នួន ជា និង ខៀវ សំផន ត្រូវបានអង្គជម្រះសាលាដំបូងរកឃើញថា មានពិរុទ្ធភាពចំពោះបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតៗ

ចំណែកសវនាការជំនុំជម្រះលើសំណុំរឿង០០២/០២ បានចាប់ផ្តើមនៅថ្ងៃទី១៧ខែតុលា ឆ្នាំ២០១៤ៗ សំណុំរឿង ០០២/០២ សំដៅលើការជំនុំជម្រះដំណាក់កាលទី២ ប្រឆាំងនឹង នួន ជា និង ខៀវ សំផន ដែលត្រូវជំនុំជម្រះទៅលើបទចោទប្រកាន់ចំនួន៨ករណីបន្ថែមទៀតលើសំណុំរឿង០០២ៗ នៅក្នុងសេចក្តីប្រកាសមួយកាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មានទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុដូចខាងក្រោម ដែលនឹងបង្កើតបានជាមូលដ្ឋានសម្រាប់សំណុំរឿង០០២/០២ៈ

- អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាមៗ
- ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ (នៅទូទាំងប្រទេស)ៗ
- ការបោសសម្អាតផ្ទៃក្នុងៗ
- មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោលៗ
- ការដ្ឋានសាងសង់ទំនប់ ១ មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានលើកទំនប់ត្រពាំងថ្មៗ
- សហករណ៍ត្រាំកក់ៗ

ការប្រព្រឹត្តមកលើពុទ្ធសាសនិកជន (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និងការកំណត់គោលដៅមកលើអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តនេះត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានសាងសង់ទំនប់ ១ មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ប៉ុណ្ណោះ)ៗ

បន្ទាប់ពីចំណាយពេលប្រហែល៤ឆ្នាំ ក្នុងការជំនុំជម្រះលើសំណុំរឿង០០២/០២ ដែលសំដៅទៅលើការជំនុំជម្រះដំណាក់កាលទី២ប្រឆាំងនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នេះបានប្រកាសសាលក្រមសម្រាប់សំណុំរឿង០០២/០២ ដោយអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា នួន ជា ត្រូវតែទទួលខុសត្រូវក្នុងនាមជាអ្នកដឹកនាំម្នាក់នៅក្នុងរបបខ្មែរក្រហម ដែលបានប្រព្រឹត្តតាមគោលនយោបាយឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្ត ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង០០២/០២ៗ នួន ជា ត្រូវបានអង្គជំនុំជម្រះសាលាដំបូងនៃតុលាការខ្មែរក្រហមរកឃើញថាមានពិរុទ្ធចំពោះបទចោទចំនួន៣ក្នុងចំណោមបទចោទទាំង៨ គឺ ១)ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ២)ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និង៣)ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ៗ ចំណែក ខៀវ សំផន ត្រូវបានអង្គជំនុំជម្រះសាលាដំបូងដាក់ឲ្យទទួលខុសត្រូវតាមរយៈការប្រព្រឹត្តសហឧក្រិដ្ឋរួម រួមមានៈ ១) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ២) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង៣) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ៗ

ដូច្នេះអង្គជំនុំជម្រះសម្រេចផ្តន្ទាទោស នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិតៗ ដោយពិចារណាទៅលើការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះ នួន ជា និង ខៀវ សំផន នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលនូវការផ្តន្ទាទោសទាំងពីរទៅជាការផ្តន្ទាទោស ដាក់ពន្ធនាគារអស់មួយជីវិតតែមួយៗ

សោម ប៊ុនថន

# ការបន្ថែមបទចោទទៅលើ នួន ជា និង ខៀវ សំផន ក្នុងសាលក្រម សំណុំរឿង០០២/២ ជាការបន្ថែមយុត្តិធម៌ដល់ជនរងគ្រោះ

នួន ជា អតីតប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំផន អតីតប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ជនជាប់ចោទទាំងពីរត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម។ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការបឋមនៅខែមិថុនា ឆ្នាំ២០១១។ ចាប់ពីពេលនោះមក យ៉ាងហោចណាស់ក៏សំណុំរឿង០០២ ត្រូវបានបំបែកទៅជាសវនាការដាច់ដោយឡែកពីគ្នា ដែលសវនាការនីមួយៗ ដោះស្រាយផ្នែកផ្សេងគ្នានៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

### សំណុំរឿង ០០២/០១៖

ការជំនុំជម្រះដំណាក់កាលទីមួយ (សំណុំរឿង០០២/០១) ត្រូវបានចាប់ផ្តើមនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលផ្តោតជាចម្បងទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងតំបន់ផ្សេងៗ (ដំណាក់កាលទីមួយ និងទីពីរ) និងការសម្លាប់ទាហាន លន់ នល់ នៅទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ បន្ទាប់ពីខ្មែរក្រហមឡើងកាន់អំណាចក្នុងឆ្នាំ១៩៧៥។

អង្គជំនុំជម្រះសាលាដំបូង ក៏ពិចារណាទៅលើតួនាទីរបស់ជនជាប់ចោទទាក់ទិនគោលនយោបាយ ដាប់ពាក់ព័ន្ធនឹងបទចោទទាំងអស់ ដែលជាមូលដ្ឋានសម្រាប់ការពិនិត្យទៅលើបទចោទសេសសល់ទាំងអស់នៅក្នុងសវនាការនាពេលខាងមុខ។ សវនាការសួរដេញដោលលើភស្តុតាងក្នុងសំណុំរឿង០០២/០១ ត្រូវបានបញ្ចប់នៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ ហើយសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលត្រូវបានបញ្ចប់នៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។

សាលក្រមសាលាដំបូង ត្រូវបានប្រកាសនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤។ នួន ជា និង ខៀវ សំផន ត្រូវបានតុលាការរកឃើញថា មានពិរុទ្ធភាពចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។ ជនជាប់ចោទទាំងពីរនាក់ បាននិយាយថា ពួកគាត់នឹងប្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនេះ។

### សំណុំរឿង ០០២/០២៖

សំណុំរឿង០០២/០២ គឺសំដៅលើការជំនុំជម្រះដំណាក់កាលទីពីរប្រឆាំងនឹង ខៀវ សំផន និង នួន ជា ដែលនឹងត្រូវជំនុំជម្រះទៅលើបទចោទបន្ថែមទៀត ពីដីកាដំណោះស្រាយក្នុងសំណុំរឿង ០០២។ នៅក្នុងសេចក្តីសម្រេចមួយកាលពីថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់ផ្នែកអង្គហេតុខាងក្រោមនេះ នឹងបង្កើតបានជាមូលដ្ឋានសម្រាប់សំណុំរឿង ០០២/០២៖

- អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម និងជនជាតិវៀតណាម (ដោយមិនរាប់បញ្ចូលនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលប្រព្រឹត្តឡើងដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើដែនដីវៀតណាមនោះឡើយ)។
- ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនិងការរំលោភសេពសន្ថវៈ (នៅទូទាំងប្រទេស)។
- ការបោសសម្អាតផ្ទៃក្នុង។
- មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

- ការដ្ឋានសាងសង់ទំនប់ ១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង និងការដ្ឋានលើកទំនប់ត្រពាំងថ្ម។
- សហករណ៍ត្រាំកក់
- ការប្រព្រឹត្តមកលើពុទ្ធសាសនិកជន (កម្រិតត្រឹមតែសហករណ៍ត្រាំកក់) និង
- ការកំណត់គោលដៅមកលើអតីតមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ (ការអនុវត្តនេះត្រូវបានកម្រិតត្រឹមតែសហករណ៍ត្រាំកក់ ការដ្ឋានសាងសង់ទំនប់ ១មករា មន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់)។

សវនាការលើអង្គសេចក្តីក្នុងសំណុំរឿង០០២/០២ បានចាប់ផ្តើមនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤។ ការបង្ហាញភស្តុតាងបានចាប់ផ្តើមនៅថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ និងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ សេចក្តីប្រកាសបិទបញ្ចប់ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៧។ សាលក្រមសំណុំរឿង ០០២/០២ ត្រូវបានរំពឹងទុកនៅក្នុងត្រីមាសទី២ ឆ្នាំ២០១៨។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាកម្ពុជា(អ.វ.ត.ក.) បានចេញដីកាកំណត់កាលបរិច្ឆេទប្រកាសសាលក្រម នៅក្នុងសំណុំរឿង០០២/០២ ដោយបានជូនដំណឹងដល់ភាគីនានាថា អនុលោមតាមវិធាន ១០២ (១) នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះសាលាដំបូងនឹងប្រកាសសេចក្តីសង្ខេបហេតុ និងផ្នែកនៃសេចក្តីសម្រេចនៃសាលក្រមក្នុងសំណុំរឿង ០០២/០២ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន នៅថ្ងៃសុក្រ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅក្នុងសវនាការធំនៃ អ.វ.ត.ក. ចាប់ពីម៉ោង ០៩:៣០ នាទីព្រឹក។

សវនាការដេញដោលពិនិត្យភស្តុតាងសំណុំរឿង០០២/០២ បានចាប់ផ្តើមដោយការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ និងបានបញ្ចប់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៧។ ការជំនុំជម្រះរួមទាំងការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលផង មានរយៈពេលសរុបចំនួន២៨៣ថ្ងៃ។ ក្នុងអំឡុងពេលសវនាការនេះ អង្គជំនុំជម្រះសាលាដំបូង បានស្តាប់សក្ខីកម្មពីបុគ្គលសរុបចំនួន ១៨៥នាក់ ក្នុងនោះមានសាក្សីបញ្ជាក់អង្គហេតុចំនួន១១៤ នាក់ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦៣នាក់ និងអ្នកជំនាញចំនួន៨នាក់។ សវនាការនេះមានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសាធារណជន ដោយមានសាធារណជនចូលរួមស្តាប់ និងតាមដានសវនាការនេះដោយផ្ទាល់ សរុបចំនួន ៨២,៧៨០ នាក់។

ជនជាប់ចោទដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ មាន នួន ជា ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និង ខៀវ សំ ផន ជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ។ បទចោទនៅក្នុងសំណុំរឿង០០២/០២ គឺឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អំពើប្រល័យពូជសាសន៍ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្ម និងការចោទប្រកាន់លើអង្គហេតុដូចតទៅៈ ការដ្ឋានការងារ និងសហករណ៍ត្រាំកក់ ការដ្ឋានទំនប់ត្រពាំងថ្ម ការដ្ឋានទំនប់ ១មករា និងការដ្ឋានសាងសង់ព្រលានយន្ត



កង ខាត់ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ហោះកំពង់ឆ្នាំង មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស (មន្ទីរសន្តិសុខ ស-២១ មន្ទីរសន្តិក្រាំងតាចាន់ មន្ទីរសន្តិអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល) អំពើប្រល័យពូជសាសន៍ទៅលើប្រជាជនចាម និងវៀតណាម ការប្រព្រឹត្តពុទ្ធសាសនិកជន និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងការរៀបអាពាហ៍ពិពាហ៍នៅទូទាំងប្រទេស។ អង្គជំនុំជម្រះក៏បានបើកសវនាការដេញដោលពិនិត្យភ័ស្តុតាងលើការចោទប្រកាន់អំពីលក្ខណៈនៃជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម តួនាទីរបស់ជាប់ចោទនៅក្នុងរដ្ឋាភិបាល រួមទាំងភ័ស្តុតាងស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានពិរុទ្ធដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដូចដែលបានរៀបរាប់ដោយសង្ខេបខាងលើ និងដោយលម្អិតនៅក្នុងសាលក្រមជាលាយលក្ខណ៍អក្សរ តាមរយៈអំពើសកម្ម និងអកម្មចំពោះឧក្រិដ្ឋកម្មទាំងឡាយដូចខាងក្រោម ៖

១) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមរយៈការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ អនុលោមតាមបទបញ្ញត្តិមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

២) ការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើ



សាធារណជនចូលរួមស្តាប់ការប្រកាសសាលក្រមរបស់ នួន ជា និង ខៀវ សំផន នៅសាលសវនាការនៃសាលាក្តីខ្មែរក្រហម នៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨។

ទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ខុសច្បាប់ អនុលោមតាមមាត្រា ៦ មាត្រា ២៩(ថ្មី) និង មាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.។

៣) ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិវៀតណាម និងជនជាតិចាម អនុលោមតាមមាត្រា ៤ មាត្រា ២៩(ថ្មី) និង មាត្រា ៣៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

អង្គជំនុំជម្រះបានពិចារណាទៅលើភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម រួមទាំងទំហំ និងភាពសាហាវព្រៃផ្សៃ ក៏ដូចជាចំនួន និងភាពទន់ខ្សោយរបស់ជនរងគ្រោះ ដែលជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធរួមទាំងស្ថានទម្ងន់ទោសនានាដែលពាក់ព័ន្ធ។ អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទ នួន ជា ដាក់ពន្ធនាគារអស់មួយជីវិត។ ដោយពិចារណាទៅលើការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតចំពោះគាត់ នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរ ទៅជាការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតែមួយ។

អង្គជំនុំជម្រះសម្រេចផ្តន្ទាទោស ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិត។ ដោយពិចារណាទៅលើការផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ចំពោះគាត់នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះរួមបញ្ចូលគ្នានូវការផ្តន្ទាទោសទាំងពីរ ទៅជាផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិតតែមួយ។

ខាងក្រោមនេះ ជាការយល់ឃើញពីសាធារណជនដែលចូលរួមស្តាប់ការប្រកាសសាលក្រមក្នុងសំណុំរឿង០០២/០២ របស់អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ៖

កង ខាត់ អាយុ ៧៦ឆ្នាំ មកពីខេត្តកំពង់ស្ពឺ បានរៀបរាប់ថា «សម្រាប់ខ្ញុំដែលជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះកម្ពុជាដទៃទៀតនៃរបបខ្មែរក្រហម ខ្ញុំពិតជាពេញចិត្តចំពោះអង្គសវនាការនៅថ្ងៃនេះខ្លាំងណាស់ ដែលបានរកឃើញពីបទឧក្រិដ្ឋកម្មបន្ថែមទៀត ទៅលើជនជាប់ចោទទាំងពីរ រួមមាន នួន ជា និង ខៀវ សំផន។ សាលក្រមនេះបានជួយបំពេញបន្ថែមនៃយុត្តិធម៌ដល់ជនរងគ្រោះកម្ពុជាជាច្រើនលាននាក់ ដែលបានបាត់បង់សមាជិកគ្រួសារក្នុងអំឡុងពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាច។ ក្នុងនោះដែរ ក៏មានសាច់ញាតិខ្ញុំមួយចំនួន ដែលបានបាត់ខ្លួននៅក្នុងរបបខ្មែរក្រហម រួមមាន បងស្រីពីរនាក់ ប្អូនថ្លៃម្នាក់ កូនស្រីម្នាក់ និងក្មួយៗជាច្រើននាក់ផ្សេងទៀត។ នៅថ្ងៃនេះ ខ្ញុំពិតជាសប្បាយរីករាយខ្លាំងណាស់ ដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់យុត្តិធម៌ដល់ខ្លួនខ្ញុំផ្ទាល់ ក៏ដូចជាជនរងគ្រោះដទៃទៀត។

ស៊ិន ម៉ូត អាយុ៧០ឆ្នាំ មកពីខេត្តកំពង់ចាម បានបញ្ចេញនូវមតិផ្ទាល់ខ្លួនថា «សម្រាប់អង្គសវនាការដែលបានប្រកាសសាលក្រមនៅថ្ងៃនេះ គឺពិតជាមានសារសំខាន់ខ្លាំងណាស់ ដល់ជនរងគ្រោះកម្ពុជាដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម ជាពិសេសជនរងគ្រោះដែលបានបាត់បង់សាច់ញាតិបងប្អូននៅក្នុងអំឡុងរបបខ្មែរក្រហម។ សាលក្រមនៅថ្ងៃនេះ បានផ្តល់យុត្តិធម៌បន្ថែមទៀតទៅដល់ជនរងគ្រោះដែលបានរកឃើញពីបទឧក្រិដ្ឋកម្មបន្ថែមទៀត ទៅលើជនជាប់ចោទទាំងពីរនាក់។ ក្នុងនោះ ក៏មានរូបខ្ញុំម្នាក់ផងដែរដែលទទួលបានយុត្តិធម៌ពីសវនាការនៅថ្ងៃនេះ ពីព្រោះខ្ញុំក៏ជាជនរងគ្រោះម្នាក់ ដែលបានបាត់បង់សមាជិកគ្រួសារស្ទើរតែទាំងអស់នៅអំឡុងពេលដែលខ្មែរក្រហមកាន់អំណាច។ ខ្ញុំមានសមាជិកគ្រួសារប្រាំបីនាក់ ប៉ុន្តែត្រូវបានខ្មែរក្រហមយកទៅសម្លាប់ចោលអស់ប្រាំមួយនាក់ ដោយមិនដឹងពីមូលហេតុ។ ទោះជាយ៉ាងនេះក្តី ក៏ខ្ញុំពេញចិត្តនឹងអង្គជំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានជួយរកយុត្តិធម៌ដល់រូបខ្ញុំ ក៏ដូចជាជនរងគ្រោះផ្សេងទៀត។

*ហូ ជុនា*

# ដំណើរការនីតិវិធីរបស់សាលាក្តីខ្មែរក្រហមលើសំណុំរឿង អោ អាន

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្តីខ្មែរក្រហម

(តពីលេខមុន)

*ខ្លឹមសារសង្ខេបនៃដីកាដំណោះស្រាយ ក្នុងសំណុំរឿង ០០៤/២ (លើកលែងចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ ៖*

សហព្រះរាជអាជ្ញាអន្តរជាតិ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង ដីកា សន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម បានចោទប្រកាន់ អោ អាន ពាក់ព័ន្ធនឹងអង្គហេតុមួយចំនួនដូចជា ៖ ការបោសសម្អាតនៅភូមិភាគកណ្តាល មន្ទីរសន្តិសុខវត្តអូរត្រកួន មន្ទីរសន្តិសុខវត្ត បាធាយ មន្ទីរសន្តិសុខមិត្តសុប (គរ) ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ អំពើប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម និងការរៀបការដោយបង្ខំក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) បានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើ អោ អាន ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋកម្មចំនួន ១០ (ដប់)។ ក្នុងដំណើរនៃការស៊ើបសួរ ស.ច.ស.អ បានសម្រេចកាត់បន្ថយនូវទីតាំងបទឧក្រិដ្ឋកម្មមួយចំនួន ចេញពីវិសាលភាពនៃការស៊ើបសួរ។

អនុលោមតាមយុត្តិសាស្ត្ររបស់អង្គវិនិច្ឆ័យនៃ អ.វ.ត.ក និងដើម្បីធានានូវឯកភាព គតិយុត្តិ (unifor-mity of juris-prudence) សហចៅក្រមស៊ើបអង្កេតជាតិ (ស.ច.ស.ជ) បានពិចារណា មើលនូវភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋ និងការចូលរួមរបស់ជនជាប់ចោទ ព្រមទាំងកត្តាដទៃទៀត ដូចជាតម្រូវការនៃការបកស្រាយច្បាប់ព្រហ្មទណ្ឌបែបតឹងរ៉ឹង បរិបទនៃការសម្រេចចិត្ត និងវចនាសម្ព័ន្ធដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងចេតនារបស់អ្នករៀបចំកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដើម្បីសម្រេច ថា តើ អោ អាន ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬទេ។

បន្ថែមពីលើនេះ ដោយសារមានការទទួលស្គាល់ជាទូទៅថា បទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានសភាពធ្ងន់ធ្ងរ ក្នុងវិសាលភាពលាតសន្ធឹងទូទាំងប្រទេស មានការចូលរួមដោយអ្នកប្រព្រឹត្តជាកម្មាភិបាលច្រើននាក់ ដូច្នេះការសម្រេចថា បុគ្គល ណាមួយស្ថិតក្នុងយុត្តាធិការបែបជ្រើសរើស ក៏តម្រូវផងដែរឲ្យមានការប្រៀបធៀបការចូលរួមរវាងជនសង្ស័យ។ ការប្រៀបធៀបនេះ មិនត្រូវបានហាមឃាត់ដោយក្របខណ្ឌច្បាប់នៃ អ.វ.ត.ក ទេ និងធ្លាប់ត្រូវបានធ្វើឡើងដោយអង្គវិនិច្ឆ័យរបស់ អ.វ.ត.ក ព្រមទាំង វាក៏ជាឆន្ទានុសិទ្ធិរបស់ ស.ច.ស ផងដែរ។

ភស្តុតាង បង្កើតឡើងតាមរយៈការស៊ើបអង្កេត បានបង្ហាញអំពីអត្ថិភាពនៃការកាប់សម្លាប់ ការបង្អត់អាហារ ពលកម្មដោយបង្ខំ អនុលោមតាមគោលនយោបាយរបស់របបកម្ពុជាប្រជាធិបតេយ្យ។ ជនរងគ្រោះដែលត្រូវបានរកឃើញពាក់ព័ន្ធនឹងអំពើរបស់ អោ អាន ផ្ទាល់មានចំនួនតិចខុសឆ្ងាយពីអ្វីដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានចោទក្នុងដីកាសន្និដ្ឋាន បញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បន្ថែមពីលើនេះ ភស្តុតាងពាក់ព័ន្ធមិនបានបង្ហាញជាក់លាក់ នូវចំនួនមនុស្សដែលបានស្លាប់ ឬត្រូវបានសម្លាប់ក្នុងក្របខណ្ឌនៃវិសុទ្ធកម្ម មុនឬក្រោយពេល អោ អាន បានទៅដល់ភូមិភាគកណ្តាលទេ។ តាមគោលការណ៍ in dubio pro reo ភាពមន្ទិលនេះ គួរត្រូវបានជាប្រយោជន៍របស់ជនត្រូវចោទ។

មានភស្តុតាងតិចតួចបង្ហាញថា អោ អាន ជាអនុលេខា

ភូមិភាគកណ្តាល។ ក៏ប៉ុន្តែ មានភស្តុតាងជាច្រើនគាំទ្រថា អោ អាន ជាលេខាតំបន់៤១ នៃភូមិភាគកណ្តាល។ ទោះបីជាយ៉ាងនេះក្តី មិនមានឯកសារជាផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យបញ្ជាក់អំពីតំណែងទាំងពីរនេះទេ ហើយ អោ អាន បានទទួលតួនាទីទាំងនេះ ជាពិសេស តួនាទីជាអនុលេខា ក្នុងអំឡុងពេលប្រហែលមួយឆ្នាំ ឬអាចតិចជាងនេះ នាដំណាក់កាលចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អោ អាន មិនមែនជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស ដែលជាស្ថាប័នកំពូលនៃរបប និងមិនមែនជាលេខាតំបន់ស្វយ័ត។ ដូចនេះ គាត់មិនមានសិទ្ធិ និងអំណាចសម្រេចទូលំទូលាយ ព្រមទាំងអាចទាក់ទងផ្ទាល់ជាមួយនឹងគណៈកម្មាធិការមជ្ឈិម ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមាន សមាជិក ដូចជា ប៉ុល ពត នួន ជា ឬ សុន សេន នោះទេ។

ភស្តុតាង មិនបានបង្ហាញអំពីអំណាច ឬការទទួលខុសត្រូវដែល អោ អាន មានក្នុងតួនាទីជាអនុលេខាភូមិភាគកណ្តាលនោះទេ។ ផ្ទុយទៅវិញ មានភស្តុតាងជាច្រើនអះអាងថា អោ អាន គ្មានអំណាចចាត់ចែងកិច្ចការក្នុងភូមិភាគកណ្តាល។ កែ ពក ជាលេខាភូមិភាគ ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស មានអំណាច និងឥទ្ធិពល គ្រប់គ្រងការងារភូមិភាគ ប្រកបដោយប្រសិទ្ធភាព ទោះបីក្នុងអំឡុងពេលដែលគាត់អវត្តមានពីភូមិភាគកណ្តាលម្តងម្កាល ដោយសារ បេសកកម្មបំពេញការងារដទៃទៀត ដែលបក្សបានប្រគល់ជូនក្នុងឋានៈគាត់ជាមេដឹកនាំជាន់ខ្ពស់មួយរូប។ បន្ថែមពីលើនេះ ក្នុងពេលអវត្តមានដ៏កម្រពីភូមិភាគ ប្រធានមន្ទីរភូមិភាគ បានជំនួសការងាររបស់គាត់។

ភស្តុតាងជាសក្ខីកម្មរបស់សាក្សី បានបង្ហាញថា ក្នុងនាមជាលេខាតំបន់៤១ គ្រប់គ្រងលើ ស្រុកចំនួន៥ អោ អាន បានចូលរួមដឹកនាំប្រជុំផ្សព្វផ្សាយគោលនយោបាយរបស់បក្ស ចុះពិនិត្យការដ្ឋានការងារក្នុងសមត្ថកិច្ចរបស់គាត់។ បន្ថែមពីលើនេះ មានភស្តុតាងតិចតួច បង្ហាញផងដែរ នូវការពាក់ព័ន្ធរបស់ អោ អាន ក្នុងការបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់។ សហចៅក្រមស៊ើប អង្កេតជាតិ (ស.ច.ស.ជ) បានរកឃើញសកម្មភាពសម្របសម្រួលរបស់ អោ អាន លើការបង្ក្រាបលើជនជាតិចាម និងការរៀបការដោយបង្ខំ។ ជាចុងក្រោយ ស.ច.ស.ជមិនបានរកឃើញនូវភស្តុតាងដែលបង្ហាញថា អោ អាន មានគំនិត ឬការផ្តួចផ្តើម ជំរុញសកម្មភាព ហួសពីតួនាទី



អោ អាន

ឬអំណាចធម្មតាក្នុងឋានៈជាលេខាតំបន់ដែលគាត់មាន។

ការចូលរួមរបស់ អោ អាន មានឡើងនៅក្នុងបរិបទនៃវិសុទ្ធកម្ម ក្នុងទីតាំងភូមិសាស្ត្រមានកម្រិត ក្នុងរយៈពេលកំណត់មួយ ក្នុងទម្រង់នៃការប្រព្រឹត្តស្រដៀងគ្នាទូទាំងប្រទេស ដូចជា ការចាប់ខ្លួន ឃុំឃាំង សួរចម្លើយ និងការងារដោយបង្ខំ អនុលោមតាមគោលនយោបាយដ៏តឹង តែងបំផុតរបស់ ប៉ុល ពត ជាមួយនឹងរចនាសម្ព័ន្ធ និងរបៀបពិនិត្យតាមដានដ៏ចម្លែក និងមានប្រសិទ្ធភាពនៃរបបដឹកនាំនេះ ក្នុងបំណងស្វែងរកខ្មាំង និងវិសុទ្ធកម្មបក្ស។ គោលនយោបាយ មានចរិតបង្ក្រាប កម្ទេច ឬសម្រិតសម្រាំងនេះ មានចែងសូម្បីក្នុងរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មាត្រា១០ដែលបានបញ្ញត្តិថា «ចំពោះប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញជា ខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន ត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត។ សេចក្តីសម្រេចក្នុងឆ្នាំ១៩៧៦ នៃគណៈកម្មាធិការមជ្ឈិមបក្ស ដែលជាស្ថាប័នកំពូល បានបង្ហាញច្បាស់នូវសិទ្ធិសម្រេចកម្ទេចក្នុង និងក្រៅជួរបក្ស «បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច»។ ពាក្យ «សម្រិតសម្រាំង» មានន័យថា «ដកសមាសភាព ខ្មាំង ចេញពីក្នុងជួរ ពីក្នុងកងទ័ព ពីក្នុងប្រជាជន ដើម្បីឲ្យជួរឲ្យកងទ័ពឲ្យប្រជាជនស្អាត»។

ក្នុងបរិបទនេះ មិនមាននរណាមួយ សូម្បីមេដឹកនាំជាន់ខ្ពស់ ហ៊ានជំទាស់នឹងគោលនយោបាយជាសមូហភាព របស់បក្សទេ។ កម្មាភិបាលហ៊ានជំទាស់ នឹងត្រូវបានចាត់ទុកថាជាខ្មាំង ដែលនឹងត្រូវទទួលរងនូវការកសាងខ្លួន ឬការចាប់ខ្លួន និងសម្លាប់។ ស.ច.ស.ជ បានរកឃើញថា យ៉ាងហោចណាស់មានកម្មាភិបាលជាន់ខ្ពស់ចំនួន ៦០រូប ដូចជា កុយ ធួន (លេខាភូមិភាគឧត្តរ) រស់ ញឹម (លេខាភូមិភាគពាយ័ព្យ) និង វន វេត (សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍) ដែលត្រូវបានចាប់ខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខស-២១ ដោយសារតែត្រូវបានចោទប្រកាន់ថា ជាខ្មាំង ឬពាក់ព័ន្ធនឹងនិន្នាការប្រឆាំងបដិវត្តន៍។ ក្នុងបរិបទនេះហើយ ដែលក្នុងខ្លឹមសារនៃដីកាដំណោះស្រាយ ០០៤/១ (សម្អាងហេតុ) សហចៅក្រមស៊ើបអង្កេតបានអះអាងថា ទោះបីជាកម្មាភិបាលណាមួយមានគំនិតផ្តួចផ្តើម ក៏មិនគ្រប់គ្រាន់ដើម្បីចាត់ទុកថាជាជនទទួលខុសត្រូវខ្ពស់បំផុតដែរ។

ភស្តុតាងជារួម បានបង្ហាញថា អោ អាន មានតំណែងធម្មតា មិនហួសពីបន្ទាត់នៃអំណាច ដែលត្រូវបានផ្តល់ឲ្យ។ គាត់មិនមានអំណាច de facto ដែលគាត់អាចផ្តួចផ្តើមសកម្មភាព និងជំរុញសកម្មភាពបទឧក្រិដ្ឋ។ នេះដោយសារ អោ អាន មិនមែនជាលេខាតំបន់ស្វយ័ត។ សកម្មភាពនានារបស់ អោ អាន មិនមានលក្ខណៈជាចម្បង និងលេចធ្លោ ដែលជំរុញឲ្យមានការប្រព្រឹត្តបទល្មើស។ សកម្មភាពរបស់គាត់មិនស្ថិតនៅកៀកកិត នឹងការប្រព្រឹត្តបទល្មើសទេ។ ស.ច.ស.ជ រកឃើញថា នេះខុសពីអំណាច ឥទ្ធិពល និងការចូលរួមរបស់ ឌុច ដែលមានភាពសកម្ម កៀកកិតនឹងការប្រព្រឹត្តបទល្មើស ជំរុញសកម្មភាព និងមានទំនាក់ទំនងផ្ទាល់ជាមួយ នួន ជា និង សុន សេន។

សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា អោ អាន ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក។ ទោះបីជាយ៉ាងនេះក្តី ផ្អែកលើអង្គហេតុ ការបកស្រាយកិច្ចព្រមព្រៀង និងច្បាប់ស្តីពី អ.វ.ត.ក ការពិនិត្យមើលការចូលរួម អំណាច និងតួនាទីរបស់ជនត្រូវចោទ អោ អាន បង្ហាញក្នុងដីកាដំណោះស្រាយ ស.ច.ស.ជ សន្និដ្ឋានថា សកម្មភាពរបស់ អោ អាន មានលក្ខណៈមិនផ្ទាល់ និងធូនល្មម ដែលអាចត្រូវបានចាត់ថា «ជាជនទទួលខុសត្រូវខ្ពស់បំផុត» ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ។ អោ អាន ក៏មិនមែនជាមេដឹកនាំជាន់ខ្ពស់ដែរ។ អាស្រ័យហេតុនេះ ស.ច.ស.ជ បានសម្រេចចេញដីកាលើកលែងចោទប្រកាន់ប្រឆាំង អោ អាន។

(តទៅលេខក្រោយ)

សោម ប៊ុនថន

# ដំណឹងជ្រើសរើសនិស្សិតស្ម័គ្រចិត្ត

មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវការជ្រើសរើសនិស្សិតស្ម័គ្រចិត្តចំនួន០៥រូប (អ្នកសរសេរអត្ថបទ ២រូប អ្នកបកប្រែ ២រូប និងក្រាហ្វិកកុំព្យូទ័រ ១រូប) ក្នុងចំណោមនិស្សិតសាកលវិទ្យាល័យនានាឲ្យមកបម្រើការងារចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៨ ដល់ខែមីនា ឆ្នាំ២០១៩ ហើយអាចបន្តទៅតាមគុណភាពការងារ។

១) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការបកប្រែអត្ថបទពីភាសាអង់គ្លេសមកជាភាសាខ្មែរ ឬពីភាសាខ្មែរទៅភាសាអង់គ្លេស។ អត្ថបទដែលនឹងត្រូវបកប្រែគឺអត្ថបទខ្លីនិងវែង ដែលមានលក្ខណៈប្រវត្តិសាស្ត្រ ច្បាប់ និងអត្ថបទពិភាក្សានានា សរសេរដោយមេធាវី សាស្ត្រាចារ្យ អ្នកស្រាវជ្រាវបរទេស ឬសរសេរ ដោយប្រជាជនកម្ពុជា។

២) ការងារស្ម័គ្រចិត្តដែលនឹងត្រូវបំពេញទាក់ទងនឹងការសរសេរអត្ថបទ សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តី «ស្វែងរកការពិត» និងគេហទំព័រ http://www.khmerrougehistory.org

៣) អ្នកក្រាហ្វិកកុំព្យូទ័រ ឬរចនាទស្សនាវដ្តី តម្រូវឲ្យចេះប្រើប្រាស់កម្មវិធី InDesign និងកម្មវិធីផ្សេងៗទៀត ដែលទាក់ទងនឹងការរចនាទស្សនាវដ្តី។

ក្នុងអំឡុងពេលធ្វើការងារស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជា និស្សិតស្ម័គ្រចិត្តទាំងអស់ត្រូវបានលើកទឹកចិត្តឲ្យដាក់ពាក្យចូលរួមវគ្គបណ្តុះបណ្តាល និងបន្តការសិក្សានៅតាមសាកលវិទ្យាល័យនានា ដែលជាដៃគូសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ដូចជា ព្រះរាជាណាចក្រថៃ ហ្វីលីពីន ហុងកុង ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ជាដើម។

**លក្ខខណ្ឌសម្រាប់និស្សិតដែលអាចដាក់ពាក្យបាន មានដូចខាងក្រោម ៖**

១) និស្សិតកំពុងសិក្សាតាមសាកលវិទ្យាល័យរដ្ឋ និងឯកជននានា ដែលអាចប្រើប្រាស់ភាសាអង់គ្លេស។

២) មានអត្តចរិតថ្លៃថ្នូរ ម៉ឺងម៉ាត់ ព្យាយាម និងមានទំនួលខុសត្រូវចំពោះការងារ។

៣) មានចំណាប់អារម្មណ៍ផ្នែកការងារប្រវត្តិសាស្ត្រ ច្បាប់ និងសារព័ត៌មាន។

និស្សិតដែលមានលក្ខណៈសម្បត្តិដូចខាងលើ ហើយមានចំណាប់អារម្មណ៍នឹងការងារស្ម័គ្រចិត្តនេះ សូមផ្ញើពាក្យសុំបម្រើការងារមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ វេលាម៉ោង៥ល្ងាច។

**សូមភ្ជាប់មកជាមួយនូវឯកសារដូចខាងក្រោម ៖**

១) លិខិតសុំធ្វើការងារ ១ច្បាប់ (Cover Letter) ដោយបញ្ជាក់អំពីទឹកចិត្តផ្ទាល់ខ្លួនចំពោះការងារឲ្យបានច្បាស់លាស់ និងក្បោះក្បាយ ដែលសរសេរដោយសាម៉ីខ្លួន។

២) ប្រវត្តិរូបសង្ខេប ១ច្បាប់ (Resume)។

សូមផ្ញើមកកាន់អាសយដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬ អ៊ីម៉ែល៖ truthbunthorn.s@dccam.org។ ប្រសិនបើមានចម្ងល់ សូមទូរសព្ទមកលេខ៖ ០២៣ ២១៤ ០០៩ ឬ ០១២ ៩៩៦ ៧៥០។

**សូមអរគុណ!**

# ភ្នំប្រសិទ្ធិទីតាំងប្រល័យពូជសាសន៍
## ការបំផ្លិចបំផ្លាញ និងការរស់រាននៃសម្បត្តិវប្បធម៌

កម្ពុជាជាប្រទេសតែមួយគត់ដែលចៀសផុតពីការបែងចែកជាពីរនៅក្រោយសន្និសីទក្រុងហ្សឺណែវឆ្នាំ១៩៥៤ដែលរៀបចំដោយពួកមហាអំណាច ដើម្បីកំណត់ជោគវាសនាប្រទេសទាំង ៣គឺវៀតណាមកម្ពុជាវៀតណាម និងឡាវ។ ប៉ុន្តែសន្និសីទទីក្រុងហ្សឺណែវ មិនបាននាំមកនូវសន្តិភាពសម្រាប់ឥណ្ឌូចិនឡើយ សង្គ្រាមមួយបានឆាបឆេះជាថ្មីដោយមានមហាអំណាចកុម្មុយនីស្ត និងសេរីចូលរួម។ ប្រទេសកម្ពុជាបានប្រកាសឯករាជ្យនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នឹងធ្វើការបោះឆ្នោតសាកលមួយនៅឆ្នាំ១៩៥៥ ដើម្បីបង្កើតរដ្ឋាភិបាលមួយដែលទទួលស្គាល់ដោយអង្គការសហប្រជាជាតិ។ ប៉ុន្តែបញ្ហាដែលនៅសេសសល់គឺវត្តមាននៃកងទ័ពបរទេសនៅលើទឹកដីខ្មែរ គឺពួកវៀតមិញដែលរួមដៃជាមួយខ្មែរឥស្សរៈក្រោយមកហៅថាខ្មែរហាណូយ។ តាមកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ តម្រូវឲ្យមានការបែងចែកប្រទេសវៀតណាមជាពីរ ដែលចែកខណ្ឌដោយខ្សែស្របទី១៧ គឺសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងសាធារណរដ្ឋវៀតណាមខាងត្បូង ជាបណ្តោះអាសន្ន។ ការបោះឆ្នោតសកលនឹងតម្រូវឲ្យធ្វើឡើងនៅឆ្នាំ១៩៥៦។ ប៉ុន្តែនៅក្នុងសន្ធិសញ្ញានេះសហរដ្ឋអាមេរិកមិនបានចុះហត្ថលេខាឡើយ។ នៅក្នុងសន្និសីទតំណាងខ្មែរ ឥស្សរៈ ឬខ្មែរវៀតមិញ ដែលមាន




ខ្នោះសម្រាប់ដាក់អ្នកទោសនៅអតីតគុកភ្នំប្រសិទ្ធិ

សមាជិកចំនួន៩.០០០នាក់ ត្រូវបានអង្គសន្និសីទបដិសេធមិនទទួលស្គាល់។ ក្រោយមក ពួកគេត្រូវបានធ្វើដំណើរតាមកប៉ាល់ឆ្ពោះទៅទីក្រុងហាណូយដើម្បីទៅរៀនសូត្រ។ ចំណែកប្រទេសកម្ពុជា ត្រូវដាក់ឲ្យនៅក្រោមនយោបាយអព្យាក្រឹតដោយមិន ត្រូវមានទ័ពបរទេសនៅលើទឹកដី និងមិនចូលបក្សសម្ព័ន្ធ នៅចំពោះមុខសំណួររបស់អ្នកតំណាងកម្ពុជាថា តើត្រូវធ្វើដូចម្ដេចដើម្បីត្រួតពិនិត្យវត្តមានទ័ពបរទេសលើទឹកដីខ្មែរ? ចម្លើយគឺការបង្កើត គណៈកម្មការអន្តរជាតិខាងបទត្រួតត្រាមួយដោយយកអ្នកតំណាងមកពីប្រទេសខាងប្លុកកុម្មុយនីស្តប្លុកសេរី និងប្រទេសមិនចូលបក្សសម្ព័ន្ធ គឺ កាណាដា ប៉ូឡូញ និងឥណ្ឌា។

នៅឆ្នាំ១៩៥៦វៀតណាមខាងជើងបានបង្កើតរណសិរ្សរួបរួមរំដោះជាតិវៀតណាមខាងត្បូង ដែលគាំទ្រដោយចិនប្រជាមានិត និងសហភាពសូវៀត។ ចាប់តាំងពីប្រទេសចិនបានប្ដូរទៅ ជាសាធារណរដ្ឋប្រជាមានិតចិនដែលមានប្រជាជនជាង៥០០លាននាក់ នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៤៩ មកសហរដ្ឋអាមេរិក មានការប្រុងប្រយ័ត្នជានិច្ចចំពោះការរីកសាយនៃលទ្ធិកុម្មុយនីស្តនៅក្នុងទ្វីបអាស៊ី។ នៅពេលដែលសង្គ្រាមឥណ្ឌូចិនលើកទី២ បានឆាបឆេះម្ដងទៀត នៅក្នុងបរិបទនៃសង្គ្រាមត្រជាក់សហរដ្ឋអាមេរិកបានចូលមកជំនួសបារាំងនៅក្នុងភូមិភាគឥណ្ឌូចិន ដើម្បីការពារវៀតណាមខាងត្បូងកុំឲ្យធ្លាក់ចូលក្នុងរបបកុម្មុយនីស្ត ដែលមានបង្អែកពីប្រទេសចិន និងសហភាពសូវៀត។

ដោយប្រទេសកម្ពុជា ជាប្រទេសតូចទន់ខ្សោយ ដែលស្ថិតនៅចន្លោះប្រទេសធំពីរ សម្ដេច នរោត្ដម សីហនុ មានគម្រោងប្រកាន់របបនយោបាយអព្យាក្រឹតដែលមានការទទួលស្គាល់ព្រំដែនប្រទេសកម្ពុជាដោយប្រទេសមហាអំណាច និងប្រទេសជិតខាង។ នៅពេលដែលផ្លូវលំហូជីមិញត្រូវកាត់ផ្ដាច់ដាកង់ដោយការទម្លាក់គ្រាប់បែក គ្រឿងផ្គត់ផ្គង់យុទ្ធោបករណ៍ពីចិន និងសូវៀត នៅក្នុងសង្គ្រាមវៀតណាមត្រូវរាំងស្ទះ។ ចាប់ពីឆ្នាំ១៩៦៦ កំពង់ផែក្រុងព្រះសីហនុ បានដើរតួសំខាន់ក្នុងការនាំអាវុធទៅផ្គត់ផ្គង់ដល់ពួកវៀតកុង (វៀតណាមខាងជើង) ដែលមានជម្រកលើទឹកដីខ្មែរជាពិសេសនៅខេត្តដែលមានព្រៃក្រាស់តាមព្រំប្រទល់ប៉ែកខាងកើតដើម្បីធ្វើសង្គ្រាមប្រឆាំងនឹងសហរដ្ឋអាមេរិកនៅប្រទេសវៀតណាមខាងត្បូង។ ជាលើកដំបូងបន្ទាប់ពីសន្និសីទទីក្រុងហ្សឺណែវមានយួនខាងជើង និងវៀតកុងពី៤០.០០០ ទៅ ៥០.០០០នាក់ស្ថិតនៅលើទឹកដីខ្មែរ។ នៅឆ្នាំ១៩៦៧ តំណាងរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង បើកការិយាល័យជាអចិន្ត្រៃយ៍នៅភ្នំពេញ។ ភារធារីវៀតណាមខាងជើងក៏ត្រូវតម្លើងជាឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា។ ចំណែកសហរដ្ឋអាមេរិក និងបក្សសម្ព័ន្ធត្រូវផ្ដាច់ទំនាក់ទំនងការទូតជាបន្តបន្ទាប់។ ដំបូង មានការផ្អាកទំនាក់ទំនងការទូតជាមួយប្រទេសថៃឆ្នាំ១៩៥៧ ផ្ដាច់ទំនាក់ទំនងការទូតជាមួយ វៀតណាមខាងត្បូង ឆ្នាំ១៩៦៣ ជាមួយសហរដ្ឋអាមេរិក ឆ្នាំ១៩៦៥ ថែមទាំងប្រកាសទាត់ចោលជំនួយហិរញ្ញវត្ថុចំនួន៤០លានដុល្លាក្នុងមួយឆ្នាំ។ ទំនាក់ទំនងមិនប្រក្រតីជាមួយប្រទេសលោក សេរីបណ្ដាលមកពីការរំលោភបូរណភាពទឹកដី ការផ្ដល់ទីតាំងបុស្តិ៍ផ្សាយសំឡេងខ្មែរសេរីប្រឆាំង នឹងកម្ពុជា និងការមិនទទួលស្គាល់ខ្សែបន្ទាត់ព្រំដែនដោយប្រទេសជិតខាង។ ជាញឹកញាប់ សហរដ្ឋអាមេរិក និងវៀតណាមខាងត្បូងតែងឈ្លានពានដោយចំហដោយការទម្លាក់គ្រាប់បែក និងបាញ់រះមកលើភូមិខ្មែរតាមបណ្ដោយព្រំដែនប៉ែកខាងកើត ការវាយប្រហារច្រើនធ្វើឡើង នៅវេលាយប់។ បើតាមការអះអាងរបស់កងជីវពលថា ជួនកាលនៅពេលយប់ស្ងាត់ពួកវៀតកុង បានបាញ់យន្តហោះឈ្លបយកការណ៍អាមេរិកចេញពីទឹកទឹកដីខ្មែរ លុះមួយស្របក់ក្រោយមកភូមិខ្មែរត្រូវកម្ទេចដោយយន្តហោះវាយប្រហារ។ នៅឆ្នាំ១៩៦៥ សហរដ្ឋអាមេរិក បានចោទប្រកាន់កម្ពុជាថា ផ្ដល់ជម្រកឲ្យពួកវៀតកុង។ កន្លងមកមានការឈ្លានពានពីសំណាក់កងទ័ព សហរដ្ឋអាមេរិក និងសម្ព័ន្ធមិត្តវៀតណាមខាងត្បូងមកលើភូមិខ្មែរ នៅតាមខេត្តជាប់ព្រំដែនដូចជា នៅដាក់ដាំ ខេត្តមណ្ឌលគិរី ភូមិចន្ទ្រា ក្នុងខេត្តស្វាយរៀង និងអន្លង់ក្រេះ

ក្នុងខេត្តកំពង់ចាមជាដើម។

នៅឆ្នាំ១៩៦៧ ប្រទេសកម្ពុជាជាប្រទេសនាំអង្ករចេញ ជួបនឹងវិបត្តិដោយសារខ្វះអង្ករ សម្រាប់នាំចេញទៅកាន់ទីផ្សារអន្តរជាតិ។ អង្ករតាមទីផ្សារក្នុងស្រុកមានតម្លៃខ្ពស់ ដោយសារការរត់ពន្ធចេញទៅវៀតណាមដោយពួកមន្ត្រីពុករលួយឃុបឃិតជាមួយពួកឈ្មួញ។ ក្នុងមួយឆ្នាំៗប្រទេសកម្ពុជាបាត់បង់ថវិកាជាតិជាច្រើនក្នុងវិស័យពន្ធដារ ដើម្បីស្តារវិបត្តិនេះ រដ្ឋាភិបាល លោក លន់ នល់ បានរៀបចំគម្រោងប្រមូលទិញស្រូវ ដោយកំណត់តម្លៃទាបជាងទីផ្សារសេរី។ ប្រជាជនបានងើបបះបោរមិនព្រមលក់ស្រូវជូនរដ្ឋ។ ការប្រឈមមុខគ្នារវាងក្រុមកសិករឈាន ដល់ការផ្ទុះអាវុធនៅតំបន់សំឡូត ទាហានបានដេញតាមពួកកុបករហូតដល់ជើងភ្នំវាយចាប។ ទ្រង់ទ្រាយនៃការប្រយុទ្ធ មានការបាញ់ផ្លោងទម្លាក់គ្រាប់បែកកម្ទេចភូមិ កម្ទេចផ្ទះសម្បែង។ នៅពេលការប្រទូសរ៉ាយបានស្ងប់ប្រជាជនវិលចូលផ្ទះសម្បែងដោយគ្មានអ្វីបន្សល់ទុកឡើយ ប្រជាជនត្រូវលក់ដីធ្លី ឬបញ្ចាំ ដើម្បីយកសោហ៊ុយធ្វើដំណើរមកសារភាព នៅមុខព្រះបរមរាជវាំង ដើម្បីទទួលបានការលើកលែងទោស។ ដើមចមនៃអំពើកុបកម្មនេះត្រូវទម្លាក់លើពួកខ្មែរក្រហមទាំងស្រុង។ ពួកបញ្ញវន្ត ៣នាក់មានលោក ខៀវ សំផន ហ៊ូ យន់ និង ហ៊ូ នឹម។ ក្រោយកុបកម្មនេះ បន្តិច ហ៊ូ យន់ និង ខៀវ សំផន បានរត់ចូលព្រៃតាមផ្លូវជាតិលេខ៣ទៅកាន់ភូមិក្បាលអូរ ហៅ ទទឹងថ្ងៃ នៅពេលដែលមានការគំរាមឲ្យតុលាការសឹកកាត់ទោសប្រហារជីវិត។ នៅថ្ងៃ១៧ ខែ មករា ពួកខ្មែរក្រហមបានវាយឆ្មក់លើប៉ុស្តិ៍រដ្ឋាភិបាលនៅបាយដំរាំដោយរឹបអូសយកអាវុធបាន ៣២ដើម។ កាលបរិច្ឆេទនៃការវាយប្រហារនេះត្រូវខ្មែរក្រហមយកធ្វើជាទិវានៃខួបកំណើតកងទ័ពបដិវត្តន៍។

ការទម្លាក់សម្តេច សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គឺជាការបើកទ្វារសង្គ្រាមវៀតណាមចូលមកកម្ពុជា។ របប លន់ នល់ មានទំនុកចិត្តយ៉ាងខ្លាំងទៅលើតួនាទីសហរដ្ឋអាមេរិក នៅលើឧបទ្វីបឥណ្ឌូចិន។ លោក និច សុន ចូលកាន់សេតវិមានជាប្រធានាធិបតីខាងគណបក្សសាធារណរដ្ឋ ពីឆ្នាំ១៩៦៨ ដល់ ឆ្នាំ១៩៧២ ត្រូវលាលែងពីដំណែងដោយរឿងអាស្រូវវ៉ាទ័រហ្គេត។ លោក និច សុន គឺជាប្រធានាធិបតីតែមួយគត់នៅក្នុងប្រវត្តិសាស្ត្រដែលធ្លាក់មុនអាណត្តិ។ គោលនយោបាយរបស់ និច សុន គឺការដកទ័ពចេញពីឥណ្ឌូចិនដើម្បីចៀសវាងភាពអាម៉ាស់ក្នុងតួនាទី ជាមហាអំណាចផុតលេខ។ និច សុន បានគ្រោងដកទ័ពអាមេរិកទាំងអស់ដោយប្រគល់តួនាទីសង្គ្រាមឲ្យវៀតណាមខាងត្បូង ហៅវៀតណាមូបនីយកម្ម។ ការលើកទ័ពចូលមកកម្ពុជា ការជួយរបប លន់ នល់ និងការបង្កើនការទម្លាក់គ្រាប់បែកមកលើកម្ពុជា គឺធ្វើឡើងដើម្បីដកទ័ពតែប៉ុណ្ណោះ។ គំនិតនេះ យើងស្តាប់តាមសំដីរបស់ទ្រង់សិរិមតៈដែលថ្លែងដោយការឈឺចាប់ថា សូមអរគុណដល់ស្ថានទូតសហរដ្ឋអាមេរិក មានន័យថា នយោបាយអាមេរិកនៅឥណ្ឌូចិនជា ល្បែងលេងសើចចំណាយជីវិតប្រជាជនខ្មែរអស់រាប់លាននាក់ប្តូរនឹងតំណែងប្រធានាធិបតី។ នៅក្នុងរយៈពីរឆ្នាំនៃអាណត្តិទី២របស់លោក និច សុន សហរដ្ឋអាមេរិកបានទម្លាក់គ្រាប់លើ ប្រទេសកម្ពុជាច្រើនជាងការទម្លាក់លើទ្វីបអឺរ៉ុប និងតំបន់ប៉ាស៊ីហ្វិកទៅទៀតបើគិតជាតម្លៃ សង្គ្រាមត្រូវចំណាយ២០លានដុល្លាក្នុង១ថ្ងៃ បើប្រៀបធៀបទៅនឹងសង្គ្រាមដែលវៀតណាម លើកទ័ពចូលលុកលុយប្រទេសកម្ពុជាកាលពីថ្ងៃ២៥ ខែធ្នូ ឆ្នាំ១៩៧៨ ក្នុង១ថ្ងៃសហភាពសូវៀតចំណាយត្រឹមតែ៤លានដុល្លាប៉ុណ្ណោះ។ នៅថ្ងៃទិសាន វាទយប់ថ្ងៃទី១៥ ខែសីហា យន្តហោះប៥២បានស្រោចគ្រាប់បែកយ៉ាងសកម្មមកលើទឹកដីកម្ពុជា រហូតដល់ពាក់កណ្តាលយប់។ សហរដ្ឋអាមេរិកដកទ័ពចេញពីឥណ្ឌូចិនគ្មានថ្ងៃត្រឡប់ក្រោយដោយការនឿយណាយសង្គ្រាម និងជួបវិបត្តិផ្ទៃក្នុងធ្ងន់ធ្ងរ។ ដូច្នេះ សម្តីខ្មែរក្រហមនិយាយថា ការជម្លៀសមានមូលហេតុ មកពីការទម្លាក់គ្រាប់បែកជារឿងភូតកុហក។

ការទម្លាក់គ្រាប់បែកលើដែនអធិបតេយ្យភាព ប្រទេសកម្ពុជាធ្វើឲ្យវិនាសទ្រព្យសម្បត្តិ និងផ្តាច់ជីវិតប្រជាជនខ្មែរ

ជិតកន្លះលាននាក់ ចាប់តាំងពីឆ្នាំ១៩៦៤ រហូតមកដល់ឆ្នាំ ១៩៧៣។ ការទម្លាក់សម្តេច សីហនុ ចេញពីតំណែង ប្រជាជនខ្មែរមើលឃើញថា ជារឿងខុសច្បាប់។ ការប្តូរយុទ្ធសាស្ត្រសង្គ្រាមរបស់លោក និច សុន។ អំពើពុករលួយក្នុងរបប លន់ នល់ និងកត្តាមួយ ចំនួនទៀតដូចជាសង្គ្រាមចិត្តសាស្ត្រ(វិន័យនិងស្មារតីប្រយុទ្ធល្អ) និងការគាំទ្រពីប្រទេសចិន។ ម្យ៉ាងវិញទៀត ការលើកទ័ពចូលលុកលុយប្រទេសកម្ពុជាពីសំណាក់កងទ័ពវៀតណាមខាងត្បូងដើម្បីឆក់ប្លន់ទ្រព្យសម្បត្តិ និងធ្វើបាបប្រជារាស្ត្រខ្មែរជាកំហុសធ្ងន់ៗនៃរបប លន់ នល់ ដែលធ្វើឲ្យចលនាតស៊ូរំដោះដណ្តើមបានការគាំទ្រពីប្រជាជនខ្មែរ។

ខ្មែរក្រហមបានបានឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានដឹកនាំប្រទេសតាមមនោគមវិជ្ជា ម៉ៅ ដែលមានលក្ខណៈខុសគ្នាស្រឡះពីមនោគមវិជ្ជាខ្មែរ ដែលមានរាប់ពាន់ឆ្នាំមកហើយ។ ទម្រង់មនោគមវិជ្ជាពីរដែលខ្មែរក្រហមយកមកអនុវត្តហើយដែលជាកំហុសធ្ងន់នៃការដឹកនាំរបស់ ម៉ៅ គឺមាគ៌ាមហាលោតផ្លោះ ត្រូវគេមើលឃើញនៅក្នុងផែនការ៤ឆ្នាំ។ ចំណែកឯបដិវត្តន៍វប្បធម៌ ត្រូវបានគេមើលឃើញតាមរយៈការលុបបំបាត់សាលារៀន ប្រពៃណី ទំនៀមទម្លាប់ សាសនា សិល្បៈ ជំនឿ និងការសម្លាប់រង្គាល។

នៅក្នុងរយៈពេលជាងពាឆ្នាំនៃការគ្រប់គ្រាប្រទេស ត្រូវបានគេមើលឃើញថារបបខ្មែរ ក្រហមជារបបផ្តាច់ការដែលកាប់សម្លាប់ប្រជាជនខ្មែរអស់ជិតពីរលាននាក់។ ក្រៅពីការកាប់សម្លាប់ខ្មែរក្រហមបានប្រមាថទៅលើសាសនា មានការកម្ទេចវត្តអារាម ផ្សឹកព្រះសង្ឃ សម្លាប់ គណៈសង្ឃជាន់ខ្ពស់ ដូចជា សម្តេចសង្ឃរាជ ហួត តាត ព្រះអាចារ្យ សូរ ហាយ វិរិយបណ្ឌិតោ ប៉ាង ខាត់ និងព្រះគ្រូ ប៉ុន សម្ភាជជាដើម។ វត្តអារាមជាទីកន្លែងប្រណិប័តន៍ត្រូវវាយកម្ទេច ឬយកធ្វើជាកន្លែងចិញ្ចឹមជ្រូក ជាចម្ការដំណាំ ជាឃ្លាំង ជាមន្ទីរសន្តមកិច្ច ក្រៅពីនេះខ្មែរក្រហម បានយករូបសំណាក ឬបដិមាករធ្វើពីមាសប្រាក់ ឬសំរឹទ្ធដែលជាស្នាដៃវប្បធម៌ជាមរតកដូនតា



ព្រះវិហារនៅវត្តភ្នំប្រសិទ្ធិ

លក់ឲ្យឈ្មួញបរទេស។ ខ្មែរក្រហមបានកម្ទេចចោលនូវគម្ពីរក្បូនខ្នាតជាស្នាដៃវប្បធម៌ និងសិល្បៈ ដែលមានតម្លៃជាប្រវត្តិសាស្ត្រ។ មិនតែប៉ុណ្ណោះខ្មែរក្រហមបានកម្ទេចវត្តអារាម ឬយកវត្តអារាមសម្រាប់ធ្វើជាឃ្លាំង មន្ទីរសង្គមកិច្ច ឬជាកន្លែងចិញ្ចឹមសត្វ។ ចំពោះសាសនាអ៊ីស្លាម ខ្មែរក្រហម បានហាមប្រាមមិនឲ្យធ្វើពិធីសូត្រធម៌ និងបង្ខំជនជាតិចាមឲ្យហូបសាច់ជ្រូក។ អ្វីដែលមជ្ឈដ្ឋានលោកខាងលិចភ្ញាក់ផ្អើល គឺការកម្ទេចព្រះវិហារគ្រិស្តសាសនាដ៏ធំនៅទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។

របបខ្មែរក្រហមបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដោយសារការវាយលុកពីកងទ័ពវៀតណាមដែលគាំទ្រដោយអាវុធ និងសេដ្ឋកិច្ចពីសហភាពសូវៀត។ នៅក្រោយការដួលរលំជនរងគ្រោះបានស្រែករកយុត្តិធម៌ចំពោះការកាប់សម្លាប់ប្រជាជនដែលគ្មានកំហុស។ តាមអារម្មណ៍ប្រជាជនចង់ឲ្យមានការកាត់ទោសមេដឹកនាំខ្មែរក្រហមក្រៅប្រព័ន្ធច្បាប់។ ជន៥រូបជាមុខសញ្ញានៃការកាត់ទោស គឺ ឌុច ប្រធានមន្ទីរសន្តិសុខស-២១ (គុកទួលស្លែង) នួន ជា ប្រធានរដ្ឋសភា ខៀវ សំផន គណៈប្រធានរដ្ឋ អៀង សារី រដ្ឋមន្ត្រីការបរទេស និង អៀង ធីរិទ្ធ រដ្ឋមន្ត្រីសង្គមកិច្ច។ មិនខុសពីរបបផ្តាច់ការណាហ្ស៊ី មេដឹកនាំកំពូល និងអ្នកទទួលខុសត្រូវក្នុងការកាប់សម្លាប់នៃរបបខ្មែរក្រហម ត្រូវកាត់ទោសដោយតុលាការកូនកាត់មួយ ចូលរួមដោយចៅក្រមអន្តរជាតិ និងចៅក្រមកម្ពុជា ដែលបង្កើតឡើងឆ្នាំ២០០៦ តាមសេចក្តីស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ដោយមានការកាត់ទោសសំណុំរឿង០០១ និង០០២។ សំណុំរឿង០០១ បានកាត់ទោសកាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រធានមន្ទីរសន្តិសុខស-២១ ឲ្យជាប់គុកអស់មួយជីវិត។ សំណុំរឿង០០២ទាក់ទងនឹងមេដឹកនាំកំពូល៤រូបនៃរបបខ្មែរក្រហម សព្វថ្ងៃនៅសល់ពីរនាក់ គឺ នួន ជា និង ខៀវ សំផន ក្នុងសំណុំរឿង០០២ ដែលបានចែកជាពីរផ្នែកទៀតគឺ ផ្នែកទី១) ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគឺការសម្លាប់ទាហានលន់នល់ នៅទួលពោធិ៍ជ្រៃ។ ផ្នែកទី២) ទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺការសម្លាប់ជនជាតិវៀតណាម និងជនជាតិចាម។

ប្រសិនបើតុលាការខ្មែរក្រហមនៅតែបន្តកាត់ក្តីលើឧក្រិដ្ឋជន តុលាការមិនអាចមើលរំលង ឧក្រិដ្ឋកម្មប្រឆាំងសម្បត្តិវប្បធម៌ ឧក្រិដ្ឋកម្មប្រឆាំងសាសនា (ឧក្រិដ្ឋកម្មសង្គ្រាម) និងការធ្វើទុក្ខបុកម្នេញលើសាសនា ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ត្រង់មាត្រាទី២០៩ និង ២១០ ឡើយ ប៉ុន្តែច្បាប់នេះមានលក្ខណៈតូចចង្អៀតពីព្រោះនិយាយចំពោះតែបុគ្គលដែលជាសង្ឃព្រះពុទ្ធសាសនាចំណែកសាសនាដទៃមិនបាននិយាយដល់ឡើយ។ តុលាការត្រូវតែទាញយកច្បាប់អន្តរជាតិមួយចំនួនទៀតមកកាត់ទោសមេដឹកនាំខ្មែរក្រហមដូចជា ៖ អនុសញ្ញាប្រល័យពូជសាសន៍ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៤៨។ ច្បាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទីក្រុង


ខ្លោងទ្វារវត្តភ្នំប្រសិទ្ធិ

រ៉ូម ឆ្នាំ១៩៩៨។ ការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ស្តីពីសម្បត្តិវប្បធម៌។ អនុសញ្ញាឆ្នាំ១៩៥៤ ទីក្រុងឡាអេ ស្តីពីការបំផ្លិចបំផ្លាញបេតិកភណ្ឌវប្បធម៌។ វត្តអារាមចំនួនជាង ៣.០០០ ត្រូវបំផ្លាញ លើកលែងតែវត្តនៅទីក្រុងភ្នំពេញ ខ្លះប៉ុណ្ណោះ ដែលខ្មែរក្រហមរក្សាទុកជាឃ្លាំង។ ព្រះសង្ឃជាង ៦០.០០០អង្គត្រូវចាប់ផ្សឹកធ្វើជាកងចល័ត ឬធ្វើជាយោធា។ សាស្ត្រាស្លឹករឹត គម្ពីរព្រះត្រៃបិតក ច្បាប់ទូន្មាន និងជាស្នាដៃអក្សរសីលដែលបន្សល់តាំងពីសម័យមុនត្រូវបានបំផ្លាញចោល។

នៅរដូវទឹកស្រក ឆ្នាំ១៩៧៦ ការដ្ឋានមហាប្រល័យមួយបានត្រូវចាប់ផ្តើមដោយនាំយកកម្លាំងយុវជន១៧ មេសាប្រហែល ៧.០០០នាក់ចូលរួម មានទីតាំងនៅស្រុកភ្នំស្រុកក្នុងតំបន់៥ នៅក្រោមបញ្ជារបស់គណៈតំបន់ឈ្មោះ ហ៊ីង ជាអតីតសិស្សវិទ្យាល័យព្រះយុគន្ធរ ហៅ ១៨ មីនា រួមទាំងបក្ខពួកជាមួយសមមិត្ត ដាំ ផេង ដែលបានសម្លាប់លោកវេជ្ជបណ្ឌិតសាស្ត្រចារ្យមហាបរិញ្ញា កែវ សង់គីម ជារដ្ឋមន្ត្រីក្រសួងអប់រំ និងលោក ថាច់ ជា ចាងហ្វាងសាលាសកលវិទ្យាល័យភូមិន្ទបច្ចេកទេសក្នុងពេលបាតុកម្ម។ នៅទីនោះ យុវជនរាន់រយនាក់បានស្លាប់ដោយជំងឺ និងធ្វើការងារបាក់កម្លាំងមួយចំនួនទៀតត្រូវនាំយកទៅវាយសម្លាប់នៅព្រៃភ្នំកូនខ្លែងដោយគ្រាន់តែនិយាយពីការស្រេកឃ្លាន និងត្អូញត្អែរពីការនឿយហត់។ មុនចាប់ផ្តើមបើកការដ្ឋាន ហ៊ីង បានបញ្ជាឲ្យរុះរើថ្មបាយក្រៀមដែលជាគ្រឹះផ្លូវបុរាណតភ្ជាប់ទៅប្រាសាទអង្គរ និងប្រាសាទភីម៉ៃ ក្នុងប្រទេសថៃ។ រឿងវិនាសកម្មមួយទៀត គឺការប្រើកងចល័តឲ្យចាក់ដីលុបទ្វារទឹកសម័យអង្គរដែលឆ្លងកាត់ស្ទឹងស្ពានស្រែង មានទម្រង់ដូចគ្នានឹងស្ពានកំពង់ក្តីក្នុងស្រុកជីក្រែងដែរ។ នៅក្រោយការស្ថាបនាអាងត្រពាំងថ្មរួចខ្មែរក្រហមបានប្រៀបប្រដូចទៅនឹងជ័យជម្នះលើសមរភូមិក្នុងការវាយចក្រពត្តិអាមេរិក និងបរិវារដើម្បីរំដោះប្រទេសជាតិនៅថ្ងៃទី១៧ ខែមេសា។

ភ្នំប្រសិទ្ធិ ជារមណីយដ្ឋានដ៏រុងរឿងនៅសម័យសង្គមរាស្ត្រនិយមក្លាយជាឋាននរកមួយដ៏គួរឲ្យភ័យខ្លាចនៅសម័យខ្មែរក្រហម។ គុកភ្នំប្រសិទ្ធិ ឬមន្ទីរអប់រំ០១ ដើរតួនាទីយ៉ាងទូលំទូលាយ និងសកម្មបំផុតក្នុងការប្រមូលអ្នកទោសនៅក្នុងភូមិភាគបស្ចិមទាំងមូល។ ភូមិភាគនេះក៏សម្បូណ៌ជនជាតិចាមរស់នៅ ជាពិសេសនៅតំបន់៣២ ទំហំនៃការកាប់សម្លាប់ និងការធ្វើទុក្ខបុកម្នេញទៅលើសាសនិកអ៊ីស្លាមកើតមានគួរឲ្យកត់សម្គាល់។ គុកភ្នំប្រសិទ្ធិគ្រប់គ្រងដោយមេគុកឈ្មោះ ទិត ជាអតីតសិស្សវិទ្យាល័យទេពប្រណម្យចូលបដិវត្តន៍ នៅឆ្នាំ១៩៧២។ អ្នកទោសភាគច្រើនជាកម្មាភិបាលជាន់ទាបថ្នាក់មធ្យម និងសាច់ញាតិរបស់កម្មាភិបាល។ គណៈតំបន់៣២ និងយាយ លី ជាគណៈស្រុកខដុគ្គ ត្រូវជាប្រពន្ធ ដូ ផេត ជាគណៈភូមិភាគបស្ចិម ត្រូវជាប់គុកនៅទីនោះដែរ បន្ទាប់ពី ដូ ផេត ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១។ ចំពោះប្រភេទនៃទោសមានពីរប្រភេទ គឺទោសសីលធម៌ និងក្បត់បក្ស។ ទោសសីលធម៌ត្រូវអនុវត្តទារុណកម្មកាចសាហាវបំផុត មានការសម្លាប់តាមផ្លូវដោយដុតទាំងរស់ ឬចងឲ្យរត់តាមក្រោយសេះ។ អ្នកទោសធ្ងន់ដែលមានច្រវាក់ជើង និងច្រវាក់ក ត្រូវស្លាប់តែហោងដោយគ្រាប់មីននៅវេលាម៉ោងប្រហែល៧យប់ នៅពេលដែលខ្មែរក្រហមដឹងថាកងទ័ពវៀតណាមចូលកាន់តែកៀកភ្នំប្រសិទ្ធិ។ ចំណែកឯឆ្មាំគុកកម្មាភិបាលខ្មែរក្រហម និងអ្នកទោសស្រាលមួយចំនួនបានរត់ទៅកាន់ផ្លូវជាតិលេខ៥១។

នៅក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនខ្មែរបានវិលត្រឡប់មកស្រុកកំណើតដោយក្តីអស់សង្ឃឹម គ្មានផ្ទះសម្បែង គ្មានសាលារៀន គ្មានមន្ទីរពេទ្យ គ្មានវត្តអារាម គ្មានក្រដាសប្រាក់ គ្មានផ្សារ មានតែរបស់ប្តូរជាមួយរបស់។ ដើម្បីបំពេញអ្វីដែលបាត់បង់ ប្រជាជនខ្មែរត្រូវក្រោកឈរដោយខ្លួនឯងជាមួយរដ្ឋាភិបាល និងសហគមន៍អន្តរជាតិអស់រយៈពេលជាង១០ឆ្នាំ ទំរាំជួសជុលបាននូវអ្វីដែលបាត់បង់នៅក្នុងអតីតកាលដ៏ខ្លោចផ្សា។

ស៊ីវ ធួន

# រឿងរ៉ាវរបស់ជនរងគ្រោះណាខ្លះដែលគួរត្រូវលើកយកមកនិយាយ?

## ការស្រាវជ្រាវពីការលើកឡើងនៃភាពជាជនរងគ្រោះ នៅក្នុងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក

ចាប់តាំងពីទសវត្សរ៍ទី៨០មក សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជ-សាសន៍ជើងឯក បានប្រែក្លាយជាទីតាំងភស្តុតាង រំឭកការចងចាំនិងការអប់រំពីរបបខ្មែរក្រហម។ ជារៀងរាល់ឆ្នាំ ទីតាំងប្រវត្តិសាស្ត្រទាំងពីរនេះ បានទាក់ទាញភ្ញៀវទេសចររាប់ពាន់នាក់ពីជុំវិញពិភពលោកមកចូលទស្សនា ហើយត្រូវបានចុះក្នុងបញ្ជីជាតំបន់ទេសចរណ៍ដែលមានភ្ញៀវចូលទស្សនាច្រើនក្នុងចំណោមទីតាំងផ្សេងទៀតរបស់ភ្ញៀវទេសចរ ក្នុងអំឡុងដំណើរមកកាន់ប្រទេសកម្ពុជា។

ដំណើរមកទស្សនាទីតាំងទាំងនេះ បានឆ្លុះបញ្ចាំងពី «ដំណើរទេសចរណ៍ទៅកាន់ទីតាំងងងឹតអន្ធការ ដែលមានការសម្លាប់រង្គាល»។ ឃ្លានេះ ត្រូវបានប្រើប្រាស់ដើម្បីរៀបរាប់ពីដំណើរទស្សនារបស់ភ្ញៀវទេសចរនិងអ្នកធ្វើដំណើរទៅកាន់កន្លែងដែលមានការកើតឡើងនៃការសម្លាប់ ការរងទុក្ខវេទនា ការធ្វើបាប ឬគ្រោះមហន្តរាយ។ ស្របពេលដែលការចាប់អារម្មណ៍របស់មនុស្សជាតិទៅលើទីតាំងដែលមានមនុស្សស្លាប់ មានអាយុកាលដូចគ្នាទៅនឹងការអនុវត្តនៃដំណើរទេសចរណ៍ និងការរំឭកការចងចាំ ដូច្នេះក្នុងរយៈកាលប៉ុន្មានឆ្នាំមកនេះ យើងបានសង្កេតឃើញថា មានការរីកលូតលាស់នៃការស្រាវជ្រាវទៅលើ «ដំណើរទេសចរណ៍ទៅកាន់ទីតាំងងងឹតអន្ធការ ដែលមានការសម្លាប់រង្គាល»។ ការស្រាវជ្រាវភាគច្រើន បានផ្តោតទៅបទពិសោធន៍របស់ភ្ញៀវទេសចរណ៍ និងការអនុវត្តវិធីសាស្ត្រនៃការពន្យល់ អប់រំ និងការគ្រប់គ្រងទីតាំងទេសចរណ៍ងងឹតអន្ធការ។ ទោះបីជាយ៉ាងណាក៏ដោយ កិច្ចការស្រាវជ្រាវនេះ អាចមើលឃើញពីទស្សនយល់ឃើញរបស់បុគ្គល ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងទីតាំងទាំងនេះ គឺជាជនរងគ្រោះ។ តើរឿងរ៉ាវរបស់ជនរងគ្រោះត្រូវបានលើកមកបង្ហាញតាមរបៀបណា? តើជនរងគ្រោះ អាចមានសិទ្ធិគ្រប់គ្រងទៅលើរឿងរបស់ខ្លួនដែលត្រូវបានលើកឡើងបានដែរឬទេ? តើរឿងរ៉ាវអ្វីដែលជនរងគ្រោះមានទំនាក់ទំនងជាមួយទីតាំងទាំងនេះ? តើការអភិ-វឌ្ឍន៍ទៅលើទីតាំងជាក់លាក់មួយចំនួន បានបង្កើតឲ្យមានការយល់ដឹងរបស់យើងទៅលើបទពិសោធន៍របស់ជនរងគ្រោះនៃភាពជាជនរងគ្រោះតាមរបៀបណា?

សំណួរខាងលើបានបង្កើតមូលដ្ឋាននៃគម្រោងស្រាវជ្រាវ ដោយក្រុមការងារស្រាវជ្រាវនៃសកលវិទ្យាល័យ ឃ្វីនប៊ែលហ្វាស ស្ថិតនៅក្នុងចក្រភពអង់គ្លេស ដែលមានចំណងជើងថា រឿងរ៉ាវរបស់ជនរងគ្រោះណាខ្លះដែលគួរត្រូវលើកយក



ក្រុមការងារស្រាវជ្រាវមកពីសកលវិទ្យាល័យ ឃ្វីនប៊ែលហ្វាស និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅព្រលានយន្តហោះខេត្តកំពង់ឆ្នាំង

មកនិយាយ? ភាពជាជនរងគ្រោះ និងដំណើរទេសចរណ៍ទៅកាន់អតីតទីតាំងអន្ទការ នៅក្នុងប្រទេសកម្ពុជា។ ក្នុងកិច្ចការស្រាវជ្រាវជាមួយលោក ឡុង ដានី និងលោក ស៊ាង ចិន្តា នៃក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា លោកស្រីបណ្ឌិត ឆ័រវីល ឡូឌ័រ លោកស្រីបណ្ឌិត ឡូរិន ខែមស្ទ័រ និងលោកស្រីបណ្ឌិត វ៉ាឆែល ឃីលលាន បានដំណើរការស្រាវជ្រាវនៅប្រទេសកម្ពុជា នៅខែមករា ឆ្នាំ២០១៨ ដើម្បីសិក្សាស្រាវជ្រាវទៅលើរបៀបនៃការលើកឡើងពីភាពជាជនរងគ្រោះ នៅក្នុងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក។ ក្រុមការងារស្រាវជ្រាវបានជួបជាមួយអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម អតីតកម្មាភិបាលខ្មែរក្រហម អ្នកតំណាងនៃអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិ បុគ្គលិក និងមន្ត្រីនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអ្នកប្រវត្តិសាស្ត្រ ដែលមានចំណេះដឹងទៅលើប្រវត្តិសាស្ត្រយុគសម័យថ្មីនៃប្រទេសកម្ពុជា។ ក្រុមការងារស្រាវជ្រាវ ក៏បានចូលទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក និងទីតាំងផ្សេងទៀត ទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម ដូចជា ព្រលានយន្តហោះកំពង់ឆ្នាំង គុកក្រាំងតាចាន់ និងវត្តអំពែភ្នំ។

ចំណុចសំខាន់មួយចំនួន បានពើបប្រទះឡើងពីកិច្ចការស្រាវជ្រាវនេះ។ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ត្រូវបានចាត់ទុកតាមរយៈបទសម្ភាសន៍ថា ជាទីតាំងសំខាន់នៃភ័ស្តុតាង ការចងចាំ និងការអប់រំ។ យ៉ាងណាក៏ដោយ មានទស្សនយល់ឃើញថា មានវិធីសាស្ត្រមួយចំនួនផ្សេងទៀត ដែលទីតាំងទាំងនេះអាចក្លាយជាកន្លែងនៃភ័ស្តុតាង ការចងចាំ និងការអប់រំ ដោយបានលើកឡើងពីភាពទទួលរងគ្រោះក្នុងរបបខ្មែរក្រហម។ មានញត្តិគាំទ្រការទាមទារឲ្យមានការផ្តល់ព័ត៌មានបន្ថែមអំពីនរណាជាជនរងគ្រោះនិងជាអ្នករស់រានមានជីវិត។ អ្នករស់រានមានជីវិតជាច្រើនបាននិយាយ និងចាត់ទុកខ្លួនឯងជា**ឯកសាររស់**ពីអតីតកាលនិងចង់ទទួលបានឱកាសនិយាយដោយផ្ទាល់ពីរឿងរ៉ាវរបស់ខ្លួនជាមួយភ្ញៀវទេសចរ។ ខណៈសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ផ្តោតទៅលើការធ្វើទារុណកម្ម និងការសម្លាប់ ក៏មានការចង់បានឲ្យមានការលើកឡើងពីគ្រោះមហន្តរាយ និងការរងទុក្ខវេទនាផ្សេងៗ ដូចជា ការបង្ខំឲ្យធ្វើការហួសកម្លាំង និងការបង្អត់អាហារ។ មនុស្សមួយចំនួនបង្ហាញបំណងថា មានទីតាំងផ្សេងទៀតមានទំនាក់ទំនងជាមួយរបបខ្មែរក្រហម ដែលគួរតែអភិរក្ស និងអភិវឌ្ឍន៍ឲ្យទៅជាទីតាំងទេសចរណ៍ ដើម្បីលើកឡើងពីគ្រោះមហន្តរាយដែលបានកើតឡើងទូទាំងប្រទេស។

បន្ថែមពីលើការចង់ទទួលបានឱកាសនិយាយរឿងរ៉ាវរបស់ខ្លួន អ្នករស់រានមានជីវិត ជួនកាលបានបង្ហាញពីបំណងចង់ចូលរួមផ្តល់យោបល់លើការរៀបចំរឿងរ៉ាវ ដែលត្រូវបានលើកឡើងនៅក្នុងទីតាំងទេសចរណ៍។ គោលបំណងនេះមានតំណភ្ជាប់ជាមួយប្រធានបទស្រាវជ្រាវទី២ ដែលបានលើកឡើងអំពីការរកកើតឡើងពីភាពតានតឹង អំពីរឿងរ៉ាវទាំងអស់ដែលត្រូវបានលើកឡើងនៅក្នុងទីតាំងទាំងនេះ។ ការប្រើប្រាស់រូបថត និងការផ្លាស់ប្តូរប្លង់ទីតាំង បានបង្កឲ្យមានទស្សនយល់ឃើញផ្សេងៗគ្នា ដោយមានការជជែកវែកញែកមួយចំនួនថា ទីតាំងទេសចរណ៍អតីតកាលអន្ទការនឹងបង្ហាញខុសអំពីប្រវត្តិសាស្ត្រ ប្រសិនបើទីតាំងទាំងនេះមិនត្រឹមត្រូវ។ វាមានសារសំខាន់ណាស់ចំពោះអ្នកផ្តល់បទសម្ភាសន៍ជាច្រើន ក្មេងជំនាន់ក្រោយបានយល់ពីការពិតពីអតីតកាល ដោយធ្វើឲ្យមានការលើកឡើងរឿងរ៉ាវពិតប្រាកដដ៏មានសារសំខាន់។

ប្រធានបទស្រាវជ្រាវចុងក្រោយ បានភ្ជាប់ទៅនឹងសំណួរថាតើនរណាគួរតែទទួលបានប្រយោជន៍ពីទីតាំងទេសចរណ៍ងងឹតអន្ទការទាំងនេះ។ ឧទាហរណ៍ មានភាពតានតឹងកើតឡើងទៅលើនរណាម្នាក់ អ្នកនោះគួរតែទទួលបានប្រយោជន៍ហិរញ្ញវត្ថុ តាមរយៈថ្លៃសំបុត្រចូលទស្សនា ការលក់សៀវភៅ ឬដំណើរការរកស៊ីនៅក្នុងទីតាំងទាំងនោះ។ បំណងប្រាថ្នា

អភិវឌ្ឍន៍តំបន់ដ៏ទៃទៀត បានផ្សាភ្ជាប់ទៅនឹងក្តីសង្ឃឹមនៃការទទួលបានអត្ថប្រយោជន៍ហិរញ្ញវត្ថុផងដែរ ពីព្រោះអ្នកផ្តល់បទសម្ភាសន៍មួយចំនួនសង្ឃឹមថា ការអភិវឌ្ឍន៍តំបន់ផ្សេងទៀតនេះ អាចជួយដល់អ្នករស់រានមានជីវិត និងសហគមន៍របស់ខ្លួនៗកន្លះអត្ថប្រយោជន៍ហិរញ្ញវត្ថុសម្រាប់ជនរងគ្រោះ បាននាំឲ្យមានអារម្មណ៍ថា ទីតាំងទាំងនេះបាន «ធ្វើអាជីវកម្មទៅលើការឈឺចាប់របស់ជនរងគ្រោះ» និងអាចជួយបន្ថែមទៀតដើម្បីសម្រួលដល់អ្នករស់រានមានជីវិត និងមនុស្សផ្សេងទៀត ដែលត្រូវបានរងគ្រោះដោយអំពើហិង្សាកើតឡើងនៅក្នុងទីតាំងនេះៗ

ប្រធានបទទាំងនេះបង្ហាញពីការពិត ខណៈទីតាំងទេសទេសចរណ៍អតីតកាលអន្ធការ អាចជាកន្លែងសំខាន់នៃការអប់រំ ភ័ស្តុតាង និងការចងចាំៗ ទីតាំងទាំងនេះក៏អាចជាកន្លែងនៃភាពតានតឹង និងការខ្វែងគំនិតគ្នា នៅក្នុងសង្គមក្រោយជម្លោះដែរៗ នេះមិនមានន័យថា ទីតាំងទាំងនេះមិនមានតម្លៃ ហើយមិនអាចផ្តល់ប្រយោជន៍ដល់អ្នកទស្សនា និងអ្នករស់រានមានជីវិតនោះទេៗ ទោះបីជាយ៉ាងណាក៏ដោយ មានកិច្ចការដែលអាចត្រូវបានធ្វើច្រើនទៀត ដើម្បីស្វែងរកវិធីក្នុងការពិគ្រោះយោបល់ជាមួយអ្នករស់រានមានជីវិត ការបញ្ចូលទស្សនយល់ឃើញផ្សេងៗនៅតាមទីតាំងទាំងនេះ និងធានាថា ភាពសម្បូរបែបនៃបទពិសោធន៍ជនរងគ្រោះត្រូវបានបង្ហាញឡើងៗ ក្រុមការងារស្រាវជ្រាវ នឹងធ្វើការក្នុងរយៈពេលប៉ុន្មានខែខាងមុខ ដើម្បីគិតអំពីបញ្ហាទាំងនេះឲ្យកាន់តែស៊ីជម្រៅ ជាមួយគោលដៅនៃការបង្កើតរបាយការណ៍ស្រាវជ្រាវ ដែលពិនិត្យមើលលើប្រធានបទទាំងនេះឲ្យកាន់តែស៊ីជម្រៅៗ

**រ៉ាឆែល ឃីលលាន**

## ដំណឹងប្រកាសរកអត្ថបទសម្រាប់បោះពុម្ពផ្សាយលើទស្សនាវដ្តីស្វែងរកការពិត

ទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានចាប់ផ្តើមបោះពុម្ពផ្សាយដំបូងនៅឆ្នាំ២០០០ៗ ទស្សនាវដ្តីស្វែងរកការពិត បាននិងកំពុងសរសេរ ព្រមទាំងបោះពុម្ពផ្សាយពីរឿងរ៉ាវផ្សេងៗដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម ដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លូតត្រង់ប្រមាណជិតពីរលាននាក់បាត់បង់ជីវិត បែកបាក់គ្រួសារ និងរងការឈឺចាប់រហូតមកដល់សព្វថ្ងៃៗ អត្ថបទទាំងនេះបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការធ្វើឲ្យធូរស្បើយផ្លូវចិត្តសម្រាប់អ្នកដែលនៅរស់រានមានជីវិតការជំរុញឲ្យមានយុត្តិធម៌ និងការផ្សះផ្សានៅក្នុងសង្គមកម្ពុជាទាំងមូលៗ ការសរសេរសាច់រឿងពិតចេញពីបទពិសោធន៍របស់ប្រជាជនកម្ពុជា គឺជាការចូលរួមចំណែកដ៏ធំធេងក្នុងការថែរក្សាការចងចាំនិងជាសារមួយដ៏សំខាន់សម្រាប់អប់រំក្មេងៗជំនាន់ក្រោយឲ្យបានដឹងពីរឿងរ៉ាវរបស់មនុស្សដែលកំពុងរស់នៅជុំវិញខ្លួន ជាពិសេសសាច់ញាតិរបស់ខ្លួន និងប្រវត្តិសាស្ត្រដែលបានកើតឡើងនៅប្រទេសកម្ពុជាក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)ៗ បន្ថែមលើរឿងរ៉ាវប្រវត្តិសាស្ត្រ ទស្សនាដ្តីស្វែងរកការពិតក៏បានសរសេរ និងចែករំលែកនូវព័ត៌មានពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (សាលាក្តីខ្មែរក្រហម) ដែរៗ

បច្ចុប្បន្ន មានប្រជាជនកម្ពុជា និងជនបរទេសបានអាន និងគាំទ្រដល់ការងាររបស់ទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជាៗ អ្នកទាំងនេះបានសរសេរ និងបានផ្ញើរឿងរ៉ាវជីវិតផ្ទាល់ខ្លួន រួមទាំងសាច់ញាតិរបស់ខ្លួនមកចុះផ្សាយនៅលើទស្សនាវដ្តីស្វែងរកការពិតទៀតផងៗ

ដូច្នេះ ប្រសិនបើ អ៊ំ ពូ មីង បងប្អូន មានបំណងចង់បន្តចូលរួមសរសេរ និងមានអត្ថបទ ទាក់ទងនឹងរឿងរ៉ាវពីរបបខ្មែរក្រហម ហើយចង់ចុះផ្សាយនៅលើទស្សនាវដ្តីស្វែងរកការពិត សូមផ្ញើអត្ថបទទាំងនេះមកកាន់ខ្ញុំបាទ សោម ប៊ុនថន លេខទូរសព្ទ ៖ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១៨ ០០៩ អ៊ីម៉ែល ៖ truthbunthorn.s@dccam.org ឬ តាមរយៈអាសយដ្ឋាន ៖ ផ្ទះលេខ ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញៗ សូមអរគុណ!

# ការិយាល័យព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍វិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរគឺ ជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦មហាវិថីព្រះសីហនុខាងកើតវិមានឯករាជ្យ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោងប្រាំបី ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ ដល់ម៉ោង៥។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង មី បូរី តាមរយៈទូរសព្ទលេខ៖ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល៖ truthborey.m@dccam.org។














# បញ្ជីឈ្មោះអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហមចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

គីម យន ហៅ ភាព មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់ស្វាយ ខេត្តកំពង់ធំ ជាកូនរបស់ពូ គូ ជា និងមីង គៀក ជាពេទ្យនៃកងពល៣១០ មានកូនប្រុស ១នាក់ និងស្រី៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៧ នៅកំពង់ស្វាយ ខេត្តកំពង់ធំ។ ខ្មែរក្រហមសម្លាប់ គីម យន ហៅ ភាព នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។

គីម យ៉ុង មានអាយុ២២ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាម ជាពេទ្យយោធាប្រចាំកង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកំពង់សោម ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ៣ បន្ទប់ធំ២។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា គីម យ៉ុង ត្រូវបានខ្មែរក្រហមបញ្ចូលក្នុងគុកទួលស្លែងនៅថ្ងៃទី៧ ខែឧសភា ឆ្នាំ ១៩៧៦ ហើយសម្លាប់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦។

គីម យា ជាទាហានសក្តិ២ មកពីប្រទេសបារាំង ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញ ដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា គីម យា ត្រូវបានខ្មែរក្រហមចាប់ខ្លួនមកពីភូមិតាលៃ ហើយបញ្ចូលក្នុងគុកទួលស្លែងនៅថ្ងៃទី២៨ ឬ៣០ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ គីម យា នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦។

គីម យាត ហៅ កុំ មានអាយុ២៤ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់សៀម ខេត្តកំពង់ចាម ជាកូនរបស់ពូ សយ ផន និងមីង ជី ណន់ ជាប្រធានកងហា មន្ទីរកាត់ដេររដ្ឋ មានប្តីឈ្មោះ ប្រាក់ លួន ហៅ សោ មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ១៩៧៧ នៅមន្ទីរកាត់ដេររដ្ឋ។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ ចំណែកឯប្តីឈ្មោះ ប្រាក់ លួន ត្រូវបានខ្មែរក្រហមចាប់ខ្លួនមកជាមួយប្រពន្ធនៅថ្ងៃជាមួយគ្នា ហើយសម្លាប់ចោលនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧។

គីម យីស៊ុន ហៅ ស៊ាង មានអាយុ៥៥ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតជាទាហាន មានស្រុកកំណើតនៅទ្រាំង ខេត្តតាកែវ ជាកូនលោកតា គិម ចេង និងលោកយាយ ប៉ែន ហិន មានប្រពន្ធឈ្មោះ មាស មុំ មានកូនស្រី៥នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៦ នៅភ្នំស្រុក ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះក បន្ទប់ធំ៨បន្ទប់តូច២។ ខ្មែរក្រហមទំនងជាបញ្ជូន គីម យីស៊ុន ទៅនៅមន្ទីរស-២១ (ក) មុននឹងសម្លាប់ចោលនៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦។

គីម លី ហៅ សេង អ៊ីម មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅល្វាឯម ខេត្តកណ្តាល ជាកូនរបស់ពូ លី និងមីង គីម សេង អ្នកធ្វើចម្ការ មានប្តីឈ្មោះ វណ្ណ ជា ហៅ ម៉ូវ ឬ សុត ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៣ ខែតុលា ឆ្នាំ១៩៧៥ នៅមន្ទីរស្រុកល្វាឯម ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៤។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា មាន

ឈ្មោះ គីម លី នេះច្រើន និងថ្ងៃចាប់ខ្លួនខុសគ្នា រកកំណត់ឲ្យច្បាស់លាស់ពុំបាន។ វ៉ាន់ ដា ឬ វណ្ណ ដា ត្រូវបានខ្មែរក្រហមចាប់ខ្លួនបញ្ជូលមកដល់គុកទួលស្លែងនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម លីង ហៅ លុន មានឋានៈអនុកងហា ខាងថាមពល ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ គីម លីង នៅថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៧៦។

គីម វង់ ជាទាហានសត្តិ២ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦ នៅកំពង់សោម ហើយបញ្ជូនមកដល់គុកទួលស្លែងនៅថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម វាសនា មានអាយុ២៣ឆ្នាំ ក្នុងឆ្នាំ១៩៧៦ ជាអតីតនិស្សិតឆ្នាំទី១ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាម ជាកូនរបស់ពូ គីម ស៊ីនួន និងមីង តាំង ស៊ឹម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរស្រុកកោះធំ ថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៧ បន្ទប់តូច ១។ ខ្មែរក្រហមសម្លាប់ គីម វាសនា នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦។

គីម ស៊ីថា មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតនិស្សិតពេទ្យ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាម ជាកូនរបស់ពូ គីម ស៊ីនួន និង តាំង ស៊ឹម បងបង្កើតរបស់ គីម វាសនា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧៦ នៅភូមិព្រែកស្តី ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៨ បន្ទប់តូច ២។ ខ្មែរក្រហមទំនងជាបញ្ជូន គីម ស៊ីថា ទៅនៅមន្ទីរ ស.២១ (គ) មុននឹងសម្លាប់ចោលនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦ ដូចប្អូនរបស់ខ្លួន គីម វាសនា ដែរ។ ពូ គីម ស៊ីនួន ក៏ត្រូវបានខ្មែរក្រហមចាប់យកមកគុកទួលស្លែង ហើយសម្លាប់នៅថ្ងៃជាមួយកូនៗដែរ។

គីម ស៊ីនួន ហៅ គីម ស៊ីថន មានអាយុ៥០ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតទាហានសត្តិ២ ស្រុកកំណើតនៅស្រុកសង្កែ ខេត្តបាត់ដំបង ជាកូនរបស់តា អ៊ិន គីម និងយាយ នាង ស មានប្រពន្ធឈ្មោះ តាំង វែកស៊ឹម មានកូនស្រី១នាក់ ជាឪពុករបស់ គីម ស៊ីថា និង គីម វាសនា ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅព្រែកស្តី ឃុំព្រែកថ្មី ស្រុកកោះធំ ខេត្តកណ្តាល ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក៨ បន្ទប់ធំ ១៣។ ខ្មែរក្រហមសម្លាប់ទាំងឪពុកនិងកូនប្រុស២នាក់ទៀតខាងលើ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៦។

គីម ស៊ុត មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកោះសូទិន ខេត្តកំពង់ចាម ជាកូនរបស់ពូ ស៊ាង បាន និងមីង អាន សេង ជានីរសារកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្តាត ថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៦ ហើយបញ្ជូនមកឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ១ បន្ទប់ធំ ៥។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ថ្ងៃខែបញ្ចូលក្នុងគុកទួលស្លែង គឺថ្ងៃទី១៣ និង ១៨ ខែឧសភា ទៅវិញ។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម ស្រ៊ន ប្រពន្ធរបស់ឈ្មោះ ហ៊ីង ចុង ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅរោងចក្រស្រា ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ ហើយខ្មែរក្រហមសម្លាប់ចោលនៅថ្ងៃបន្ទាប់គឺថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ រីឯប្តីឈ្មោះ ហ៊ីង ចុង ត្រូវបានខ្មែរក្រហមសម្លាប់នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៦។

គីម សាង មានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតស្នងការនគរបាលតាខ្មៅ មានស្រុកកំណើតនៅត្រកូវ ខេត្តតាកែវ មានឪពុកម្តាយ គីម ឌូ និង គីម ធី ភីន មានប្រពន្ធឈ្មោះ កែវ សុផាន់ណារ៉ា ហៅ កែវ សៃចាយ មានកូនប្រុស៣នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុកភ្នំស្រុក ខេត្តបាត់ដំបង ថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ១ បន្ទប់តូច ១០។

ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម សាផូ ហៅ ឡាតា មានអាយុ៣៥ឆ្នាំ ក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅសង្កែ ខេត្តបាត់ដំបង ជាកូនរបស់អ៊ំ គីម តាន ឈីវ និងអ៊ំស្រី លី ង៉ោ ជាកម្មកររោងចក្រថ្មពិល មានប្រពន្ធឈ្មោះ វង់ សៀន មានកូនប្រុស១នាក់ និងស្រី២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរោងចក្រថ្មពិល ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក.១ បន្ទប់ធំ ៩។ ខ្មែរក្រហមសម្លាប់ គីម សាផូ នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈ ១៥៧ ថ្ងៃ។

គីម សាអឹម ហៅ សាអែម មានអាយុ៣៨ឆ្នាំ ក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅពាមរក៍ ខេត្តព្រៃវែង កូនរបស់អ៊ំ គីម ហ៊ន និងអ៊ំស្រី អ៊ិន គូរ មានប្រពន្ធឈ្មោះ សេក រីម ហៅ អ៊ីម មានកូនប្រុស៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១២ ខែមករា ឆ្នាំ១៩៧៦ នៅរោងចក្រអគ្គិសនីចាក់អង្រែ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៨ បន្ទប់តូច ២។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម សុក ហៅ សឺន មានអាយុ២៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាម ជាកូនរបស់ពូ ថ្វាង ញ៉ាន និងមីង តាក សយ ជាប្រធានកងតូចឋាមពល ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឋាមពល ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ គីម សុក នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងនៅគុកទួលស្លែងអស់រយៈពេល៣៧ថ្ងៃ។

គីម សុខុម មានអាយុ២២ឆ្នាំ ក្នុងឆ្នាំ១៩៧៦ អតីតនិស្សិត មានស្រុកកំណើតនៅកណ្តាលស្ទឹង ខេត្តកណ្តាល ជាកូនរបស់ពូ គីម យុន និងមីង ទែន នួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៦ នៅមន្ទីរពេទ្យរទេះភ្លើង ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងនៅថ្ងៃទី១០ ខែឆ្នាំដដែល ក្នុងផ្ទះ ក បន្ទប់ធំ ២ បន្ទប់តូច ៦។ ខ្មែរក្រហមសម្លាប់ គីម សុខុម នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល៥០ថ្ងៃ។

គីម សុផល មានអាយុ២៨ឆ្នាំក្នុងឆ្នាំ១៩៧៥ អតីតអាកាសចរណ៍កម្ពុជា មានស្រុកកំណើតនៅពញាឮ ខេត្តកណ្តាល ជាកូនរបស់ពូ គីម លន់ និងមីង រស់ យឿន មានប្រពន្ធឈ្មោះ គង់វង់ សុគណាវី ហៅ មុំ មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៧៥ នៅភូមិទួលសង្កែ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ៨ បន្ទប់តូច ១២។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម សុវណ្ណារី ហៅ ដន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឃោសនាក្នុងឆ្នាំ១៩៧៦។ គីម សុវណ្ណារី ជាប្រពន្ធរបស់ ជុំ ណារិត ត្រូវបានខ្មែរក្រហមបញ្ជូនមកគុកទួលស្លែងនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៦។ រីឯ ជុំ ណារិត ជាអតីតសាស្ត្រាចារ្យ ត្រូវបានខ្មែរក្រហមចាប់ខ្លួនជាមួយប្រពន្ធបញ្ជូលមកគុកទួលស្លែងនៅនោះដែរ។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម ឡេង ជាបញ្ជាការវរសេនាតូចកងពល៧០៣ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៧៦ នៅកងពល៧០៣។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម អៀម ហៅ ម៉ាក់ មានអាយុ២៨ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅព្រែកប្រសប់ ខេត្តក្រចេះ ជាកូនរបស់អ៊ំ ទី ហាយ និងអ៊ំស្រី គីម ឯម យុទ្ធជនកងពល៣១០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៧៧។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គីម ឌិន ហៅ មៀច មានអាយុ៥៣ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតគិញសក្តិ៣ មានស្រុកកំណើតនៅល្វាឯម ខេត្តកណ្តាល ជាកូនរបស់តា គីម ឌីន និងយាយ សោម សំ មានប្រពន្ធឈ្មោះ

គឹម ឌីន ហៅ មៀច មានកូនប្រុស៦នាក់ និងស្រី៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពោធិ៍សាត់ ថ្ងៃទី១១ ឆ្នាំ១៩៧៦ ហើយឃុំឃាំងនៅគុកទួលស្លែងក្នុងបន្ទប់ធំ៥បន្ទាប់តូច១០។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ខ្មែរក្រហមបញ្ជូល គឹម ឌិន ក្នុងគុកទួលស្លែងនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៧៦ ហើយថ្ងៃសម្លាប់មានពីរខុសគ្នា គឺមួយនៅថ្ងៃទី១៩ ខែមេសា និងមួយទៀតនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៦។

គឹម ណាង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅឧស្សាហកម្មក្នុងឆ្នាំ១៩៧៦។

គឹម ធី មានអាយុ៣២ឆ្នាំ ក្នុងឆ្នាំ១៩៧៦ អតីតគ្រូបង្រៀននៅសាលាបឋមសិក្សានិរោធរង្សី មានស្រុកកំណើតនៅថ្នល់ ខេត្តកម្ពុជាក្រោម ជាកូនរបស់អ៊ំ គឹម ដាង និងអ៊ំស្រី កៀង ធី សឹង មានប្រពន្ធឈ្មោះ ចៅ ហា មានកូនប្រុស១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំស្រុក ខេត្តបាត់ដំបង ថ្ងៃទី១៨ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៧ បន្ទប់លេខ ៧។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា កាលបរិច្ឆេទនៃការសម្លាប់មានលក្ខណៈខុសគ្នា មួយនៅថ្ងៃទី២៣ ខែឧសភា និងមួយទៀតនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៦ ដូចគ្នា។

គឹម មាស ហៅ ហ៊ាង មានអាយុ៥១ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតនាយការិយាល័យសុរិយោដី មានស្រុកកំណើតនៅទូកមាស ខេត្តកំពត មានប្រពន្ធឈ្មោះ នាង ម៉ុលអឿន មានកូនប្រុស១នាក់ និងស្រី៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ នៅស្រុកភ្នំស្រុក ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៦ បន្ទប់ធំ ៨។ ខ្មែរក្រហមសម្លាប់ គឹម មាស នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៧៦។ យាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថា កាលបរិច្ឆេទនៃការបញ្ជូនមកគុកទួលស្លែងខុសគ្នា មួយនៅថ្ងៃទី១៣ ខែកុម្ភៈ និងមួយទៀតនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៧៦។

គឹម សុផាន់ណា មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៦ អតីតកូនសិស្ស មានស្រុកកំណើតនៅកំពត ខេត្តកំពត ជាកូនរបស់ពូ គឹម ស៊ីនួន និងមីង តាំង ស៊ីម ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅវត្តព្រែកឫស្សី ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ គ បន្ទប់ធំ ២ បន្ទប់តូច ៨។ ខ្មែរក្រហមបញ្ជូន គឹម សុផាន់ណា មកដល់គុកទួលស្លែងនៅថ្ងៃទី២ ខែមីនា ឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។ កំណត់សម្គាល់៖ គឹម សុផាន់ណា ត្រូវជាបងប្អូនបង្កើតជាមួយ គឹម វ៉ាសនា គឹម ស៊ីថា។

គុង ជន ហៅ គឹម យ៉ុង ជាវរសេនាធំនៃកងពល១៧០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើជាបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញា នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារកឃើញថាគុងជនត្រូវបានខ្មែរក្រហមចាប់បញ្ជូនមកដល់គុក ទួលស្លែងនៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

គុណ គយ ហៅ វ៉ាន់ អាយុ១៩ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅឃុំវាលពង់ ស្រុក១៥៣ តំបន់១៥ (ស្រុកឧត្តុង ខេត្តកំពង់ស្ពឺ) ជាកូនរបស់ពូ កៀក គុណ និងមីង យឹម មុត ជាយុទ្ធជនកងពល៤៥០ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៤៥០ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

**វ៉ាន់ ថាន់ពោធិវ៉ា និង ឡុង ដានី**

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# សំបុត្រពីមិត្តភក្តិរបស់ខ្ញុំដែលបានបាត់ខ្លួន

ខ្ញុំសរសេរសារអេឡិចត្រូនិចនេះទៅកាន់អ្នកដោយមានសំណើមួយ។ វាហាក់បីដូចជាសំណើមួយដែលប្លែកៗ ដំបូងខ្ញុំនឹងផ្តល់ជូនអ្នកនូវប្រវត្តិសង្ខេបខ្លះៗដូចខាងក្រោម៖

ខ្ញុំធ្លាប់បានមកប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៧០។ ខណៈពេលនោះ ខ្ញុំមានអាយុ២០ឆ្នាំ។ ខ្ញុំត្រូវបានពន្យារពេលឲ្យចូលធ្វើជាយោធា ដោយសារខ្ញុំមានបញ្ហាសុខភាពកាលពីកុមារភាព ដែលនេះជាមូលហេតុធ្វើឲ្យខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យចូលបម្រើការងារជាកងទ័ពសហរដ្ឋអាមេរិក និងបញ្ជូនទៅប្រទេសវៀតណាម ដូចជាមិត្តភក្តិប្រុសៗដែលខ្ញុំបានស្គាល់នៅក្រៅសាលានៅក្នុងគ្រានោះ។

ហេតុដូច្នេះ ខ្ញុំបានប្រើប្រាស់ពេលវេលាចេញពីស្ថានការណ៍របស់ខ្ញុំឲ្យមានសារប្រយោជន៍ ដោយបានធ្វើជាអ្នកទេសចរណ៍ផ្សងព្រេង ដោយធ្វើដំណើរជុំវិញពិភពលោក។ បន្ទាប់ពីបានធ្វើដំណើរទៅកាន់ប្រទេសអឺរ៉ុប និងអាហ្វ្រិកខាងជើងអស់រយៈពេលប្រហែល៣ខែរួចមក ខ្ញុំក៏បានបញ្ចប់ការធ្វើដំណើររបស់ខ្ញុំនៅតំបន់អាស៊ីអាគ្នេយ៍។ ខណៈពេលដែលខ្ញុំកំពុងធ្វើដំណើរនៅក្នុងប្រទេសថៃ ខ្ញុំបានជួបគ្រូជនជាតិថៃស្រីម្នាក់ដែលបានឲ្យយោបល់ខ្ញុំមកទស្សនាប្រទេសកម្ពុជា។ នាងមានមិត្តភក្តិ២នាក់នៅក្នុងប្រទេសកម្ពុជា គឺ វណ្ណី និង កាន់យ៉ា ដែលជាគ្រូបង្រៀនភាសាអង់គ្លេសដល់ក្មេងៗនៅ



រូបថតរបស់ វណ្ណី និងក្មេងៗក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០

សាលាមួយក្នុងទីក្រុងភ្នំពេញ។ វណ្ណី និង កាន់យ៉ា បានរស់នៅរួមគ្នានៅទីក្រុងភ្នំពេញ។

សរុបសេចក្តីមក ខ្ញុំគ្រាន់តែចង់និយាយថា ខ្ញុំបានបញ្ចប់ការធ្វើដំណើររបស់ខ្ញុំនៅក្នុងទីក្រុងភ្នំពេញ ដោយបានស្នាក់នៅជាមួយ វណ្ណី និង កាន់យ៉ា មួយរយៈពេលក្នុងកំឡុងឆ្នាំ១៩៧០។ យើងបានក្លាយជាមិត្តភក្តិជិតស្និទ្ធនឹងគ្នា។ នៅក្នុងឆ្នាំនោះ មានរឿងរ៉ាវចម្លែកៗ ប៉ុន្តែវាពិតជារឿងរ៉ាវដែលគួរឲ្យចាប់អារម្មណ៍ បានកើតឡើងនៅក្នុង និងជុំវិញទីក្រុងភ្នំពេញ។ ខ្ញុំបានទៅជាមួយ វណ្ណី នៅពេលដែលនាងទៅបង្រៀនសិស្សនៅក្នុងថ្នាក់របស់នាង។ ខ្ញុំចូលចិត្តប្រជាជននៅក្នុងប្រទេសកម្ពុជាណាស់។ ខ្ញុំបានជួបមិត្តភក្តិជាច្រើននាក់របស់នាង។ ខ្ញុំបានទៅចូលរួមពិធីអាពាហ៍ពិពាហ៍ដ៏ស្រស់ស្អាតផងដែរ។ វណ្ណី បានជួយបង្រៀនខ្ញុំអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា និងស្ថានភាពនយោបាយនៅក្នុងប្រទេសកម្ពុជានៅខណៈពេលនោះ។ យើងបានដើរគ្រប់ទីកន្លែង និងនិយាយគ្នាគ្រប់ពេលវេលា។ នៅរដូវផ្ការីកនាពេលនោះ ព្រះអង្គម្ចាស់ នរោត្តម សីហនុ ត្រូវបានដកចេញពីអំណាច ចំណែកឯលោកប្រធានាធិបតី លន់ នល់ ត្រូវបានប្រកាសតែងតាំងឲ្យឡើងកាន់អំណាចជាបន្ទាន់ឲ្យក្លាយទៅជាប្រមុខរដ្ឋពេញលេញមួយ។ ពេលខ្លះ សាកសពត្រូវបានប្រជាជនឃើញអណ្តែតនៅតាមដងទន្លេមេគង្គ។ ពាក្យសម្តីដែលបាននិយាយនៅតាមផ្លូវ គឺខ្មែរក្រហមកំពុងតែខិតចូលតាមតំបន់មួយចំនួននៅជិតទីក្រុងភ្នំពេញ។ ហេតុដូច្នេះហើយ ជារឿយៗប្រជាជនមានអារម្មណ៍ភ័យខ្លាច និងមានកង្វល់ជាខ្លាំង។

ខ្ញុំបានចូលរួមក្នុងសន្និសីទសារព័ត៌មានប្រចាំថ្ងៃ ដែលត្រូវបានគេរៀបចំឡើងនៅបន្ទប់ជាន់ខាងលើនៅក្នុងសណ្ឋាគារក្នុងស្រុកមួយ ដើម្បីកំណត់ថាតើវាមានសុវត្ថិភាពក្នុងការបន្តស្នាក់នៅក្នុងរាជធានីភ្នំពេញដែរឬទេ។ ជាទូទៅ អ្នកដែល






បានមកចូលរួមប្រជុំក្នុងសន្និសីទសារព័ត៌មាននេះគឺជាមន្ត្រីរដ្ឋាភិបាល និងកងទ័ព។ អ្នកកាសែតអន្តរជាតិមួយចំនួនតូចក៏បានចូលរួមក្នុងកិច្ចប្រជុំនោះដែរ។ ថ្ងៃមួយ មានការប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និង ខ្មែរក្រហមបានកើនឡើងដោយនឹកស្មានមិនដល់នៅជិតទីក្រុងភ្នំពេញ បន្ទាប់មកមន្ត្រីក្នុងជួរកងទ័ពបានចេញការដាស់តឿនមួយថា៖ «តើចាកចេញពីប្រទេសកម្ពុជាភ្លាមៗ ឬក៏បន្តការស្នាក់នៅក្នុងប្រទេសកម្ពុជា និងប្រសិនបើមិនមានលទ្ធភាពក្នុងការចាកចេញ»។ ប៉ុន្តែពិតជាគួរឲ្យសោកស្តាយ ខ្ញុំបានចាកចេញពីទីក្រុងភ្នំពេញ។ បន្ទាប់ពីរយៈពេលប្រហែលពី២ទៅ៣ខែក្រោយមក ខ្ញុំបានព្យាយាមរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹង វណ្ណី។ ពិតជានឹកស្មានមិនដល់ សំបុត្រមួយចំនួនរបស់យើងត្រូវបានផ្ញើទៅដល់ដៃ។ ខ្ញុំបានទទួលសំបុត្រចំនួន២ពីនាង។

កន្លងហួសអស់រយៈពេលប្រហែលជា៥០ឆ្នាំមកហើយ រហូតមកទល់សព្វថ្ងៃនេះ បន្ទាប់ពីខ្ញុំបានធ្វើការស្រាវជ្រាវជាច្រើន ខ្ញុំបានរកឃើញសំបុត្ររបស់ វណ្ណី។ ខ្ញុំបានភ្ជាប់សំបុត្រទាំងអស់នៅខាងក្រោមនេះ ដូច្នេះ អ្នកអាចអានសំបុត្រនេះបាន។

សំបុត្រទាំងអស់នេះ គឺជារឿងរ៉ាវផ្ទាល់ខ្លួន។ វាពិតជារំជួលចិត្ត និងក្រៀមក្រំណាស់សម្រាប់ខ្ញុំនៅពេលដែលអានសំបុត្រទាំងអស់ក្នុងពេលនេះ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ខ្ញុំមិនមានភាពខ្មាសអៀនចំពោះការចែករំលែកសំបុត្រទាំងនេះដែរ។ ខ្ញុំសង្ឃឹមថា តាមរយៈការចែករំលែកសំបុត្រទាំងអស់នេះជាមួយអ្នក ជាពិសេស ដើម្បីឲ្យអ្នកអាចទទួលបានព័ត៌មានដើមនៃការទំនាក់ទំនង និងជាយថាហេតុក៏ជាវិធីសាស្ត្រមួយ ដើម្បីស្វែងយល់បន្ថែមអំពីអ្វីដែលបានកើតឡើង និងអាចកើតឡើងចំពោះពួកគេដែរ។ ព័ត៌មានដែលខ្ញុំបានទទួលពីប្រទេសកម្ពុជាក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៧០ នៅពេលដែលខ្ញុំបានត្រឡប់មកផ្ទះរបស់ខ្ញុំនៅឯសហរដ្ឋអាមេរិកវិញ គឺភាគច្រើនជាព័ត៌មានដែលរៀបរាប់អំពីការបង្ហូរឈាម និងភាពវឹកវរនៅក្នុងប្រទេសកម្ពុជា។ ការទទួលបានព័ត៌មានទាំងនោះ បានធ្វើឲ្យក្តីសង្ឃឹមរបស់ខ្ញុំចំពោះការរស់រានមានជីវិតរបស់ពួកគេបានថយចុះ។ ទោះបីជាយ៉ាងណា បំណងប្រាថ្នាដ៏មុតមាំរបស់ខ្ញុំដើម្បីដឹងថាតើមានរឿងអ្វីបានកើតឡើងចំពោះ វណ្ណី និង កាន់យ៉ា នៅតែមាន។

តើមានវិធីសាស្ត្រអ្វីខ្លះដែលអង្គការរបស់អ្នកអាចជួយខ្ញុំដើម្បីស្វែងរកទីតាំងរស់នៅរបស់នាង ឬយ៉ាងហោចណាស់អាចដឹងពីស្ថានភាពរបស់នាង? ប្រសិនបើអ្នកមិនអាចរកឃើញ តើអ្នកអាចដឹងថា មានអង្គការណានៅក្នុងប្រទេសកម្ពុជាកំពុងតែធ្វើកិច្ចការពាក់ព័ន្ធនឹងរឿងរ៉ាវទាំងអស់នេះដែលអាចជួយខ្ញុំដើម្បីស្វែងរកដំណឹងរបស់ពួកគេ? ខ្ញុំនឹងធ្វើដំណើរទៅទីក្រុងភ្នំពេញនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ខាងមុខនេះ។ អរគុណ!




ជេន វេគនើរ

## សំបុត្រលើកទី១ដែល វណ្ណី បានផ្ញើទៅ ដេន ៖
## កំពង់សោម ថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៧០

ជូនចំពោះ ដេន ជាទីស្រឡាញ់

ខ្ញុំគិតថាអ្នកប្រហែលជាបំភ្លេចខ្ញុំហើយ មែនឬទេ? ខ្ញុំគឺជាស្ត្រីម្នាក់ដែលអ្នកបានជួបក្នុងកំឡុងពេលដែលអ្នកបានស្នាក់នៅក្នុងទីក្រុងភ្នំពេញ។

អ្នក គឺជាបុរសម្នាក់ដែលមានចិត្តសណ្ដោសប្រណី ហើយខ្ញុំពិតជាចូលចិត្តអ្នកខ្លាំងណាស់។ អ្នកពិតជានឹកស្មានមិនដល់ទេថាខ្ញុំក្រៀមក្រំខ្លាំងយ៉ាងណា បន្ទាប់ពីអ្នកបានចាកចេញពីប្រទេសកម្ពុជា ហើយ កាន់យ៉ា (មិត្តភក្តិរបស់ខ្ញុំ) ពិតជាខឹងនឹងខ្ញុំខ្លាំងណាស់ ពីព្រោះខ្ញុំមិនអាចហាមឃាត់ចិត្តរបស់អ្នកបាន។

ខ្ញុំតែងតែចងចាំអំពីដំណើរទស្សនារបស់យើងទៅវត្តភ្នំ ផ្សារថ្មី សារមន្ទីរជាតិ និងការដើរកម្សាន្តរបស់យើងនៅលើស្ពាន នៅតាមដងទន្លេមេគង្គ និងនៅសួនច្បារវិមានឯករាជ្យ។ វាពិតជាអនុស្សាវរីយ៍មួយដ៏អស្ចារ្យណាស់សម្រាប់ខ្ញុំ។

ដេន ជាទីស្រឡាញ់! ខ្ញុំបានព្យាយាមសរសេរសំបុត្រទៅអ្នកកាលពីខែមុន ប៉ុន្តែខ្ញុំមិនអាចសរសេរបានទេ ពីព្រោះខ្ញុំមិនដឹងថា តើអ្នករស់នៅក្នុងប្រទេសបារាំង ឬក៏រស់នៅក្នុងសហរដ្ឋអាមេរិក ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំចង់បានរូបថតមួយចំនួនដែលយើងបានថតជាមួយគ្នា។ ខ្ញុំគិតថាអ្នកប្រហែលជាបោះរូបថតទាំងអស់នោះចោលហើយ។

ឥឡូវនេះ ខ្ញុំសូមបញ្ចប់ការសរសេរសំបុត្រត្រឹមនេះ ហើយខ្ញុំសង្ឃឹមថា ខ្ញុំនឹងអាចសរសេរសំបុត្រឲ្យបានវែងជាងនេះនៅពេលក្រោយ។ សូមសរសេរត្រឡប់មកវិញផង!

ដោយក្ដីរីករាយ

វណ្ណី

សេចក្ដីបន្ថែម៖ សព្វថ្ងៃនេះខ្ញុំរស់នៅកំពង់សោម។ ប្រសិនបើអ្នកចង់សរសេរសំបុត្រមកកាន់ខ្ញុំ សូមអ្នកផ្ញើតាមរយៈអាសយដ្ឋានរបស់ខ្ញុំដូចខាងក្រោម ៖

កញ្ញា ស៊ឹម វណ្ណី

ផ្ទះលោក ឆាល ដូវេត

អគារ ៧៨ ស.ល.រ.ព

ក្រុងកំពង់សោម ប្រទេសកម្ពុជា

សំបុត្រមួយច្បាប់នេះត្រូវបានផ្ញើចេញពីប្រទេសកម្ពុជាទៅកាន់សហរដ្ឋអាមេរិក នៅថ្ងៃទី ១០ ខែតុលា ឆ្នាំ១៩៧០។

## សំបុត្រលើកទី២ ដែល វណ្ណី បានផ្ញើទៅ ដេន ៖
## ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៧០
## កំពង់សោម នៅក្រោមពន្លឺព្រះច័ន្ទ

ជូនចំពោះ ដេន ជាទីស្រឡាញ់

ខ្ញុំ ពិតជាអរគុណខ្លាំងណាស់ចំពោះសំបុត្រ និងរូបថតដែលខ្ញុំទើបតែទទួលបាននៅក្នុងថ្ងៃនេះ។

ខ្ញុំពិតជាមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលខ្ញុំបានទទួលដំណឹងពីអ្នក។ ជាការពិតណាស់ ខ្ញុំមិនធ្លាប់បានទទួលសំបុត្រពីអ្នកទាល់តែសោះ។ ខណៈពេលមុន ខ្ញុំបានឲ្យ

អាសយដ្ឋានរបស់បងប្រុសខ្ញុំទៅអ្នក ហើយខ្ញុំក៏ធ្លាប់បានទៅយកសំបុត្រនៅផ្ទះរបស់បងប្រុសខ្ញុំដែរ ប៉ុន្តែគាត់បានប្រាប់ខ្ញុំថា គាត់មិនធ្លាប់បានទទួលសំបុត្រពីអ្នកទេ។ ខ្ញុំពិតជាមិនយល់ទាល់តែសោះថាតើមានរឿងអ្វីកើតឡើង?

ជេន! ខ្ញុំពិតជាចង់យំណាស់នៅពេលដែលខ្ញុំគិតដល់អ្នក។ ចំពោះខ្ញុំ ពេលវេលាដែលយើងបានចំណាយរួមគ្នា គឺជាពេលវេលាមួយដ៏អស្ចារ្យបំផុតនៅក្នុងជីវិតរបស់ខ្ញុំ។ អូ! ជេនជាទីស្រឡាញ់ សព្វថ្ងៃនេះ សុខភាពរបស់ខ្ញុំមិនសូវល្អទេ។ ខ្ញុំឈឺ។ ខ្ញុំមិនសូវចូលចិត្តទីក្រុងភ្នំពេញទេ ដូច្នេះហើយបានជាខ្ញុំមករស់នៅកំពង់សោមប៉ុន្មានខែនេះ។ នៅទីនេះ មានជនជាតិបារាំងជាច្រើនរស់នៅ។ ខ្ញុំស្គាល់លោក ដូវេត និងលោក ខែល ពិច។ ខ្ញុំចង់ប្រើប្រាស់អាស័យដ្ឋានរបស់ពួកគេ ពីព្រោះអាសយដ្ឋានរបស់ខ្ញុំមិនច្បាស់លាស់ទេ។

ខ្ញុំសូមទោសផង ជេន! ក្រៅពី កាន់យ៉ា ខ្ញុំមិនធ្លាប់បានទទួលដំណឹងអ្វីពីមិត្តភក្តិផ្សេងទៀតទេ។ កាន់យ៉ា បានសរសេរសំបុត្រមកប្រាប់ខ្ញុំថា នាងសុខសប្បាយទេ។ នាងនឹងរៀបការជាមួយបុរសជនជាតិអាមេរិកាំងម្នាក់ក្នុងពេលឆាប់ៗនេះ។

ជេន! ហេតុអ្វីបានជាអ្នកមិនត្រឡប់មកជួបខ្ញុំនៅក្នុងប្រទេសកម្ពុជាវិញ? ជាការពិតណាស់ ពួកយើងអាចមានពេលវេលាជាមួយគ្នា។ ពេលវេលាដើម្បីស្គាល់គ្នា និងជិតស្និទ្ធគ្នាទៅវិញទៅមក។ ប្រសិនបើខ្ញុំមានលុយគ្រប់គ្រាន់ ខ្ញុំនឹងធ្វើដំណើរទៅកាន់សហរដ្ឋអាមេរិក ដើម្បីស្វែងរកអ្នក។ ប៉ុន្តែខ្ញុំ គឺជានារីក្រីក្រម្នាក់។

ដំណើរទស្សនារបស់យើងទៅកាន់វត្តភ្នំ ផ្សារថ្មី និងសារមន្ទីរជាតិ ហើយគ្រប់ពេលវេលាទាំងអស់ គឺយើងបានដើរជាមួយគ្នា ចំណាយពេលវេលារួមគ្នា ដែលការចងចាំទាំងអស់នេះ នឹងស្ថិតក្នុងចិត្តរបស់ខ្ញុំជានិច្ច។ ទោះបីជាអ្នកបានស្នាក់នៅក្នុងទីក្រុងភ្នំពេញរយៈពេលខ្លី ប៉ុន្តែវាពិតជាមានអត្ថន័យជ្រាលជ្រៅបំផុតសម្រាប់ខ្ញុំ។

ជេន! ខ្ញុំពិតជាចង់ដឹងពីសុខទុក្ខរបស់អ្នកខ្លាំងណាស់? ខ្ញុំក៏ចង់ដឹងដែរថា តើអ្នកកំពុងតែធ្វើអ្វីនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា? តើអ្នកបានរៀនភាសាបារាំងដែរឬទេ? តើខ្ញុំអាចក្លាយជាគ្រូរបស់អ្នកបានដែរឬទេ? សូមមេត្តាផ្តល់ដំណឹងដល់ខ្ញុំផង ប្រសិនបើសព្វថ្ងៃនេះ អ្នកទទួលបានការងារធ្វើហើយ។

យប់ជ្រៅហើយ! ខ្ញុំត្រូវតែបញ្ចប់ការសរសេរសំបុត្ររបស់ខ្ញុំ។ អូ! កុំភ្លេចថា គ្រប់ពេលទាំងអស់ដែលខ្ញុំបានអានសំបុត្ររបស់អ្នក ខ្ញុំតែងតែយំ។

លាហើយ!

វណ្ណី

សេចក្តីបន្ថែម ៖ លោក ដូវេត នឹងចាកចេញពីប្រទេសកម្ពុជានាពេលឆាប់ៗខាងមុខនេះ។ ខាងក្រោមនេះជាអាសយដ្ឋានថ្មីរបស់ខ្ញុំ៖

ស៊ឹម វណ្ណី

ផ្ទះលេខ U2 ខែលពិច

អគារ ៧៨ ស.ល.រ.ព

ក្រុងកំពង់សោម ប្រទេសកម្ពុជា

សំបុត្រមួយច្បាប់នេះ ត្រូវបានផ្ញើចេញពីប្រទេសកម្ពុជាទៅកាន់សហរដ្ឋអាមេរិក នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៧០។

បញ្ជាក់៖ខ្លឹមសារខាងលើគឺជាសំណើដែល ជេន វេតនើរ បានសរសេរជាភាសាអង់គ្លេស រួចហើយផ្ញើមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈសារអេឡិចត្រូនិចក្នុងបំណងស្វែងរកដំណឹងមិត្តភក្តិរបស់គាត់ គឺ វណ្ណី និង កាន់យ៉ា ដែលបានបែកគ្នាក្នុងអំឡុងសង្គ្រាមឆ្នាំ១៩៧០។ នៅក្នុងសារអេឡិចត្រូនិចនេះ ជេន ក៏បានភ្ជាប់មកជាមួយនូវសំបុត្រចំនួនពីរដែលគាត់បានទទួលពី វណ្ណី ដែលត្រូវបានបកប្រែចេញពីខ្លឹមសារដើមទាំងស្រុង មកជាភាសាខ្មែរដោយ អ៊ិន សុដាវី អ្នកសរសេរទស្សនាវដ្តីស្វែងរកការពិត។

# អដ្ឋិធាតុ៖ គ្មានអ្វីជាអមតៈ

## បញ្ជីអដ្ឋិធាតុដែលរកឃើញនៅក្រោមបល្ល័ង្កព្រះពុទ្ធរូបក្នុងវត្តលង្កា, ទីក្រុងភ្នំពេញ

*រៀបរៀងដោយ៖ ចាន ប្រាថ្នា, សា ហ្វាទីលី, សុភ័ក្ត្រ ភាណា និង អ៊ិន សុដាវី*
*វិទ្យាស្ថានស្លឹករឹត, ខែកុម្ភៈ ឆ្នាំ២០១៥*

| ល.រ | លេខកូដ | ឈ្មោះជាភាសាអង់គ្លេស | ឈ្មោះ | ភេទ | អាយុ | ថ្ងៃមរណភាព | ទំព័រក្នុងសៀវភៅ |
|---|---|---|---|---|---|---|---|
| ៧៨ | ៧៦៨៣ | Chhit Savit | ឈិត សាវិត | ? | ៣០ឆ្នាំ | ១២/១០/១៩៨៧ | ៥៩ |
| ៧៩ | ៧៦៩២ | Keo Chem | កែវ ចែម | ? | ? | ? | ៦០ |
| ៨០ | ៧៦៩៣ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ៨១ | ៧៧០១ | Prak Phanna | ប្រាក់ ផាន់ណា | ? | ? | ព.ស. ២៥៥-? | ៦០ |
| ៨២ | ៧៧០៥ | Chheng Many | ឆេង ម៉ានី | ? | ? | ១៧/៥/១៩៨៩ | ៦០ |
| ៨៣ | ៧៧០៩ | Kea Channyeun | គា ចាន់យឺន | ? | ? | ? | ៦០ |
| ៨៤ | ៧៧១០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៦០ |
| ៨៥ | ៧៧២៩ | Iv Lay | អ៊ីវ ឡាយ | ស្រី | ៨៣ឆ្នាំ | ២៦/១២/១៩៨៧ | ៦៤ |
| ៨៦ | ៧៧៣១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៦៤ |
| ៨៧ | ៧៧៣២ | Ven Rim | វ៉ែន រឹម | ? | ២៣ឆ្នាំ | ? | ៦៤ |
| ៨៨ | ៧៧៣៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ៨៩ | ៧៧៤០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៦៤ |
| ៩០ | ៧៧៤១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ៩១ | ៧៧៥១ | Bin Dam | ប៊ិន ដាំ | ? | ? | ២៧/០៣/១៩៨៥ | |
| ៩២ | ៧៧៥០ | Pheng Sokhan | ហេង សុខន | ? | ? | ១៥/០៦/១៩៩០ | ៦៧ |
| ៩៣ | ៧៧៧៤ | Yorn | យន | ស្រី | ៦៦ឆ្នាំ | ១៧/១២/១៩៨៩ | ៧១ |
| ៩៤ | ៧៧៨៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧១ |
| ៩៥ | ៧៧៨៨ | Khiev Nop | ខៀវ ណុប | ? | ? | ? | ៧២ |
| ៩៦ | ៧៧៦៥ | Om Sokly | អ៊ុំ សុខលី | ? | ១០ឆ្នាំ | ? | ៦៨ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៩៧ | ៧៧៦៩ | Keo Seu | កែវ សឺ | ? | ៥០ឆ្នាំ | ១១/០៣/១៩៨៨ | ៦៨, ៧៥ |
| ៩៨ | ៧៧៩៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧២ |
| ៩៩ | ៧៧៧៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧១ |
| ១០០ | ៧៨០១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧២ |
| ១០១ | ៧៧៩១ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧៥ |
| ១០២ | ៧៧៩៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧៥ |
| ១០៣ | ៧៧៥៤ | Prum Thuok | ព្រុំ ធូក | ស្រី | ? | ? | ៦៧ |
| ១០៤ | ៧៧៥៧ | Khann Phirun | ខាន់ ភីរុណ | ប្រុស | ? | ? | ៦៧ |
| ១០៥ | ៧៧៦៣ | Yors Khiev | យស ខៀវ | ស្រី | ? | ? | ៦៨ |
| | | Svay Ut | ស្វាយ អ៊ុត | ប្រុស | ? | ? | |
| | | Kong Keorin (Father) | កុង កែវរិន (ឪពុក) | ប្រុស | ? | ? | |
| | | Keo Ngouv | កែវ ង៉ូវ | ស្រី | ? | ? | |
| ១០៦ | ៧៨៥០ | Suon Yem (Yauv) | សួន យ៉ែម (យ៉ូវ) | ? | ? | ១១/០៦/១៩៩០ | ៧៧ |
| ១០៧ | ៧៨៥១ | Duch Sreypeou | ឌុច ស្រីពៅ | ? | ? | ? | ៧៧ |
| ១០៨ | ៧៨៥២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧៧ |
| ១០៩ | ៧៨៥៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧៧ |
| ១១០ | ៧៨៥៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧៧ |
| ១១១ | ៧៨៥៨ | Neary Khun-aun | នារី ឃុនអូន | ស្រី | ២០ឆ្នាំ | ២៩/៥/១៩៨៩ | ៧៨ |
| ១១២ | ៧៨៦០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧៨ |
| ១១៣ | ៧៨៦២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧៨ |
| ១១៤ | ៧៨៦៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៧៨ |
| ១១៥ | ៩១៤៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | |
| ១១៦ | ៧៨៧៣ | Sok Cheat | សុខ ជាតិ | ? | ? | ? | ៧៨ |
| ១១៧ | ៧៨៧៥ | Moul Pamony alias Touch | មូល ប៉ាមុនី ហៅ ទូច | ? | ? | ២៩/១១/១៩៨៨ | ៨១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១៨ | ៧៨៧៦ | Meany Chauv | មានី ចូវ | ស្រី | ? | ២១/០១/១៩៩២ | ៨១ |
| ១១៩ | ៧៨៧៧ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨១ |
| ១២០ | ៧៨៧៨ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨១ |
| ១២១ | ៧៨៨០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨១ |
| ១២២ | ៧៨៨៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨២ |
| ១២៣ | ៧៨៨៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨២ |
| ១២៤ | ៧៨៨៧ | Sa Sokkun | ស សុខគុណ | ស្រី | ? | ១៩៨៥ | ៨២ |
| ១២៥ | ៧៨៨៨ | Bal Samorn | បាល់ សាមន | ស្រី | ? | ? | ៨២ |
| ១២៦ | ៧៨៩០ | Kranh Simean | ក្រាញ់ ស៊ីមាន | ? | ? | ១៥/១២/១៩៩១ | ៨៥ |
| ១២៧ | ៧៨៩៣ | Sapon Thida | សាប៊ុន ធីតា | ? | ? | ? | ៨២ |
| ១២៨ | ៧៩៣៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨៥ |
| ១២៩ | ៧៩២៣ | Moeung Pisey | មឿង ពិសី | ? | ? | ? | ៨៥ |
| ១៣០ | ៧៩៤៤ | Chann Kimly | ចាន់ គីមលី | ? | ? | ? | ៨៥ |
| ១៣១ | ៧៩៥៣ | Tuy Vannthan | ទុយ វ៉ាន់ថន | ? | ? | ? | |
| ១៣១ | ៧៩៥៣ | Tuy Vannthan | ទុយ វ៉ាន់ថន | ? | ? | ? | |
| ១៣២ | ៧៩៥០ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨៦ |
| ១៣៣ | ៧៩៥១ | Ieng Muy-E | អៀង មុយអិ | ស្រី | ៤៣ ឆ្នាំ | ២២/១២/១៩៨៩ | ៨៦ |
| ១៣៤ | ៧៩៥៤ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨៦ |
| ១៣៥ | ៧៩៥៨ | Sok Chanphearom | សុខ ច័ន្ទភារម្យ | ? | ? | ១៨/០៩/១៩៩២ | ៨៩ |
| ១៣៦ | ៧៩៥៦ | Norng Siek | នង សៀក | ? | ? | ? | ៨៦ |
| ១៣៧ | ៧៩៦២ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨៩ |
| ១៣៨ | ៧៩៦៦ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨៩ |
| ១៣៩ | ៧៩៦៩ | Unknown | មិនដឹងឈ្មោះ | ? | ? | ? | ៨៩ |
| ១៤០ | ៧៩៨៧ | Sam Channsinat | សំ ចាន់ស៊ីណាត | ? | ២៣ ឆ្នាំ | ១៣/០៦/១៩៨៩ | ៩០ |

(នៅមានត)

# ដំណឹងស្វែងរកឪពុក

នាងខ្ញុំឈ្មោះ ស៊ូ បូរ៉ាមី ភេទស្រី អាយុ៥១ឆ្នាំ សព្វថ្ងៃរស់នៅក្នុងភូមិ៥ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ។ នាងខ្ញុំជាកូនច្បងនៅក្នុងគ្រួសារ ដែលមានបងប្អូនបង្កើតចំនួន៣នាក់៖ ទី១) នាងខ្ញុំ,ទី២) ស៊ូ ពេជ្រ (ភេទប្រុស),ទី៣) ស៊ូ សុធារី (ភេទស្រី) និង ទី៤) ស៊ូ ស្រីល័ក្ខ (ភេទស្រី)។ នាងខ្ញុំមានម្តាយឈ្មោះ អោម ណារី និងឪពុកឈ្មោះ ស៊ូ ណៃម។

នាងខ្ញុំសូមប្រកាសរកឪពុកឈ្មោះ ស៊ូ ណៃម។ នៅពេលដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសទៅខេត្តកំពង់ស្ពឺ។ នៅទីនោះមិនបានប៉ុន្មានខែផង ខ្មែរក្រហមក៏បានជម្លៀសគ្រួសារនាងខ្ញុំ ទៅរស់នៅស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ នៅឆ្នាំ១៩៧៦ ឪពុករបស់នាងខ្ញុំត្រូវបានខ្មែរ-ក្រហម ហៅទៅរៀនសូត្រនៅផ្សារមួយក្នុងឃុំព្រះនេត្រព្រះ បន្ទាប់មកខ្មែរក្រហមបានយកគាត់ដាក់នៅវត្តព្រះនេត្រព្រះ ជាមួយឈ្មោះ ម៉ែន ហឿន ដែលជាមិត្តភក្តិជិតស្និទ្ធរបស់គាត់ និងអ្នកដែលមានចំណេះដឹងប្រមាណ ៥០នាក់ទៀត។

ក្រោយរបបខ្មែរក្រហមបានដួលរលំ ម្តាយនាងខ្ញុំបានជួបជាមួយអ្នកធ្លាប់ធ្វើម្ហូប និងដាំបាយនៅគុកទួលស្លែង ដែលផ្ទះរបស់គាត់នៅជាប់ជាមួយផ្ទះរបស់ខ្ញុំកាលពីសង្គមចាស់។ គាត់បានប្រាប់ម្តាយខ្ញុំថា គាត់បានឃើញខ្មែរក្រហមដឹកឪពុករបស់ខ្ញុំ ចូលទៅគុកទទួលស្លែងយ៉ាងច្បាស់ផ្ទាល់ភ្នែក។ ទោះបីជាយ៉ាងនេះក្តី នាងខ្ញុំបានខិតខំស្វែងរករូបថត និងចម្លើយសារភាពរបស់ឪពុកខ្ញុំ តែរកមិនឃើញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ ប្រសិនបើបងប្អូនណាបានស្គាល់ ឬធ្លាប់ឮឈ្មោះ ឪពុកនាងខ្ញុំឈ្មោះ ស៊ូ ណៃម សូមមេត្តាទំនាក់ទំនងតាមរយៈអាសយដ្ឋាន៖ ផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឬតាមរយៈទូរសព្ទលេខ៖ ០២៣ ២១៨ ០ ០៩ ឬ ០១២ ៩៩៦ ៧៥០ និងសារអេឡិចត្រូនិច៖ truthbunthorn.s@dccam.org។

**សូមអរគុណ!**



ស៊ូ បូរ៉ាមី បច្ចុប្បន្នជាគ្រូបង្រៀននៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ



ឪពុកម្តាយ និងប្អូនប្រុសរបស់ បូរ៉ាមី




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

*ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥*

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org



A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 227, November 2018 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M BRK, 30 Ocotber 2018.